**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**

Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ឯកសារដើម**
**ORIGINAL/ORIGINAL**
ថ្ងៃ ខែ ឆ្នាំ (Date): 23-Nov-2016, 14:39
CMS/CFO: Sann Rada

**ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៦**

**ម៉ោង ០៩:០១នាទី**

**សវនាការលើកទី៤៤២**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម យ៉ា សុខន  ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូ ឧត្តរា

ចៅក្រម ធូ មណី

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ជា ស៊ីវហ៊័ង

កញ្ញា ម៉ាដាលេណា ហ្គេហ្ស៊ី
*(Ms.Maddalena Ghezzi)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*

លោក សេង លាង

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក លឹវ សុវណ្ណា

លោកស្រី ដូរីន ជិន *(Mrs. Doreen CHEN)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក ហុង គឹមសួន

លោក វ៉ែន ពៅ

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម យ៉ា សុខន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| ចៅក្រម ក្លូឌា ហ្វែនស៍ | អង់គ្លេស |
| លោក នីកូឡាស គូមជែន | ខ្មែរ |
| លោក សេង លាង | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក ហុង គឹមសួន | ខ្មែរ |
| លោកស្រី ដូរីន ជិន | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| សាក្សី 2-TCW-850 | ខ្មែរ |
| ដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-274 | ខ្មែរ |

# ខ្លឹមសារ

**ការសួរសំណួរទៅសាក្សី÷** 2-TCW-850

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ........ ទំព័រ ៣
សួរដោយលោក នីកូឡាស គូមជែន ផ្តើមពី ........ ទំព័រ ៦
សួរដោយលោក សេង លាង ផ្តើមពី ........ ទំព័រ ៤០
សួរដោយលោកស្រី ដូរីន ជិន ផ្តើមពី ........ ទំព័រ ៤៧
សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្តើមពី ........ ទំព័រ ៥៩

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី÷** 2-TCCP-274

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ........ ទំព័រ ៦៧
សួរដោយលោក ហុង គីមសួន ផ្តើមពី ........ ទំព័រ ៧០

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:០៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-850 តាមរយៈប្រព័ន្ធសោតទស្សន៍ពីខេត្តឧត្តរមានជ័យពាក់ព័ន្ធនឹងអង្គហេតុការបោសសម្អាតផ្ទៃក្នុង ហើយអាចនឹងចាប់ផ្តើមស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-274 ទាក់ទងនឹងអង្គហេតុបទបញ្ជានៃការរៀបអាពាហ៍ពិពាហ៍។

ក្រឡាបញ្ជីសវនាការ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលទាំងឡាយដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ សូមអញ្ជើញ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ លើកលែងតែលោកមេធាវី លីវ សុវណ្ណា មេធាវីការពារក្តីលោក នួន ជា អវត្តមាននៅពេលព្រឹកនេះ ដោយមូលហេតុផ្ទាល់ខ្លួន។ ដោយឡែក លោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ហើយសាក្សីដែលត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃនេះ គឺសាក្សីដែលមានរហស្សនាម 2-TCW-850។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិតឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីបានធ្វើសម្បថរួចហើយមុននឹងសក្ខីកម្ម នៅចំពោះមុខអង្គជំនុំជម្រះ ហើយសាក្សីមានមេធាវីប្រឹក្សា លោក ម៉ម រិទ្ធា។ ហើយនៅថ្ងៃនេះមានដើមបណ្តឹងរដ្ឋប្បវេណីបម្រុងមួយរូបដែលមានរហស្សនាម 2-TCCP-274។ សូមអរគុណលោកប្រធាន។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[០៩:០៣:២១]

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រី សែ កុល វុឌ្ឍី។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៦។

មេធាវីការពារក្ដីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះ មិនអាចបកស្រាយថា ការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្ដីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះ គ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៦ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់ នួន ជា ថ្ងៃនេះ មានអាការៈឈឺចង្កេះ អង្គុយយូរមិនបាន និងបានផ្ដល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

[០៩:០៤:៣៩]

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥)នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅខាងក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅខាងក្រោមសាលសវនាការនេះ ក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

មុននឹងចាប់ផ្តើមស្តាប់សក្ខីកម្មសាក្សី 2-TCW-850 អង្គជំនុំជម្រះសូមជម្រាបដល់ភាគីថា អង្គជំនុំជម្រះបានទទួលអ៊ីម៉ែលពីមេធាវីការពារក្តីលោក ខៀវ សំផន ស្នើសុំធ្វើសារណាផ្ទាល់មាត់ ពាក់ព័ន្ធនឹងសំណើសុំរបស់មេធាវីនាំមុខលើការបញ្ជាក់ពីវិសាលភាពនៃសំណុំរឿង០០២/០២។ ទាក់ទងនឹងបទចោទនៃការរំលោភសេពសន្ថវៈនៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ឯកសារ E306/7។ អង្គជំនុំជម្រះសម្រេចតាមសំណើសុំនេះ និងអនុញ្ញាតឲ្យមេធាវីការពារក្តីលោក ខៀវ សំផន ធ្វើសារណាផ្ទាល់មាត់ ពាក់ព័ន្ធនឹងបញ្ហានេះ ក្រោយពេលបញ្ចប់ការស្តាប់សក្ខីកម្មសាក្សី 2-TCW-850 ដូច្នេះសូមភាគីជ្រាប។

[០៩:០៦:០៦]

ជាបន្តទៀត អង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មសាក្សី 2-TCW-850។ អង្គជំនុំជម្រះកត់សម្គាល់ថា សាក្សីរូបនេះ ត្រូវបានស្តាប់ចម្លើយក្នុងកិច្ចស៊ើបអង្កេត ដែលកំពុងដំណើរការនៅក្នុងសំណុំរឿងផ្សេង។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានកំណត់សាក្សីរូបនេះ ស្ថិតនៅក្នុងក្រុម "ក" នៃក្រុមទាំងបីប្រភេទនៅក្នុងអនុស្សរណៈរបស់ខ្លួន (ឯកសារ E319/35)។ ហើយបានស្នើថា សាក្សីរូបនេះគួរប្រើរហស្សនាម ក្នុងគោលបំណងការពារនូវភាពសម្ងាត់នៃកិច្ចដំណើរការស៊ើបអង្កេត។

អង្គជំនុំជម្រះយល់ឃើញថា វិធានការដែលមានកម្រិតបែបនេះ គឺត្រឹមត្រូវសមស្របតាមច្បាប់នៅក្នុងករណីបែបនេះ។ ហើយការបង្គាប់នេះ គឺត្រូវធ្វើឲ្យមានតុល្យភាពគ្នារវាងតម្រូវការនៃសាធារណភាពនៃសវនាការ ជាមួយនឹងការការពារសុច្ចរិតភាពនៃការស៊ើបអង្កេត។ ហើយអង្គជំនុំជម្រះ ក៏សូមរំឭកដល់ភាគីដែរថា ឲ្យគោរពឲ្យបានខ្ជាប់ខ្ជួននូវសេចក្តីណែនាំនៅក្នុងឯកសារ E319/7 ក្នុងការប្រើប្រាស់ឯកសារដាក់បង្ហាញពីសំណុំរឿងផ្សេង។

មន្ត្រីរដ្ឋបាលតុលាការ តើបច្ចេកទេសសោតទស្សន៍រៀបចំរួចហើយឬនៅ?

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តី លោកសាក្សី។ នៅក្នុងកិច្ចដំណើរការសវនាការចំពោះមុខអង្គជំនុំជម្រះតាមសំណើរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ គឺបានប្រើប្រាស់តែរហស្សនាមរបស់លោកទេ។ ហើយលោកសាក្សីមានរហស្សនាម 2-TCW-850។ ហើយជាទូទៅ ភាគីនឹងតែងតែប្រើប្រាស់ហៅលោកក្នុងនាមជាសាក្សីប៉ុណ្ណោះ។ អ៊ីចឹងសូមលោកយល់ថា អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យភាគីពាក់ព័ន្ធ រួមទាំងអង្គជំនុំ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ជម្រះខ្លួនឯង ប្រើនាមត្រកូល និងតាមខ្លួនរបស់លោកជាសាធារណៈក្នុងសវនាការនេះទេ។ លោកមេធាវីប្រឹក្សាសាក្សី លោក ម៉ម រិទ្ធា សូមលោកជួយយកឯកសារ E3/9570 ទៅឲ្យសាក្សីពិនិត្យ។

លោកសាក្សី តទៅនេះ អង្គជំនុំជម្រះសូមឲ្យលោកបញ្ជាក់ពីអត្តសញ្ញាណរបស់លោក ដែលមាននៅក្នុងឯកសារ E3/9570 ដែលមានលេខ ERN ជាភាសាខ្មែរ 00893175, ERN ជាភាសាអង់គ្លេស 00901043 និង ERN ជាភាសាបារាំង 00974986។ សូមលោកសាក្សីពិនិត្យមើលកន្លែងដែលមាន *ហាយឡាយ*ជាពណ៌ទឹកក្រូចថា តើឈ្មោះលោក សញ្ជាតិ ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត មុខរបរ ឈ្មោះឪពុក ឈ្មោះម្ដាយ ឈ្មោះប្រពន្ធរបស់លោក និងចំនួនកូនរបស់លោក ពិតជាត្រឹមត្រូវដែរឬទេ? លោកសាក្សី គ្រាន់តែឆ្លើយថា ការសរសេរនេះពិតជាត្រឹមត្រូវ ឬមិនត្រឹមត្រូវបានហើយ។ លោកសាក្សី តើព័ត៌មានក្នុងឯកសារនេះ ត្រឹមត្រូវដែរឬទេ?

[០៩:០៩:២៦]

2-TCW-850៖

**ឆ៖** បាទ ខ្ញុំសូមគោរពលោកប្រធាន។ បាទ ក្នុងរហស្សនាមដែលបានពិនិត្យក្នុងគម្រោងនេះ គឺ បាទ គឺត្រឹមត្រូវ។

**ស៖** លោកសាក្សី ប្រវត្តិរូបដែលមានសរសេរនៅលើឯកសារនេះ ត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ លោកប្រធាន។

**ស៖** អរគុណលោកសាក្សី។ តាមរបាយការណ៍របស់ក្រឡាបញ្ជីកាលពីព្រឹកមិញ បានបញ្ជាក់ថា តាមសមត្ថភាព និងលទ្ធភាពដែលលោកអាចដឹង គឺលោកមិនមានជាប់ចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន និងបុគ្គលដែលត្រូវបានទទួលយកជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២ នេះទេ។ តើពិតមែនទេ?

លោកសាក្សី ឮទេលោកសាក្សី?

**ឆ៖** បាទ ឮ។ អត់ឮ ដាច់ៗលោកប្រធាន។

**ស៖** អ៊ីចឹងអង្គជំនុំជម្រះអានម្ដងទៀតឲ្យលោកស្ដាប់។ តាមរបាយការណ៍របស់ក្រឡាបញ្ជីកាលព្រឹកមិញបានបញ្ជាក់ថា តាមសមត្ថភាពនិងលទ្ធភាពដែលលោកអាចដឹង គឺលោកមិនមានជាប់ចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយជនជាប់ចោទទាំងពីររូបគឺលោក នួន ជា និង លោក ខៀវ សំផន និងបុគ្គលដែលត្រូវបានទទួលយកជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២ នេះទេ។ តើ

ពិតជាអ៊ីចឹងមែនទេ?

**ធ៖** បាទ ខ្ញុំមិនមានញាតិពន្ធអីជាមួយលោកទាំងពីរទេ លោក នួន ជា និងលោក ខៀវ សំផន។

[០៩:១១:៣៧]

**ស៖** អរគុណលោកសាក្សី។ ហើយថាលោកបានធ្វើសម្បថរួចហើយ មុននឹងផ្ដល់សក្ខីកម្មនាពេលនេះ តើពិតជាអ៊ីចឹងទេ?

**ធ៖** បាទ គឺពិតអ៊ីចឹងហើយ។

**ស៖** អរគុណលោកសាក្សី។ ជាបន្តទៅនេះ យើងប្រាប់អំពីសិទ្ធិនិងករណីយកិច្ចដែលលោក -- ដល់លោកក្នុងឋានៈលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ។ អំពីសិទ្ធិ ក្នុងឋានៈលោកជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការនៅចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬការដែលឲ្យលោកធ្វើអត្ថាធិប្បាយមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ អំពីករណីយកិច្ច ក្នុងឋានៈលោកជាសាក្សី លោកត្រូវតែឆ្លើយរាល់ តបរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែសំណួរណាដែលនាំឲ្យចម្លើយតបរបស់លោក ឬការធ្វើអត្ថាធិប្បាយរបស់លោកនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងប្រាប់អំពីសិទ្ធិរបស់លោករួចហើយអម្បាញ់មិញនេះ។

ក្នុងឋានៈជាសាក្សី លោកត្រូវតែឆ្លើយឲ្យការណ៍ដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរដែលភាគីសួរចំពោះលោក។

លោកសាក្សី តើលោកដែលផ្ដល់សក្ខីកម្ម ឬផ្ដល់កិច្ចសម្ភាសន៍ជាមួយអ្នកស៊ើបអង្កេតនៃការិយា-ល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ ក្នុងពេលកន្លងមក? ហើយប្រសិនបើមាន តើធ្វើប៉ុន្មានដង? ធ្វើនៅពេលណាខ្លះ? ធ្វើនៅកន្លែងណា? សូមអញ្ជើញឆ្លើយ!

[០៩:១៣:៣០]

**ធ៖** បាទ សូមជម្រាបលោកប្រធាន គឺខ្ញុំអត់ឮ ដាច់ៗបាទ។

**ស៖** អង្គជំនុំជម្រះសូមជម្រាបទៅសាក្សីម្ដងទៀតថា តើលោកដែលផ្ដល់សក្ខីកម្ម ឬផ្ដល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ ក្នុងពេលកន្លងមក? ហើយប្រសិនបើមាន តើធ្វើប៉ុន្មានដង? ធ្វើនៅពេលណាខ្លះ ធ្វើនៅកន្លែងណា? សូមអញ្ជើញឆ្លើយ!

**ឆ៖** បាទ គឺស៊ើបអង្កេត គាត់បានមកសួរខ្ញុំនៅនឹងកន្លែងផ្ទះខ្ញុំ គឺប្រហែល*(ឮមិនច្បាស់)*។

**ស៖** អរគុណលោកសាក្សី។ ហើយនៅមុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះនេះ តើលោកបានពិនិត្យមើល ឬបានអាននូវកំណត់ហេតុដែលលោកបានផ្តល់ចម្លើយកាលពីពេលមុនជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ដើម្បីរំឭកការចងចាំដែរឬទេ? សូមឆ្លើយ!

**ឆ៖** បាទ បានអាន បានពិនិត្យនៅតាមសំណួរដែលខ្ញុំបានឆ្លើយពីថ្ងៃមុន គឺបានអាន បានអានហើយ។

**ស៖** អរគុណលោកសាក្សី។ ហើយតាមសមត្ថភាពដែលលោកអាចដឹងបាន តើលោកអាចបញ្ជាក់បានដែរឬទេថា កំណត់ហេតុស្តាប់ចម្លើយដែលលោកបានអាន ដើម្បីរំឭកការចងចាំហ្នឹង វាពិតជាត្រឹមត្រូវ វាស៊ីសង្វាក់គ្នា ស្របទៅនឹងចម្លើយដែលលោកបានផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតកាលពីមុនដែរឬទេ?

**ឆ៖** បាទ គឺបានអាន និងពិនិត្យ ហើយខ្ញុំពិនិត្យទៅឃើញថាវាត្រឹមត្រូវជាខ្សែសង្វាក់ហើយ។

[០៩:១៥:៣៣]

**ប្រធានអង្គជំនុំ៖**

ក្នុងការសួរដេញដោលសាក្សីរូបនេះ អនុវត្តតាមបទប្បញ្ញត្តិ៩១ស្ទួន និងវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះផ្តល់វេទិកាជូនតំណាងសហព្រះរាជអាជ្ញាក្នុងការសួរដេញដោលសាក្សីនេះ មុនភាគីដទៃទៀតក្នុងរឿងក្តី។ ហើយតំណាងសហព្រះរាជអាជ្ញា រួមជាមួយសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេ-ណីមានរយៈពេលពីរវគ្គ។ សូមអញ្ជើញលោកព្រះរាជអាជ្ញាមានសំណួរ!

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** អរុណសួស្តីលោកសាក្សី។ ខ្ញុំព្យាយាមនិយាយឲ្យបានយឺតៗ ប៉ុន្តែបើសិនណាជាលោកមិនយល់ត្រង់កន្លែងណាមួយ លោកអាចសូមសួរការបញ្ជាក់ឡើងវិញ ខ្ញុំនឹងបញ្ជាក់ជូនតាមក្រោយឲ្យបានច្បាស់លាស់។ លោកសាក្សីខ្ញុំមានកំណត់ហេតុស្តាប់ចម្លើយជាច្រើន ដែលលោកបានឆ្លើយ ខ្ញុំចង់យកកំណត់ហេតុស្តាប់ចម្លើយនេះមកសួរលោក។ ទី១ យើងមានកំណត់ហេតុស្តាប់ចម្លើយបី ដែលលោកបានឆ្លើយជូនសហចៅក្រមស៊ើបអង្កេត។ ហើយកំណត់ហេតុស្តាប់ចម្លើយទាំងបីនេះ គឺ<កំណត់ហេតុស្តាប់ចម្លើយទី១>ធ្វើឡើងនៅក្នុងខែកក្កដា ឆ្នាំ២០០៩។ ហើយកំណត់ហេតុស្តាប់ចម្លើយទី២ គឺខែមីនា

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01351192



ឆ្នាំ២០១៣ ហើយចុងក្រោយនេះ គឺខែសីហា ឆ្នាំ២០១៥ គឺឆ្នាំទៅ។ ហើយបន្ថែមលើកំណត់ហេតុស្ដាប់ចម្លើយដែលលោកឆ្លើយជូនសហចៅក្រមស៊ើបអង្កេតនេះ ក៏មានឯកសារកិច្ចសម្ភាសន៍ដែលសម្ភាស ដោយ ឡុង ដានី មកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានសួរលោកអំពី<>ព្រឹត្តិការណ៍<>ដែលលោកបានជួយសង្គ្រោះមនុស្សនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ហើយយើងក៏មាន<កំណត់ហេតុសង្ខេបនៃ>កិច្ចសម្ភាសន៍មួយដោយអ្នកដែលថតខ្សែភាពយន្តម្នាក់ឈ្មោះ ថេត សម្បត្តិ។ តើលោកនៅនឹកឃើញអំពីកិច្ចសម្ភាសន៍ទាំងអស់នេះដែរឬទេលោកសាក្សី?

[០៩:១៨:១០]

**2-TCW-850៖**

**ឆ៖** ខ្ញុំស្ដាប់សំណួរមិនទាន់បានច្បាស់ទេបាទ។

**ស៖** លោកបានជម្រាបជូនអង្គជំនុំជម្រះថា លោកបានឆ្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ថាតើត្រឹមត្រូវដែរទេ នៅក្នុងឆ្នាំ២០០៨ គឺ៨ឆ្នាំកន្លងមកហើយ។ លោកបាននិយាយជាមួយមនុស្សម្នាក់មកពីមជ្ឈមណ្ឌលឯកសារកម្ពុជាឈ្មោះ ឡុង ដានី អំពីព្រឹត្តិការណ៍មួយដែលលោកបានជួយជីវិតមនុស្សនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ លោកនឹកឃើញរឿងនេះទេ?

**ឆ៖** --អត់បានទេ--។

*(មានបញ្ហាបច្ចេកទេស)*

**ប្រធានអង្គជំនុំ៖**

សូមលោកសាក្សីឆ្លើយនឹងសំណួរ!

**2-TCW-850៖**

**ឆ៖** ឮដាច់ៗសំឡេងបាទ លោកប្រធាន។

[០៩:១៩:៤៥]

**លោក នីកូឡាស គូមជែន៖**

យើងគួរទំនាក់ទំនងជាមួយមន្ត្រី អាយ.ធី នេះឬក៏គួរឈប់សម្រាកសិនលោកប្រធាន ដើម្បីរៀបចំឧបករណ៍ដំណើរការបានល្អ ឬក៏ខ្ញុំគួរបន្តការតាំងសំណួរតទៅទៀត?

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

គឺថាមានមនុស្សម្នាក់កំពុងតែទៅពិនិត្យមើលឧបករណ៍នេះហើយ។ អ៊ីចឹងយើងចាំបន្តិចសិន។

**ប្រធានអង្គជំនុំ៖**

មន្ត្រីសោតទស្សន៍សុំរយៈពេល២នាទី ដើម្បីធ្វើឧបករណ៍នេះ។ សូមអង្គុយ!

*(មានបញ្ហាបច្ចេកទេស)*

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន ថាតើយើងគួរនិយាយគ្នាអំពីសំណើសុំរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន សិន ឬក៏យ៉ាងណា?

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកស្រីត្រូវការរយៈពេលប៉ុន្មាន?

**កញ្ញា អង់តា ហ៊្គីសសេ៖**

លោកស្រីចៅក្រម ២នាទីអីទេ គ្រប់គ្រាន់ហើយ។

[០៩:២១:៤២]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមអញ្ជើញមេធាវីស្តាប់នូវសារណាផ្ទាល់មាត់។

**កញ្ញា អង់តា ហ៊្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថាប្រហែលជាមានការភ័ន្តច្រឡំគ្នា។ ខ្ញុំមិនៗឆ្លើយតបទៅនឹងការកត់សម្គាល់របស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទេ។ ខ្ញុំគ្រាន់តែចង់ទាញចំណាប់អារម្មណ៍អង្គជំនុំជម្រះនូវសំណើមួយដែលដាក់កាលពីថ្ងៃទី១៨ ខែមីនា ដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធទៅនឹងវិសាលភាពនៃការរំលោភសេពសន្ថវៈ គឺឯកសារ E306/7។ យើង<បាន> ឆ្លើយតបនៅថ្ងៃទី២៨ ខែមីនា <គឺឯកសារ E306/7/1> គឺមានការឆ្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី ហើយយើងចង់សួរអង្គជំនុំជម្រះថា តើ<នឹងមានការចេញ>សេចក្តីសម្រេច<នាពេលឆាប់ៗនេះ ឬ>យ៉ាងម៉េច ពីព្រោះថានៅក្នុងក្របខ័ណ្ឌនៃសាក្សីដែលនឹងត្រូវមកផ្តល់សក្ខីកម្មអំពីការរៀបអាពាហ៍ពិពាហ៍ មានចម្លើយមួយចំនួនដែលចេញហួសពីវិសាលភាពពាក់ព័ន្ធនឹងរំលោភសេពសន្ថវៈក្នុងក្របខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ ហើយវាពាក់ព័ន្ធទៅនឹងការសួរសំណួររបស់យើងទៅកាន់សាក្សី។

ដូច្នេះខ្ញុំគិតថា វាមានសារៈសំខាន់សម្រាប់ភាគីទាំងអស់។ អ៊ីចឹងដើម្បីចង់ដឹងថាតើគោលជំហររបស់អង្គជំនុំជម្រះយ៉ាងម៉េច ដើម្បីឲ្យយើងអាចរៀបចំខ្លួនបានសម្រាប់ការសួរដេញដោលសាក្សីទាំង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អស់នោះ ពីព្រោះថាវគ្គស្តីអំពីអាពាហ៍ពិពាហ៍នេះនឹងចាប់ផ្តើមឆាប់ៗនេះហើយ។ អ៊ីចឹងយើងចង់ដឹងឲ្យជាមុនដើម្បីឲ្យយើងអាចត្រៀមខ្លួនត្រៀមលក្ខណៈបានល្អ។

[០៩:២៣:៣៤]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតបដោយខ្លី។

**ប្រធានអង្គជំនុំ៖**

អនុញ្ញាតមេធាវី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមឆ្លើយតបដោយខ្លី ដើម្បីឲ្យអង្គជំនុំជម្រះមានព័ត៌មានគ្រប់គ្រាន់។ នៅក្នុងសារណា<សង្ខេប>របស់យើង E306/7 ដែលសហមេធាវីការពារក្តីលោក ខៀវ សំផន ទើបតែលើកឡើងនោះ យើងគ្រាន់តែចង់ស្នើសុំឲ្យមានការបំភ្លឺពាក់ព័ន្ធទៅនឹងបទចោទស្តីអំពីការរំលោភសេពសន្ថវៈនៅក្នុងមន្ទីរស-២១, ក្រាំងតាចាន់ និងសហករណ៍ត្រាំកក់។ នេះជាគោលជំហររបស់ដើមបណ្តឹងរដ្ឋប្បវេណី យើងគិតថាអង្គជំនុំជម្រះទទួលបានបណ្តឹងពាក់ព័ន្ធទៅនឹងអង្គហេតុដែលពាក់ព័ន្ធទៅនឹងការរំលោភសេពសន្ថវៈនៅមន្ទីរសន្តិសុខស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ និងសហករណ៍ត្រាំកក់។ ដូច្នេះវាមានទីតាំងបី ហើយសារណារបស់យើង E306/7នេះ គឺកម្រិតត្រឹមតែស្នើសុំការបំភ្លឺទៅលើទីតាំងទាំងបីនេះតែប៉ុណ្ណោះ លោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីសោតទស្សន៍ តើឧបករណ៍ភ្ជាប់បានល្អហើយនៅ?

អញ្ជើញលោកព្រះរាជអាជ្ញាមានសំណួរបន្ត!

[០៩:២៥:៤៩]

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី ខ្ញុំបានសួរលោកអំពីកំណត់ហេតុស្តាប់ចម្លើយ គឺកំណត់ហេតុស្តាប់ចម្លើយឆ្នាំ២០០៨ យើងបានទទួលឯកសារនេះពីមជ្ឈមណ្ឌលឯកសារកម្ពុជានេះ ដែលលោកបានផ្តល់ចម្លើយទៅជាមួយអ្នកសម្ភាសម្នាក់ឈ្មោះ ឡុង ដានី។ ឥឡូវខ្ញុំព្យាយាមសាកល្បងក្រែងជួយដល់ការចងចាំរបស់លោកបានខ្លះ។ <ជាការចាប់ផ្តើម គាត់បាននិយាយទៅកាន់លោកថា> "ជាពិសេស ខ្ញុំមាន

ចំណាប់អារម្មណ៍ទាក់ទងទៅនឹងការប្រាស្រ័យទាក់ទង<ល្អ>របស់លោក ជាមួយប្រជាជន<ដែលមិនមែនជាអ្នក>មូលដ្ឋាន។ <>តើ<ទំនាក់ទំនងអ្វីដែលលោកមានជាមួយពួកគេ ហើយតើ>លោកជួយសង្គ្រោះ<ពួកគេតាមរបៀបណា>?” <តើលោកចាំអំពីកិច្ចសម្ភាសន៍នេះទេ?>

លោកសាក្សី លោកស្តាប់ខ្ញុំឮដែរ?

**2-TCW-850៖**

**ឆ៖** បាទ ឮដាច់ៗ។

**ស៖** ឥឡូវខ្ញុំព្យាយាមសាកល្បងសួរលោកបន្តទៅមុខបន្តិចទៅទៀតមើល បើសិនមានបញ្ហាសឹមយើងរៀបចំឡើងវិញ។ លោកសាក្សី លោកធ្លាប់បួសជាសង្ឃទេ?

**ឆ៖** បាទ ខ្ញុំធ្លាប់បួសជាសង្ឃបាទ។

**ស៖** នៅក្នុងអំឡុងពេលសង្គ្រាមស៊ីវិលពីឆ្នាំ១៩៧០ដល់៧៥ តើលោកមានចូលរួមក្នុងកងកម្លាំងខាងណាមួយទេ ក្នុងអំឡុងពេលសង្គ្រាមស៊ីវិលនោះ?

**ឆ៖** បាទ ខ្ញុំធ្លាប់ធ្វើឈ្លប។

[០៩:២៨:៣៩]

**ស៖** តើពេលដែលលោកធ្វើឈ្លបនេះ គឺជាឈ្លបរបស់ខ្មែរក្រហមវាយប្រយុទ្ធជាមួយនឹងទាហានលន់ នល់ ឬ?

**ឆ៖** បាទ ធ្វើឈ្លបរបស់ កាលនោះគេហៅ “រណសិរ្ស”។

**ស៖** សូមអរគុណលោកសាក្សី។ សំណួររបស់ខ្ញុំភាគច្រើន គឺផ្តោតទៅលើជ័យជម្នះក្រោយថ្ងៃ ១៧ មេសា ១៩៧៥។ តើលោកអាចជម្រាបជូនតុលាការបានទេ នៅក្នុងឆ្នាំ១៩៧៦នោះ តើលោកមានបានទៅនៅឯស្រុកស្អាងដែរឬទេ?

**ឆ៖** បាទ បាន ខ្ញុំទៅនៅស្រុកស្អាង។

**ស៖** តើថ្នាក់ដឹកនាំខ្មែរក្រហមគេចាត់តាំងឲ្យលោកទៅទីនោះឬ?

**ឆ៖** ស្តាប់អត់ច្បាស់លោកប្រធាន។

**ស៖** ខ្ញុំសូមសួរលោកឡើងវិញ។ លោកគឺមានតួនាទីអនុលេខាស្រុកស្អាង អ៊ីចឹងមែនទេ?

**ឆ៖** បាទ អ៊ីចឹងមែនបាទ។

**ស៖** នៅក្នុងឆ្នាំ១៩៧៦ គឺលោកត្រូវបានចាត់តាំង និងបញ្ជូនឲ្យទៅធ្វើការនៅភូមិភាគកណ្តាល

មែនទេ?

**ឆ៖** បាទ បានចាត់តាំងខ្ញុំមែន នៅឆ្នាំ៧៨។

[០៩:៣១:០៣]

**ស៖** លោក តាមពិតគេចាត់តាំងឲ្យលោកទៅទីនោះនៅក្នុងឆ្នាំ១៩៧៦ទេ <តើត្រឹមត្រូវទេ?> ឥឡូវខ្ញុំសាកព្យាយាម<រំឭកលោក ដោយ>ដកសម្រង់ចម្លើយរបស់លោកជាមួយនឹងមជ្ឈមណ្ឌលឯក-សារកម្ពុជា ជាការថតជាខ្សែអាត់។ កិច្ចសម្ភាសន៍នេះមានថតជាខ្សែអាត់ផង។ ហើយគឺឯកសារ E3/9149, ERN ជាភាសាខ្មែរ 00731242, បារាំង 01101029, អង់គ្លេស 01116146។ លោកសាក្សី លោកមិនបាច់ផ្តោតអារម្មណ៍ទៅលេខ ERN ដែលខ្ញុំអានអម្បាញ់មិញទេណា នេះសម្រាប់តែអង្គជំនុំជម្រះទេ។ ប៉ុន្តែខ្ញុំនឹងអានចម្លើយរបស់លោកដែលលោកបានឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា។ លោកបានឆ្លើយថា៖ “ក្រោយជ័យជម្នះ<ឆ្នាំ>១៩៧៥ ភូមិភាគបានចាត់តាំងឲ្យខ្ញុំទៅដឹកនាំប្រជាជន គឺទៅដឹកនាំប្រជាជននៅស្រុកស្អាង។ ខ្ញុំធ្វើការនៅទីនោះអស់រយៈពេល១ឆ្នាំ ហើយក្រោយមកខ្ញុំបានក្លាយទៅជាអនុប្រធានស្រុកធ្វើការនៅស្រុកស្អាងហ្នឹងបាន១ឆ្នាំដែរ។” ហើយលោកឆ្លើយថា៖ “នៅខែកក្កដាឆ្នាំ<១៩៧៦> ភូមិភាគបានចាត់តាំងឲ្យខ្ញុំទៅធ្វើការនៅភូមិភាគកណ្តាល។” តើចំណុចនេះ វាជួយរំឭកដល់ការចងចាំរបស់លោកទេ ថាលោកនេះ ត្រូវបានគេបញ្ជូនទៅឲ្យធ្វើការនៅភូមិភាគកណ្តាលនៅក្នុងខែកក្កដា ឆ្នាំ១៩៧៦?

**ឆ៖** មិនមែន៧៦ទេ បាទលោក។ ៧៦ហ្នឹង ខ្ញុំនៅ – ៧៦, ៧៧ហ្នឹងខ្ញុំនៅស្អាងនៅឡើយ។

**ស៖** លោកគឺជាលេខានៅស្រុកនៅ<តាំងគោក> តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ អត់ត្រឹមត្រូវទេ។

[០៩:៣៣:៥៦]

**ស៖** លោកសាក្សី <យើង>មានចម្លើយ<របស់លោក ដែលលោកនិយាយថា លោកជាលេខាស្រុកនោះ> ហើយនិងចម្លើយអ្នកផ្សេងទៀត<ក៏និយាយដូច្នេះដែរ។> ខ្ញុំអាចចាក់ឲ្យលោកស្តាប់ផងដែរ <បើចាំបាច់។> លោកបាននិយាយដូច្នោះថា ខ្ញុំសូមលើកឡើង៖ “ខ្ញុំមកស្រុក<តាំងគោក>” ហើយក្រោយមកលោក ឡុង ដានី សួរលោកថា៖ “តើទៅ<តាំងគោក> ដើម្បីធ្វើជាលេខាស្រុកនោះ ឬក៏យ៉ាងម៉េច? លោកឆ្លើយថា៖ បាទ ខ្ញុំពិតជាធ្វើជាលេខាមែន។ ខ្ញុំទៅស្រុក<តាំងគោក> ដើម្បីទទួលយកតំណែងជាលេខា។” នៅពេលនេះ ខ្ញុំនឹងចាក់សំឡេងដែលគេថតលោកកាលពីលើកនោះ នៅពេលដែល

លោកឆ្លើយ ហើយតើលោកពិតជាធ្លាប់កាន់តំណែងជាលេខាស្រុក<តាំងគោក>ដែរឬទេ សូមលោកបញ្ជាក់ឲ្យបានច្បាស់លាស់ ដោយសារតែលោកឆ្លើយនៅទីនោះក្រោមសម្បថ?

**ឆ៖** បាទ ខ្ញុំមិនដែលទៅធ្វើការនៅស្រុកត្រាំកក់ទេ ព្រោះការសរសេរ ឬក៏ការកត់ មិនដឹងជាយ៉ាងម៉េចដែរ ខ្ញុំមិនៗៗ--

**ស៖** ប្រហែលជាឈ្មោះ បញ្ហាលើឈ្មោះ មិនមែនត្រាំកក់ទេ គឺតាំងគោក។

**លោក សេង លាង៖**

មិនមែនត្រាំកក់ គឺតាំងគោក។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** បាទ គឺស្រុកតាំងគោក លោក។ សូមអធ្យាស្រ័យដែលខ្ញុំអានមិនច្បាស់។ តើលោកធ្លាប់កាន់តំណែងជាលេខាស្រុកតាំងគោកនៅភូមិភាគកណ្ដាលដែរឬទេ?

[០៩:៣៥:៥០]

**2-TCW-850៖**

**ឆ៖** នៅតាំងគោកហ្នឹង ខ្ញុំបានធ្វើមួយរយៈបាទ នៅចុងឆ្នាំ។

**ស៖** នៅពេលនេះ ខ្ញុំសូមចាក់ការថតសំឡេងលោកតែម្ដង ហើយខ្ញុំសូមឲ្យខាងទូរបកប្រែ ឬក៏ទូរចាក់សំឡេងហ្នឹងត្រៀមខ្លួនផង បើសិនជាអត់បាន ចាក់អត់បានទេ សូមជម្រាបខ្ញុំ ខ្ញុំអាចបន្តទៅមុខទៀត។

ខ្ញុំអត់ដឹងថាតើសំឡេង ខ្សែអាត់សំឡេងត្រង់ចំណុចតាំងគោកហ្នឹងបានកត់ត្រា ឬបញ្ជាក់ មានស្លាកសម្គាល់ត្រឹមត្រូវ ដើម្បីអាចចាក់បានដែរឬទេ។ លោកសាក្សី ខ្ញុំនឹងចាក់ខ្សែអាត់សំឡេង ជូនលោកស្ដាប់នាពេលក្រោយ។ នៅពេលនេះខ្ញុំសូមបន្តទៅមុខទៀត។ នៅក្នុងការសម្ភាសដដែល លោកបានលើកឡើងដូចតទៅ ឯកសារ E3/9149, អង់គ្លេសគឺ 011116147, ខ្មែរគឺ 00731243 ដល់ 44, បារាំងគឺ 01101030។ លោកបានលើកឡើងថា -- គេសួរលោកថា "ក្រោយពីលោកនៅតាំងគោក៧ខែ តើលោកទៅណាទៀត? លោកឆ្លើយថា ខ្ញុំទៅបារាយណ៍។" តើត្រឹមត្រូវដែរឬទេ អ្វីដែលលោកលើកឡើងនាពេលនោះ?

**ឆ៖** បាទ គឺត្រឹមត្រូវហើយ។

**ស៖** តើលោកទៅជំនួសនរណាដែរនៅបារាយណ៍?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01351198



[០៩:៣៨:៤៤]

ឆ៖ ខ្ញុំទៅហ្នឹងគឺមិន ខ្ញុំក្តាប់មិនបានថាជំនួសលោកណាទេ ប៉ុន្តែដែលខ្ញុំត្រូវទៅហ្នឹង គឺខ្ញុំទៅមែនហើយ--។

ស៖ នៅក្នុងកិច្ចសម្ភាសន៍ឆ្នាំ២០១៣ ឯកសារ E3/9570 លោកបានលើកឡើងថា លោកបានអានរួចហើយ កំណត់ហេតុស្តាប់ចម្លើយនោះនៅក្នុងចម្លើយទី៣ លោកបានឆ្លើយដូចតទៅ៖ “<ប្រាក់> គឺ<ជា>លេខាតំបន់<២៥>នៅ<ពេល>នោះ បាន<សម្រេច>បញ្ជូនខ្ញុំទៅជំនួស មូល <អតីតលេខាស្រុក>បារាយណ៍។” តើលោកទៅបារាយណ៍ដើម្បីទៅជំនួស មូល ដែរឬទេ?

ឆ៖ បាទ។

ស៖ អរគុណ។ មូល គឺជាប្រធានស្រុកមុនលោកនៅបារាយណ៍ តើត្រឹមត្រូវដែរឬទេ?

ឆ៖ បាទ ត្រឹមត្រូវ។

ស៖ ដូច្នេះតើលោកនៅកាន់ជាប្រធាននៅស្រុកបារាយណ៍ហ្នឹងរយៈពេលប៉ុន្មានដែរ?

ឆ៖ ខ្ញុំនៅស្រុកបារាយណ៍ហ្នឹងក្នុងរយៈពេលប្រហែលជាបួនប្រាំខែ ប្រាំទៅបួនខែ។

ស៖ លោកសាក្សី តើលោកធ្លាប់នៅតាំងគោកទេ? ហើយរយៈពេលប៉ុន្មានដែរ?

ឆ៖ នៅតាំងគោកហ្នឹងក៏មិនវែងប៉ុន្មានទេ ប៉ុន្មានពីរបីខែ ពីរបីខែមួយស្រុក។

ស៖ តើរយៈពេលប៉ុន្មានទៅដែលលោកទៅនៅ<ទីនោះ>នោះ?

[០៩:៤១:០៦]

ឆ៖ ខ្ញុំមិនចាំអស់ទេបាទ វាយូរដែរហើយ។

ស៖ អ៊ីចឹងខ្ញុំសាកល្បង តើដើម្បីអាចឲ្យលោកនឹកឃើញដែរឬទេ? ក៏ប៉ុន្តែមុនដំបូងខ្ញុំសួរថាតើលោកកាន់តួនាទីអ្វីដែរនៅតាំងគោក? តើលោកជាលេខាស្រុក ឬក៏យ៉ាងម៉េច?

ឆ៖ ពេលខ្ញុំមកដំបូងហ្នឹង គឺជាអនុលេខា អនុប្រធានស្រុកហ្នឹង ឯគេនៅហ្នឹងគេជាប្រធាន។

ស៖ តើនរណាជាប្រធាននៅពេលនោះ?

ឆ៖ ពេលហ្នឹងគឺឈ្មោះស្អីទេ ខ្ញុំចាំដូចឈ្មោះ ឆត។

ស៖ ឆន? តើមានអ្វីកើតឡើងលើ ឆន?

ឆ៖ លើ ឆន ហ្នឹង ខ្ញុំមិនដឹងដែរ បាទគឺខាងតំបន់គេ។

ស៖ តើឈ្មោះ នុត ឆន ហៅ ស្ន ដែលលោកហៅថា ឆន១ ហ្នឹងមែនដែរឬទេ?

**ឆ៖** ខ្ញុំចាំតែថាឮថា ឆនៗ អ៊ីចឹងហ្មង មិនបានដឹងឈ្មោះអីច្រើន។

**ស៖** តើលោកស្គាល់ ឆ្កោក ជាវ ដែរឬទេ? ខ្ញុំសូមឲ្យសហសេវិកជាតិ អានឈ្មោះជាខ្មែរឲ្យបានច្បាស់។

**លោក សេង លាង៖**

ឆ្កោក ជាវ។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** តើលោក ជាវ ហ្នឹងគាត់នៅទីនោះទេ នៅពេលដែលលោកទៅដល់?

[០៩:៤៣:២៧]

**2-TCW-850៖**

**ឆ៖** អត់ទេ អត់ដឹងដែរ ខ្ញុំអត់ស្គាល់ផង។

**ស៖** លោកសាក្សី នៅក្នុងការសម្ភាសផ្ដល់ចម្លើយរបស់លោកទៅមជ្ឈមណ្ឌលឯកសារកម្ពុជា លោកបានលើកឡើងថា ត្រង់ទំព័រ 01116146 ជាភាសាអង់គ្លេស, ហើយខ្មែរត្រង់ទំព័រ 00731243, បារាំងគឺ 01101029។ គេសួរលោកថា៖ “ហេតុអ្វីលោកទៅភូមិភាគកណ្ដាល? លោកឆ្លើយថា៖ ទៅធ្វើនៅស្រុក ហើយទទួលខុសត្រូវខាងស្រុក។ ហើយ ដានី សួរថា៖ តើស្រុកណាដែលលោកទៅកាន់ហ្នឹង? ហើយលោកឆ្លើយថា៖ ស្រុកតាំងគោក។ ក្រោយមកសួរទៀត សួរលោកទៀតថា៖ តើលោកទៅធ្វើជាប្រធានស្រុកតាំងគោកហ្នឹងដែរឬទេ? ហើយលោកឆ្លើយថា៖ បាទ ខ្ញុំទៅកាន់ប្រធាន។ ខ្ញុំទៅទីនោះដើម្បីធ្វើជាប្រធានថ្មី។” តើលោកនឹកឃើញទេ ថាលោកបានឡើងកាន់ជាលេខាស្រុកនៅតាំងគោកហ្នឹង?

**ឆ៖** បាទ ពេលហ្នឹង គឺខ្ញុំមកហ្នឹង គឺអត់ទាន់មានខាងភាគ ខាងតំបន់ណាដែលតែងតាំង ឬក៏មកចាត់តាំងឲ្យខ្ញុំជាលេខាហ្នឹង គឺអត់ទេ បាទគឺ--។

**ស៖** អ៊ីចឹងនៅពេលណាដែរ ដែលលោកក្លាយជាលេខាស្រុកតាំងគោក ក្រោយពេលលោកទៅដល់ទីនោះ រយៈពេលប៉ុន្មានខែដែរ?

**ឆ៖** ដូចខ្ញុំបាទជម្រាបហើយ ជាប្អូនទៅប្រាំខែប៉ុណ្ណឹង។

[០៩:៤៥:៤២]

**ស៖** អ៊ីចឹងទៅណាទៀត ក្រោយពីលោកចេញពីតាំងគោកទៅ?

**ឆ៖** ដូចខ្ញុំជម្រាបអ៊ីចឹង បាទ បារាយណ៍។

**ស៖** ដូច្នេះអ្វី បើសិនជាអ្វីលោកឆ្លើយប្រាប់ ឌី.ស៊ី.ខេម មជ្ឈមណ្ឌលឯកសារកម្ពុជាថាត្រឹមត្រូវនោះ គឺលោកទៅក្នុងខែកក្កដា ឆ្នាំ៧៦ ហើយនៅទីនោះរយៈពេលបួនប្រាំខែតែប៉ុណ្ណោះ។ ហើយលោកក្រោយមក ទៅបារាយណ៍នៅចុងឆ្នាំ៧៦ ដើមឆ្នាំ៧៧ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ មិនមែនអ៊ីចឹងទេ។ ខ្ញុំ៧៨ហើយ ចុង៧៨។

**ស៖** នៅបារាយណ៍ តើលោកមានតួនាទីអ្វីដែរ?

**ឆ៖** ពេលនោះដូចខ្ញុំបានជម្រាបអ៊ីចឹង ខ្ញុំទៅដល់ ដូចថា គេយក មូល, មូល គេចេញទៅ គេឲ្យខ្ញុំទៅនៅៗស្រុកបារាយណ៍ហ្នឹង។

**ស៖** អរគុណច្រើនលោកសាក្សី។ នៅពេលនេះខ្ញុំមានសំណួរមួយចង់សួរលោក នូវអ្វីដែលលោកឆ្លើយក្នុងកំណត់ហេតុមជ្ឈមណ្ឌលឯកសារកម្ពុជា ឯកសារ E3/9149 ខ្មែរត្រង់ទំព័រ 00731244, បារាំង 01101030, អង់គ្លេសត្រង់ទំព័រ <01116147>។ លោកបានលើកឡើងអំពីសម័យនៅក្នុងកម្ពុជាប្រជាធិបតេយ្យ លោកបានឆ្លើយថា៖ “ប្រសិនបើយើងនិយាយអ្វីដោយគ្មានគិតពិចារណា ហើយយើងត្រៀមខ្លួនស្លាប់ទៅ។” តើលោកមានន័យយ៉ាងម៉េច នៅពេលដែលលោកនិយាយដូច្នេះ?

**ឆ៖** បាទ ដែលខ្ញុំនិយាយដូច្នេះហ្នឹង គឺវាក្នុងសភាពការណ៍ដែលវាៗចង្អៀត ភ័យព្រួយតែពីរឿងសន្តិសុខផ្ទាល់ខ្លួនដែរ។

[០៩:៤៨:៣២]

**ស៖** សូមអរគុណ។ ក្រោយមកលោកឆ្លើយតទៀតថា ត្រង់ទំព័រដដែល។ បន្ទាប់មក៖ “សមាសភាព១៧មេសា ឬក៏ទាហាន<លន់ នល់> ត្រូវបានគេដកចេញ។ <ពួកគេត្រូវបានគេចាត់ទុកថាជាសមាសភាព។>” លោកបានលើកឡើងថា <“អ្នកដែលគេចាត់ទុកថាជា>សមាសភាព<ត្រូវបានគេដកចេញ>”។ តើលោកមានន័យយ៉ាងម៉េចដែរ?

**ឆ៖** នេះនៅខាងខ្ញុំផ្ទាល់ដែលខ្ញុំធ្វើការហ្នឹង គឺខ្ញុំមិនដែលមានគំនិត ឬក៏មានការជ្រើសរើសដែលដូចលោកប្រធានបានបញ្ជាក់ហើយ។

**ស៖** លោកលើកឡើងថា មិនមែនលោកធ្វើទេ ក៏ប៉ុន្តែលោកនិយាយថា “អ្នក១៧មេសា និងអតីតទាហាន លន់ នល់ ត្រូវបានគេដកចេញ ហើយអ្នកដែលគេចាត់ទុកថា មានសមាសភាពនោះ ត្រូវបានគេដកចេញ។” តើលោកដឹងថា កើតឡើងអ៊ីចឹងទេ នៅពេលនោះ? ខ្ញុំមិនមែនថា លោកអ្នកធ្វើទេ។

**ឆ៖** បាទ។

**ស៖** តើលោកឃើញករណីហ្នឹងកើតឡើងនៅទីណាដែរ?

**ឆ៖** ខ្ញុំមិនដែលឃើញទេ។

**ស៖** តើលោកមានដែលធ្លាប់បញ្ជា -- ទទួលបញ្ជាឲ្យចាប់មនុស្សដែរឬទេ?

**ឆ៖** បាទ អត់ទេ ខ្ញុំអត់ដែល។

[០៩:៥០:៤១]

**ស៖** ខ្ញុំសូមរំឭកលោកសាក្សី នូវអ្វីដែលលោកបានឆ្លើយប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា។ លោកបានលើកឡើងថា៖ "មានបញ្ជាមកពីខាងលើឲ្យចាប់អ្នកដែលប្រឆាំងនឹងយើង ក៏ប៉ុន្តែគ្មាននរណាគេប្រឆាំងនឹងយើងនោះទេ គេបាន<>ដាក់បញ្ជីឈ្មោះមនុស្សដែល<>ត្រូវដកចេញ។ ហើយខ្ញុំបានលើកឡើងនៅពេលនោះថា <នៅស្រុកខ្ញុំ> គ្មានអ្នកប្រឆាំងនោះទេ។ ហើយខ្ញុំប្រាប់ថ្នាក់លើថា ប្រសិនមិនជឿខ្ញុំទេ សួរថ្នាក់ក្រោមៗខ្ញុំទៅ។ ក្រោយមកគេក៏ចាប់អនុប្រធានរបស់ខ្ញុំចេញទៅ។"--

**អ្នកបកប្រែ៖**

អ្នកបកប្រែអត់ទទួលបានសំឡេងពីសហព្រះរាជអាជ្ញានោះទេ។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** តាមអ្វីដែលខ្ញុំអានអម្បាញ់មិញ លោកសាក្សីលោកឆ្លើយថា លោកបានទទួលបញ្ជា--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាននេះមិនមែនជាការជំទាស់ទេ ក៏ប៉ុន្តែដើម្បីឲ្យយើងអាចតាមទាន់ហ្នឹង សូមឲ្យលេខយោងផងលោកប្រធានដើម្បីឲ្យយើងអាចតាមទាន់។

**ប្រធានអង្គជំនុំ៖**

សូមលោកព្រះរាជអាជ្ញាប្រាប់លេខយោងផង ដើម្បីឲ្យភាគីបានតាមទាន់។

[០៩:៥២:២០]

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** ឯកសារ E3/9149 ខ្មែរគឺ <00731253>, បារាំងគឺ 01101039, អង់គ្លេស <01116153>។ លោកសាក្សី លោកបានឆ្លើយប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាថា លោកបានទទួល

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បញ្ជាពីថ្នាក់លើ<ឱ្យចាប់អ្នកប្រឆាំង> ហើយមានបញ្ជីពីថ្នាក់លើបញ្ជាក់ឈ្មោះដែលត្រូវដកចេញ ហើយលោកបានឆ្លើយតបទៅថ្នាក់លើវិញថា គ្មានអ្នកប្រឆាំងយើងទេនៅពេលនោះ។ តើនេះជាអ្វីដែលកើតឡើងនាពេលនោះដែរឬទេ?

**2-TCW-850៖**

**ឆ៖** ខ្ញុំបានតបទៅវិញមែន ខ្ញុំថា នៅកន្លែងខ្ញុំគឺគ្មាន។

**ស៖** លោកបាននិយាយស្រដៀងគ្នានេះប្រាប់ ថេត សម្បត្តិ។ តើលោកនៅចាំទេថា លោកធ្លាប់បានសម្ភាសដោយបុរសម្នាក់ឈ្មោះ ថេត សម្បត្តិ ដែលគាត់ជាអ្នកផលិតខ្សែភាពយន្ត?

*(សម្រាករយៈពេលខ្លី)*

**ប្រធានអង្គជំនុំ៖**

សាក្សីស្តាប់សំណួរបានទេ? សូមលោកឆ្លើយ!

**2-TCW-850៖**

**ឆ៖** បាទ ខ្ញុំមិនដែលបានសម្ភាសជាមួយ សម្បត្តិ ណាទេ។

**ស៖** តើលោកនៅចាំថា លោកធ្លាប់បានសម្ភាសដោយអ្នកមួយចំនួនដែលគាត់ជាអ្នកផលិតខ្សែភាពយន្តដែរឬទេ? តើលោកនឹកឃើញទេ?

**ឆ៖** បាទ ខ្ញុំនឹកអត់ឃើញទេ។

[០៩:៥៥:០៩]

**ស៖** ដូច្នេះខ្ញុំសូមអានជូនលោកស្តាប់នូវអ្វីដែលគេកត់ត្រាទុកនាពេលនោះ ក៏ប៉ុន្តែខ្ញុំដាក់ជំនួសឈ្មោះ ខ្ញុំមិនដាក់ឈ្មោះលោកបញ្ចូលក្នុងនោះទេ ដោយសារតែលោកការពារអត្តសញ្ញាណ។ គឺឯកសារ E3/4202 សៀវភៅស្តីអំពី “ខ្មាំងប្រជាជន” <ERN ជាភាសាអង់គ្លេសគឺ> <00757529> ទៅដល់ 30, បារាំងគឺ 00849432, ខ្មែរគឺ 00858335។ នៅក្នុងនោះបានសរសេរថា “ឈ្មោះលោក គេដាក់ឈ្មោះលោកនៅក្នុងហ្នឹង លោកគឺជាប្រធានស្រុកតាំងគោក ក្នុងខេត្តកំពង់ធំ នៅដើមសម័យខ្មែរក្រហម។ ក្នុងពេល ប៉ុល ពត ទៅទស្សនកិច្ច បងធំទី១ ឃើញប្រជាជន<រាប់សិបនាក់>ត្រូវបានដឹកទៅកំពង់ចាមដើម្បីយកទៅសម្លាប់ចោល។ ប៉ុល ពត បានសួរថា យកមនុស្សទាំងអស់ហ្នឹងទៅណា? ហើយនរណាជាអ្នកចេញបញ្ជាឱ្យយកមនុស្សទាំងអស់នោះចេញទៅ? ហើយបន្ទាប់មកមានឈ្មោះលោក <ដោយគេ>សរសេរថា <>“លោកភ្ញាក់ផ្អើលណាស់ដែល ប៉ុល ពត មិនបានដឹង។ គាត់សន្មតថា បងធំទី១ ជា

អ្នកចេញសេចក្ដីណែនាំ។ នៅក្នុងឆ្នាំ១៩៧៧ កែ ពក បានហៅលោកទៅឲ្យចូលរួមក្នុងអង្គប្រជុំមួយ ហើយបាននិយាយថា គាត់បានទទួលសេចក្ដីណែនាំពីថាដឹកនាំជាន់ខ្ពស់ ដើម្បីតាមដានកម្មាភិបាលក្នុងគោលបំណងវែកញែកមុខសមាសភាពក្បត់។ <ប្រធាន>តំបន់ម្នាក់បាន<ប្រគល់>បញ្ជីឈ្មោះមនុស្សជាង៣០០នាក់<មកឲ្យឈ្មោះរបស់លោក> ដែលត្រូវបញ្ជូនពីភ្នំពេញទៅតំបន់របស់គាត់។ លោកបានចំណាយពេល៣ខែ តាមដានអ្នកទាំងនោះ ហើយរាយការណ៍ទៅប្រធានភូមិភាគថា<ពួកគេមិនបានធ្វើ>អ្វីខុសឆ្គងទេ។ ប្រធានតំបន់រូបនោះ<>បានស្ដីបន្ទោសលោក ដោយសារតែលោក<>មិនបានរកឃើញ<អ្នកប្រព្រឹត្ត>កំហុស ហើយចោទលោកថា លោកជាអ្នកលាក់បាំងជនក្បត់។ តើក្រោយពេលខ្ញុំអានទៅលោកនឹកឃើញទេ?

[០៩:៥៧:៥៥]

**ឆ៖** ដូចនឹកមិនឃើញទេ។

**ស៖** ខ្ញុំសូមសួរលោក តើគេធ្លាប់ប្រគល់បញ្ជីមនុស្ស៣០០នាក់ឲ្យយកទៅសម្លាប់ចោលដែរឬទេ? តើលោកនឹកឃើញទេ ឬក៏យ៉ាងម៉េចដែរ?

**ឆ៖** បាទ នឹកអត់ឃើញទេ។ ហើយក៏មិនដែលបានទទួលបញ្ជីដែរ។

**ស៖** លោកសាក្សី តើលោកធ្លាប់ឃើញផ្ទាល់ភ្នែកនូវការចាប់ខ្លួន <ឬការសម្លាប់មនុស្សទេ? តើលោកបានដឹងថាមាន>បាត់ខ្លួនមនុស្ស<នៅក្នុងស្រុកដែលលោកធ្វើការ>នៅ<>ភូមិភាគកណ្ដាលនោះដែរឬទេ?

**ឆ៖** បាទ អត់ដែលឃើញទេ។

**ស៖** ខ្ញុំត្រឡប់ទៅអ្វីដែលខ្ញុំបានអានជូនលោកអម្បាញ់មិញដដែល គឺឯកសារកិច្ចសម្ភាសន៍ដែលលោកឆ្លើយប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា យើងចំណាយពេលច្រើនដែរ ត្រូវការចាក់ខ្សែអាត់ឲ្យលោកស្ដាប់។ នៅត្រង់ទំព័រដដែល ដែលខ្ញុំបានដកស្រង់ចេញពីឯកសារ E3/9149 លោកបានឆ្លើយថា ប្រសិនបើមិនជឿលោកទេ លោកឲ្យទៅសួរថ្នាក់ក្រោមៗលោក និងអនុរបស់លោក។ ហើយក្រោយមកគឺអនុរបស់លោកត្រូវបានដកចេញ ដែលឈ្មោះហ្នឹងគឺគាត់ឈ្មោះ ឆន, ឆន អនុរបស់លោកហ្នឹងត្រូវបានដកចេញ។ ឆន ត្រូវបានដកចេញ ហើយ ចេន ហ្នឹងក៏ដកចេញដែរ។ តើលោកនៅចាំថាអនុប្រធានរបស់លោកត្រូវបានគេដកចេញដែរឬទេ?

[១០:០០:១៧]

**ធ៖** ខ្ញុំថារឿង ឆន ឈ្មោះ ឆន មួយ។

**ស៖** តើលោកនៅចាំអ្វីដែលកើតឡើងចំពោះគាត់ខ្លះ?

**ធ៖** ខ្ញុំអត់ចាំទេ។

**ស៖** តើគាត់បាត់ខ្លួនមែនដែរឬទេ?

**ធ៖** បាទ ឆន ហ្នឹងខាងតំបន់គេហៅទៅ។ គេហៅ ថាហៅទៅរៀន ហើយមិនដឹងជាយ៉ាងម៉េច ស្រាប់បាត់ឈឹងទៅ។

**ស៖** នៅពេលគេហៅអ្នកណាម្នាក់ទៅរៀនសូត្រ ហើយបាត់ខ្លួន តើលោកគិតថាមានអ្វីកើតឡើងចំពោះពួកគាត់ដែររទេ?

**ធ៖** បាទ តែបាត់ហើយ វាមុខតែមានបញ្ហាកើតឡើងហើយចំពោះគ្នា។

**ស៖** ខ្ញុំយល់។ ខ្ញុំអាននូវអ្វីដែលលោកបានឆ្លើយប្រាប់ ថេត សម្បត្តិ គឺឯកសារ E3/4202 "នៅពីក្រោយវាលពិឃាដ"។ <នៅទំព័របន្ទាប់ ជាភាសា>អង់គ្លេស <និងភាសាបារាំង>គឺ 00849432, ខ្មែរគឺ 00858336 លោកបានលើកឡើងថា៖ "<>មនុស្សរាប់ពាន់នាក់ក្នុងស្រុករបស់លោកត្រូវបានសម្លាប់ចោល ដោយចោទថាជាគិញ។" តើមានការសម្លាប់មនុស្សរាប់ពាន់នាក់នៅក្នុងស្រុករបស់លោក ដោយគេចោទថាពួកគាត់ជាគិញដែរឬទេ លោកសាក្សី?

**ធ៖** អត់ទេ។

[១០:០២:៣៥]

**ស៖** លោកសាក្សី ខ្ញុំសូមរំឭកលោកម្តងទៀត គឺថាលោកបានស្បថរួចហើយថាឆ្លើយការពិត លោកនឹងមិនត្រូវបានផ្តន្ទាទោសចំពោះ<អ្វីដែលលោកនិយាយទេ អត់មានបទ>ឧក្រិដ្ឋកម្មណាមួយទេ ហើយ<មិនមាន>សំណុំរឿង<បន្ថែមទៀតកើតឡើងនៅទីនេះដែរ ហើយគេបានប្រគល់លិខិតមួយបញ្ជាក់ជូនលោកថា នឹងមិនប្រើប្រាស់ចម្លើយរបស់លោកដើម្បីចោទប្រកាន់នឹងលោកទេ។ ទោះយ៉ាង>ណា<>តុលាការតម្រូវឲ្យលោកជម្រាបនូវការពិតតែប៉ុណ្ណឹង ហើយបើថាលោក<មិន>ជម្រាបនូវការពិតនោះទើបគឺថាអាចនឹងប្រឈមទៅតាមផ្លូវច្បាប់។សូម<អានអ្វីដែលលោកបានឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា គឺ>ឯកសារ E3/9149 ខ្មែរ <00731247>, <បារាំង 01101033> អង់គ្លេស <01116149>។ "ថ្នាក់លើបញ្ជាយើងឲ្យចាត់វិធានការ រួមទាំងការដាក់ទណ្ឌកម្មផង និងការសម្លាប់ផងដែរ។" តើលោកចង់និយាយថាដូចម្តេចដែរ នៅពេលដែលលោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារ

កម្ពុជាថា ថ្នាក់លើបញ្ជាឲ្យលោកចាត់វិធានការ រួមទាំងការសម្លាប់នោះផងដែរ?

**ប្រធានអង្គជំនុំ៖**

លោកសាក្សីស្តាប់សំណួរបានទេ? សូមលោកឆ្លើយ!

**2-TCW-850៖**

បាទ ខ្ញុំស្តាប់អត់បានទេ។

**ប្រធានអង្គជំនុំ៖**

លោកព្រះរាជអាជ្ញា សូមតាំងសំណួរជាថ្មីម្តងទៀត ព្រោះសាក្សីស្តាប់សំណួរនេះមិនបានទេ។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** ខ្ញុំសូមអានឲ្យលោកស្តាប់ម្តងទៀត នូវអ្វីដែលលោកបានឆ្លើយជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា។ លោកបានឆ្លើយដូចតទៅ សូមដកស្រង់៖ “ថ្នាក់លើបានបញ្ជាឲ្យយើងចាត់ការ រួមទាំងការដាក់ទណ្ឌកម្ម ឬក៏ការសម្លាប់ចោលតែម្តង។” បញ្ចប់ការដកស្រង់។ បើសិនណាជាវាមិនពិតទេ អ៊ីចឹងអានេះគឺជាអ្វីដែលលោកឆ្លើយបំផ្លើស ឬក៏ប្រឌិតឆ្លើយទៅប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាថា អ៊ីចឹងមែនទេ?

[១០:០៥:២៥]

**2-TCW-850៖**

**ឆ៖** ខ្ញុំដូចរកនឹកមិនឃើញ មិនដែលខ្ញុំបានឆ្លើយ ដូចដែលលោកអានទេ។

**ស៖** នេះគឺជាកិច្ចសម្ភាសន៍ ហើយមានទាំងថតជាខ្សែអាត់សំឡេងផង។ តើលោក<នៅ>នឹកឃើញឬទេថា ថ្នាក់លើបានបញ្ជាឲ្យលោកចាត់ការ រួមទាំងសម្លាប់មនុស្សចោលផង? តើលោកមានបានអនុវត្តតាមបញ្ជានេះ ចាត់ការតាមបញ្ជានេះដែរឬទេ?

**ឆ៖** អត់ទេ ខ្ញុំមិនដែលអនុវត្តទេ។ សារហ្នឹង ក៏ខ្ញុំអត់ដែលបានទទួលដែរ។

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន តើពេលវេលានេះ ដល់ពេលឈប់សម្រាកហើយឬនៅ ឬក៏យ៉ាងណាដែរ?

**ប្រធានអង្គជំនុំ៖**

អរគុណលោកព្រះរាជអាជ្ញា។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទី ចាប់ពីពេលនេះ។

អញ្ជើញសម្រាក!

01351206



*(សវនាការសម្រាកពីម៉ោង ១០:០៦ នាទី ដល់ម៉ោង ១០:២៧ នាទី)*

[១០:២៧:៥៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

សូមអញ្ជើញលោកព្រះរាជអាជ្ញាបន្តសំណួរ!

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី ដោយសារតែលោកបានចម្លើយមួយចំនួន ខ្ញុំនៅពេលនេះ សូមចាក់នូវខ្សែអាត់សំឡេងដែលគេថតទុក នៅពេលដែលលោកឆ្លើយទៅនឹងកិច្ចសម្ភាសន៍ក្នុងឆ្នាំ២០០៨ ហើយសូមឱ្យលោកស្ដាប់ដោយផ្ចិតផ្ចង់ ផ្ចង់អារម្មណ៍ឱ្យបានល្អ ហើយខ្ញុំសូមចាក់ឃ្លីបខ្សែអាត់សំឡេងទី៥។

**ប្រធានអង្គជំនុំ៖**

មន្ត្រីសោតទស្សន៍ចាក់ឃ្លីបសំឡេងនេះ។

**2-TCW-850៖**

**ឆ៖** ២០០៨?

[១០:២៨:០៤]

*(ការបង្ហាញឯកសារជាសំឡេង)*

*"...ខ្ញុំគាប់ជួន ពេលដែលគេជ្រើសរើសសមាសភាព១៧មេសា ឬក៏ជ្រើសរើសទាហាន អ្នក – ជំនាន់នោះ គេហៅថា អ្នកសមាសភាព។ ខ្ញុំ ខ្ញុំនិយាយចំពោះក្អួយ គឺខ្ញុំមិនដែល មិនដែលទៅវាយការណ៍ ឬក៏មិនដែលទៅចុចឈ្មោះថា អ្នកនេះធ្វើនេះ អ្នកនោះធ្វើនោះ គឺខ្ញុំ ខ្ញុំជំហរខ្ញុំ ខ្ញុំប្រកាន់អ៊ីចឹង ព្រោះដូចក្អួយយល់ស្រាប់ ខ្ញុំទៅពីចម្ងាយ...។"*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង)*

[១០:២៨:៤៥]

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី តើលោកស្ដាប់ឮសំឡេងចាក់អម្បាញ់មិញដែរឬទេ? ហើយលោកស្គាល់សំឡេងលោកដែរឬទេ?

**2-TCW-850៖**

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទ ខ្ញុំស្គាល់។

**ស៖** តើលោកមានន័យយ៉ាងម៉េច នៅពេលដែលលោកនិយាយថា ទាហានត្រូវបានគេចុចឈ្មោះនោះ?

**ឆ៖** ខ្ញុំដូចជារកនឹកមិនឃើញ ប៉ុន្តែ ព្រោះឯកសារដែលខ្ញុំបានទទួលហ្នឹង គឺឯកសារបី ដែលខ្ញុំបានអាន ហើយខ្ញុំបានពិនិត្យសាចុះសាឡើង។

**ស៖** សូមអធ្យាស្រ័យ លោកមិនបានទទួលនូវកំណត់កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា សូមអធ្យាស្រ័យ ក៏ប៉ុន្តែយ៉ាងណាក៏ដោយ ខ្ញុំសូមចាក់នូវខ្សែអាត់សំឡេងលេខរៀងទី៤ ជូនលោកស្ដាប់។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកសហព្រះរាជអាជ្ញា ដើម្បីជាកំណត់ត្រាប្រតិចារឹក សូមលោកផ្ដល់លេខយោងនៃខ្សែអាត់សំឡេងហ្នឹងផង។ យើងមានលេខឯកសារសម្ភាសនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ក៏ប៉ុន្តែលោកអត់មានបានផ្ដល់លេខយោងនៃខ្សែអាត់ហ្នឹងទេ។

[១០:៣១:៥៧]

**លោក នីកូឡាស គូមជែន៖**

ទំព័រ គឺទំព័រដែលខ្សែអាត់នេះ និយាយអម្បាញ់មិញហ្នឹង គឺត្រង់ទំព័រ--

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកបានចាក់ខ្សែអាត់សំឡេង អ៊ីចឹងខ្ញុំចង់ដឹងថា តើខ្សែអាត់ហ្នឹងមានលេខយោងនៅក្នុងសំណុំរឿងយើងទេ? ហើយបើមានលេខយោងហ្នឹង សូមលោកប្រាប់ផង។ ជាពិសេសប្រាប់ម៉ោងផង ម៉ោង នាទីអីហ្នឹងនៅក្នុងវីដេអូ ដែលលោកបានចាក់ផ្សាយអម្បាញ់មិញហ្នឹង នៅម៉ោងណា នាទីណា វិនាទីណា?

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកចៅក្រម។ ខ្ញុំនឹងស្នើសុំឲ្យការិយាល័យរបស់ខ្ញុំហ្នឹងរកមើលខ្សែអាត់នេះ ភ្ជាប់ជាមួយឯកសារ E3/9149។ ហើយចំពោះ*ឃ្លីប*<ចុងក្រោយ>ដែលខ្ញុំចាក់<> គឺក្នុងចន្លោះ<នាទីទី>១៨<> ហើយ<បន្ទាប់មកទៀត>គឺចន្លោះ<នាទីទី>៤៩<>។

ខ្ញុំអាចផ្តល់ជូនជាក់លាក់ជាងនេះ។ ខ្សែអាត់ទី១ ដែលខ្ញុំចាក់អម្បាញ់មិញ លេខ៥នោះ គឺ១៨:៣៥ ដល់<១៨:៥៨> ហើយខ្សែអាត់ទី៤ ដែលខ្ញុំចង់ចាក់នេះ គឺក្នុងចន្លោះម៉ោង៤៩:00 ដល់<៥១:៤១>។ អ៊ីចឹងហើយ សូមខាងទូចាក់ខ្សែអាត់នេះត្រៀមខ្លួន ហើយសូមចាក់ខ្សែអាត់ទី៤ អម្បាញ់មិញ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីសោតទស្សន៍ចាក់ផ្សាយខ្សែអាត់នេះ!

[១០:៣៤:១៧]

*(ការបង្ហាញឯកសារជាសំឡេង)*

*"...សួរ៖ ចុះព្រឹត្តិការណ៍អ៊ីជា ធ្វើជាលេខាស្រុកអ៊ីចឹង ដូចខាងតំបន់អី គេមានបញ្ហាអីមកអ៊ុំ ដូចថាឲ្យត្រូវធ្វើនេះ ដូចថាយកអ្នកនេះ យកអ្នកនោះអីទៅ ហើយអ៊ុំប្រឆាំងនឹងខាងគេ ដូចថា តវ៉ាជាមួយគេវិញដែរអត់? ឆ្លើយ៖ មានដែរ ខ្ញុំមានតវ៉ា។ សួរ៖ គេខាងនិយាយថាម៉េចខ្លះដែរ? ឆ្លើយ៖ គេមកដល់គេហើយគេជាកម្មាភិបាលយើង ចាស់ៗជំនាន់នោះណា៎ ដែលកាន់ស្រុកមកទាល់សព្វថ្ងៃ។ មកដល់ថ្ងៃមួយ មកសម្លុតខ្ញុំ ប៉ុន្តែថានិយាយទៅវា សម្លុតថា ឥឡូវមិត្តឯងនៅក្នុងស្រុកមិត្តឯងហ្នឹងដូចជាមិនឃើញមានដកហូតអ្នកកម្មាភិបាលចាស់ៗ ដែលមិនល្អ ឬក៏ដកតែកម្មាភិបាលចាស់ៗ វាត្រូវតែដកទាំងអស់។ ហើយចុះមិត្តឯងម៉េចក៏មិនដក? ខ្ញុំថា ដកយ៉ាងម៉េច បើគ្នាខំឈ្លុសឈ្លុល ដឹកនាំប្រជាជន ហើយមិនដែលមានសកម្មភាពប្រឆាំង ឬក៏ផ្ទាំងផ្ទាក់ជាមួយនឹងយើងសោះ ហើយខ្ញុំរកនឹកដកមិនឃើញ។ ខ្ញុំថាអ៊ីចឹង បាទ។ បីបួនប្រាំឆ្នាំ បាទបីបួនប្រាំឆ្នាំ ខ្ញុំនឹកអាណិត នឹកស្តាយ ខ្ញុំមើល ខ្ញុំឃើញថា ដូចជាយើងដូចខ្ញុំបានជម្រាបខាងដើមអ៊ីចឹង គេប្រាប់ពីលើមក ថាចំពោះណាដែលវាប្រឆាំងពិតប្រាកដ? បើអត់មានសកម្មភាពអីផង រួចចេះតែឲ្យចុចឈ្មោះដក ចុចឈ្មោះដក ខ្ញុំថា អស់ហើយ ខ្ញុំនឹកក្នុងចិត្តខ្ញុំ អ្នកណាធ្វើកើត។ ខ្ញុំថាអត់មានទេ ស្រុកខ្ញុំមិនមានបញ្ហាអីទេ។ ហើយបើមិនជឿទេ សួរអស់លោកដែលថា សួរសមាជិកហ្នឹង ខ្ញុំថាអ៊ីចឹងណា៎។ ប៉ុន្តែខ្ញុំអត់ប៉ានទេ ក៏អត់មានបញ្ហាអីទៅ។ ដល់ក្រោយមក គេយកអនុលេខាខ្ញុំហ្នឹងបាត់...។"*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង)*

[១០:៣៧:២៤]

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី ក្រោយពីលោកបានស្តាប់ តើលោកអាចជម្រាបយើងខ្ញុំបានសាជាថ្មីដែរឬទេ

ថាតើលោកធ្លាប់បានទទួលបញ្ជាពីថ្នាក់លើឲ្យចាប់អ្នកដែលប្រឆាំង<លោក ប៉ុន្តែ>លោកឆ្លើយនៅពេលនោះ<>ថា អត់មានអ្នកប្រឆាំងនោះ<>ទេ។ តើលោកនឹកឃើញទេ?

**2-TCW-850៖**

**ឆ៖** បាទ សំឡេងខ្ញុំបាទអំមិញនេះ គឺជាសំឡេងរបស់ខ្ញុំ ដូចខ្ញុំបានជម្រាបនៅក្នុងខ្សែអាត់អំមិញអ៊ីចឹង។

**ស៖** លោកសាក្សី នៅពេលដែលលោកឆ្លើយថា លោកបានទទួលបញ្ជាឲ្យចាប់ខ្លួនអ្នកដែលប្រឆាំង ហើយលោកបានប្រាប់ទៅគេវិញថា អត់មានអ្នកប្រឆាំងទេ។ តើក្រោយមកមានអ្វីកើតឡើងទៀត?

**ឆ៖** ដូចខ្ញុំឆ្លើយក្នុងខ្សែអាត់អំមិញអ៊ីចឹង ក្រោយមកគេចេះតែជំរិត ចេះតែរករឿង ឲ្យខ្ញុំនៅតែប្រកាន់ជំហរមួយ ថាបើមិនមានបញ្ហាអីដែលប៉ះពាល់ផង ហើយទៅធ្វើអ៊ីចឹងខ្ញុំអត់ធ្វើទេ គឺខ្ញុំមិនធ្វើដាច់ខាតពេលនោះ។

[១០:៣៩:១៧]

**ស៖** លោកបានឲ្យគេទៅនិយាយជាមួយអនុរបស់លោកឈ្មោះ ឆន តាមលោកដឹង តើអ្នកទាំងអស់នោះ មានបានទៅជួបនិយាយជាមួយនឹង ឆន ដែរឬទេ?

**ឆ៖** ស្តាប់អត់ច្បាស់ សំណួរនេះ ខ្ញុំស្តាប់អត់ទាន់បាន។

**ស៖** នៅក្នុងកិច្ចសម្ភាសន៍លោកបានឆ្លើយថា ប្រសិនបើពួកគេ អត់ជឿលោកទេ <លោកថា> ឲ្យ<ពួកគេទៅ>និយាយជាមួយនឹង ឆន ហើយលោក មុននឹងនិយាយថា ឆន បានបាត់ខ្លួន។ តើលោក<ដឹងទេ ថាតើ>គេទៅនិយាយជាមួយ ឆន <ទេ> មុនពេល<គេហៅ ឆន ទៅតំបន់ ឬក៏ទៅរៀនសូត្រ>?

**ឆ៖** បាទ ឆន ហ្នឹងបាត់។

**ស៖** ហើយលោកបានឆ្លើយថា លោកអត់ចាំឈ្មោះ <ចេន> នោះឡើយ។ ខ្ញុំសូមចាក់នូវខ្សែអាត់សំឡេង<ទី៦>ត្រង់<នាទី> <៥១:៤១> ដល់ <៥២:២៣>។ សម្រាប់អ្នកបកប្រែ នៅទំព័រលេខ ១២ ជាភាសាអង់គ្លេស, ខ្មែរគឺ 00731254។

**ប្រធានអង្គជំនុំ៖**

មន្ត្រីសោតទស្សន៍ចាក់ផ្សាយខ្សែអាត់សំឡេងនេះ!

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១០:៤១:០៥]

*(ការបង្ហាញឯកសារជាសំឡេង)*

*"...រួចមកគេ យកអនុលេខាខ្ញុំនោះបាត់។ សួរ៖ ឈ្មោះ? ឆ្លើយ៖ ឆន។ សួរ៖ ឈ្មោះ ឆន?ឆ្លើយ៖ បាទ។ សួរ៖ អនុលេខានៅហ្នឹង? ឆ្លើយ៖ អាហ្នឹងស្រុកកំណើតគាត់នៅបារាយណ៍។ សួរ៖ ថាគាត់អនុលេខានៅស្រុក? ឆ្លើយ៖ ស្រុកតាំងគោក។ សួរ៖ តាំងគោក។ ឆ្លើយ៖ ដក ឆន ៗហើយដក ដេន មួយទៀត។ ខ្ញុំឡើង (ឮមិនច្បាស់)។ សួរ៖ ដឹងមួយទៀត ដកយកទៅណា? ឆ្លើយ៖ មិនដឹងគេយកទៅណា គេថាយកទៅតំបន់។ សួរ៖ អនុលេខា -- គណៈតំបន់ឈ្មោះអីគេ? ឆ្លើយ៖ គណៈតំបន់នៅ គាត់ស្រុកគាត់នៅបារាយណ៍ទុំងដែរ ឈ្មោះ អឿន ប៉ុន្តែគាត់ស្លាប់ហើយ។ សួរ៖ អ៎! អឿន ប្អូនថ្លៃ តាពក ហ្នឹង? ឆ្លើយ៖ បាទ។..."*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង)*

[១០:៤២:១១]

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី តើលោកនឹកឃើញទេ <ចេន> ហ្នឹងដែលជាបុគ្គលម្នាក់ត្រូវបានគេដកចេញដែរនោះ ក្រោយពេលលោកស្លាប់ហើយ?

**2-TCW-850៖**

**ឆ៖** បាទ មិនមែន ឈ្មោះៗ ដេន។

**ស៖** សូមអរគុណ។ <ដេន> តើលោកអាចបញ្ជាក់ឈ្មោះឡើងវិញទេ<>?

**ឆ៖** ដេន។

**ស៖** តើគាត់ជានរណាគេដែរ?

**ឆ៖** គាត់នៅជាសមាជិកនៅក្នុងស្រុកហ្នឹងដែរ។

**ស៖** បាទ ខ្ញុំស្តាប់អត់ឮទេ លោកសាក្សី។ តើអស់លោក លោកស្រីស្តាប់ឮទេ? ខ្ញុំសូមអានអ្វីដែលលោកឆ្លើយគឺឯកសារ E3/9149 ខ្មែរគឺ 00731244, បារាំងគឺ <0110101030>*(ស៊ីក)*, អង់គ្លេសគឺ 0116147*(ស៊ីក)*។ លោកបានលើកឡើងថា៖ "នៅក្នុងអំឡុងសម័យនោះ ខ្ញុំមិនដឹងថា ថ្ងៃណាដល់ថ្ងៃខ្ញុំនោះទេ។" តើលោកអាចបញ្ជាក់ជូនយើងខ្ញុំបានដែរទេ? តើលោកមានន័យយ៉ាងម៉េច នៅពេលដែលនិយាយដូច្នេះ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ខ្ញុំបារម្ភពីសន្តិសុខ ពីសន្តិសុខផ្ទាល់ខ្លួននៅក្នុងពេលនោះ។

[១០:៤៤:៤៣]

**ស៖** ហេតុអ្វីបានជាលោកខ្លាច? តើលោកបានមើលឃើញអ្វីដែលធ្វើឲ្យលោកព្រួយបារម្ភបែបនោះ?

**ឆ៖** បាទ មើលឃើញបញ្ហាដែលចេះតែមាន ដូចខ្ញុំបានបញ្ជាក់។ យូរៗបាត់មួយ ដល់អ៊ីចឹងបារម្ភពីខ្លួនផ្ទាល់ ខាងសន្តិសុខ បានជាខ្ញុំគិតថា មិនដឹងជាថ្ងៃណា។ ខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង។

**ស៖** លោកបានបញ្ជាក់ថា គេប្រាប់លោកថា មានអ្នកដែលប្រឆាំងនឹងរបបនោះ ហើយខ្ញុំបានអាន<>ឲ្យលោកស្តាប់ហើយថា មានឈ្មោះដែលគេឲ្យលោកមកថាជាអ្នកប្រឆាំង។ ហើយក្រោយមកលោកបានរកឃើញថា គ្មានអ្នកប្រឆាំងដែរនោះទេ។ <តើជាការពិតទេ> តើលោកមានបានមើលភស្តុតាង <និងការសម្រេចឬទេ ថាតើមាន ឬក៏មិនមាន>ហេតុផល<ឲ្យជឿបាន>ថា <មាន>អ្នក<ក្បត់>នៅស្រុកបារាយណ៍នោះ<>?

**ឆ៖** អត់មានទេ។

**ស៖** តាមលោកដឹង តើមានហេតុផលអ្វី បានជាគេចាប់ទាំងអស់នេះ ហើយក្រោយមកពួកគេបាត់ខ្លួន?

**ឆ៖** ដូចអត់ទាន់យល់ លោកប្រធាន។

**ស៖** ខ្ញុំសូមពន្យល់ជូនលោក មុនពេលដែលខ្ញុំសួរសំណួរមួយទៀត។ តើលោកមាននឹកឃើញហេតុការណ៍មួយដែលលោកនិយាយនៅក្នុងឆ្នាំ២០០៨ ដែលលោកបានឆ្លើយប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅពេលដែលលោកនិយាយអំពីពិធីបុណ្យសព?

លោកសាក្សី ខ្ញុំមិនដឹងថា លោកស្តាប់ឮខ្ញុំដែរឬទេ? លោកបានលើកឡើងប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា អំពីពិធីបុណ្យសពមួយដែលលោកបានធ្លាប់ឃើញនៅសម័យនោះ។ តើលោកនឹកឃើញថា លោកបាននិយាយអំពីពិធីបុណ្យសពនោះ ប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាដែរឬទេ?

**ឆ៖** បាទ ខ្ញុំបាទនិយាយមែន។

[១០:៤៧:៣៩]

**ស៖** តើមានអ្វីកើតឡើង នៅពេលដែលលោកដើរឆ្លងកាត់ ហើយបានឃើញនុំង ពិធីបុណ្យសពនុំង?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ប្រជាជន គាត់ធ្វើបុណ្យសពនៅក្នុងផ្ទះ នៅក្នុងផ្ទះ។ រួចដល់ខ្ញុំជិះម៉ូតូទៅដល់ គាត់ភ័យដល់ភ័យអ៊ីចឹង ខ្ញុំហៅមកប្រាប់ថា ធ្វើចុះបុណ្យ ធ្វើឲ្យបានស្ងៀមស្ងាត់ ធ្វើម៉េចកុំចំហ ខ្លាចគេដឹង គេឃើញអីទៅ រករឿងដល់គាត់ផង ដល់ខ្ញុំផង។

**ស៖** សូមអរគុណ។ នៅក្នុងចម្លើយដែលលោកបានឆ្លើយប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា ហៅថា ឌី.ស៊ី.ខេម ត្រង់ខ្មែរ ទំព័រខ្មែរ 00731246, បារាំងគឺ 01101032, អង់គ្លេស <01116148> ។ លោកបាននិយាយថា និយាយស្រដៀងគ្នាថា នៅពេលដែលលោកបានជិះម៉ូតូ<ទៅផ្ទះ> "ពេលដែលពួកគេឃើញ<ខ្ញុំ> ពួកគាត់<ខ្លាចឡើង>ញ័រ។ <>ខ្ញុំ<បានហៅពួកគេម្នាក់ឲ្យ>មកជួប<ខ្ញុំ ហើយ>ខ្ញុំ<ប្រាប់ពួកគេ>ថា <វាមិនអីទេ ក្នុងការ>ធ្វើបុណ្យ<នោះ។ តែទោះជាយ៉ាងណា ខ្ញុំបានសង្កត់ធ្ងន់ថា បើគេដឹងថាយើងដុត>ធូប <នោះ>យើង<ទាំងអស់អាចនឹងត្រូវគេសម្លាប់>។" តើលោកមានបាននិយាយប្រាប់អ្នកទាំងអស់នោះដែរឬទេថា ប្រសិនបើគេឃើញលោកឲ្យធ្វើបុណ្យអ៊ីចឹង <>នោះ <> លោក ហើយនិងអ្នកទាំងអស់នោះ នឹងស្លាប់ជាមិនខាន។ តើលោកបាននិយាយដូច្នេះដែរឬទេ?

**ឆ៖** បាទ ខ្ញុំបាននិយាយ។

[១០:៥០:០៤]

**ស៖** ពាក់ព័ន្ធនឹងអ្វីដែលលោកបានឆ្លើយ ដែលបានបោះពុម្ពនៅក្នុងសៀវភៅចំណងជើងថា "នៅក្រោយវាលពិឃាត" ខ្ញុំសូមដកស្រង់សៀវភៅដែលខ្ញុំដកស្រង់ពីមុន គឺលោកទទួលបញ្ជាឲ្យរុករកអ្នកដែលប្រឆាំង ហើយលោករកឃើញថា គ្មានអ្នកប្រឆាំងនោះទេ ក៏ប៉ុន្តែលោកបាននិយាយថា មនុស្សរាប់ពាន់នាក់ក្រោយមកត្រូវបានគេយកទៅសម្លាប់ចោល<ដោយចោទថាជាគិញ>។ តើអ្នកទាំងអស់នោះមកពីស្រុកណាដែរ? ស្រុកណាដែរ ដែលលោកសំដៅ ហើយគេសរសេរនៅក្នុងសៀវភៅនោះ?

**ឆ៖** ខ្ញុំដូចជាវាក់ត្រង់ហ្នឹង ដូចមិនចាំ។

**ស៖** នៅក្នុងការផ្តល់ចម្លើយប្រាប់អ្នកស៊ើបអង្កេតនៅក្នុងតុលាការនេះ ឯកសារ E3/9149 មិនមែនឯកសារនៅតុលាការនេះទេ គឺឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជាហៅថា ឌី.ស៊ី.ខេម ភាសាខ្មែរត្រង់ 00731255, ហើយបារាំងគឺ <0110104*(ស៊ីក)*> អង់គ្លេសគឺ <01116154> <លោកបាននិយាយអំពីប្រជាជននៅស្រុកបារាយណ៍ លោកនិយាយថា "ពេលខ្លះពួកគេមកលេងខ្ញុំ -->

**អ្នកបកប្រែ៖**

លោកប្រធាន សូមឲ្យគាត់បញ្ជាក់ឯកសារលេខបារាំងឡើងវិញ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ប្រធានអង្គជំនុំ៖**

លោកៗព្រះរាជអាជ្ញាសូមបញ្ជាក់លេខឯកសារ ERN របស់បារាំងឡើងវិញ។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** <អ្វីដែលខ្ញុំមានគឺ> 0110104*(ស៊ីក)* <វាដូចជា>ខ្ញុំបាត់លេខ<មួយខ្ទង់ ប៉ុន្តែ>ខ្ញុំសង្ឃឹមថា<វាគ្រប់គ្រាន់ឲ្យ លោក លោកស្រីអាចរកឯកសារនេះឃើញ>។ លោកបាននិយាយអំពីអ្នកដែលនៅស្រុកបារាយណ៍ ហើយលោកថា ពេលខ្លះទៅគេមកជួបលោក ហើយស្វែងរកសាច់ញាតិគេដែលបានបាត់ខ្លួន។ តើពិតដែរឬទេដែលថាអ្នកនៅស្រុកបារាយណ៍នៅឆ្នាំ២០០៨ យ៉ាងហោចណាស់ គឺមកជួបលោក ហើយសាកសួរលោក ថាតើមានអ្វីកើតឡើងចំពោះសាច់ញាតិរបស់ពួកគេ នាពេលនោះ? តើពួកគាត់មានមកជួបលោកទេ?

[១០:៥២:៥៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីការពារលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ បើយើងមើលតាមលេខ ERN <ជាភាសាបារាំង> <01101040> ហ្នឹងសំណួរដែលគេសួរទៅសាក្សីហ្នឹង គឺសួរនៅឆ្នាំ៧៩ រហូតមកដល់ពេលឥឡូវ។ អ៊ីចឹងសូមឲ្យសហព្រះរាជអាជ្ញាគាត់បញ្ជាក់ពីរយៈកាលនេះឲ្យបានច្បាស់លាស់។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** បាទ សូមអរគុណ។<>គេ<បាន>សម្ភាសលោកឆ្នាំ២០០៨ <ដូច្នេះខ្ញុំគិតថា>អ្នកសម្ភាសលោក <បានសួរលោកថា នៅពេលនោះ តើ>លោកនៅតែទាក់ទងជាមួយនឹងអ្នកដែលមកពីស្រុកបារាយណ៍នៅឡើយទេ។ ហើយលោកបានឆ្លើយថា សំណួរដែលគេសួរលោកនោះគឺថា៖ "តើមានអ្នក<>មកពីបារាយណ៍មកជួបលោកនាពេលថ្មីៗនេះដែរទេ? លោកបានឆ្លើយថា "គេ<បាន>មក<ជួបខ្ញុំមួយឆ្នាំកន្លងទៅហើយ។" អាចនៅ>ឆ្នាំ២០០៧។ "ពេលខ្លះទៅ គេមកជួប<ខ្ញុំ>ដើម្បីសាកសួរអំពីសាច់ញាតិរបស់គេដែលបានបាត់ខ្លួននាសម័យមុន។" តើលោកនៅចាំដែរទេ សូម្បីនៅឆ្នាំ២០០៧ ទោះបីជា២៨ឆ្នាំក្រោយរបបនោះដួលរលំក៏ដោយ អ្នកស្រុកបារាយណ៍ខ្លះនោះនៅមកជួបលោកសាកសួរ សូមឲ្យលោកជួយថា រកសាច់ញាតិរបស់ពួកគាត់ដែលបានបាត់ខ្លួន ហើយឲ្យលោកជួយប្រាប់ថា តើមានអ្វី

កើតឡើងចំពោះសាច់ញាតិរបស់ពួកគាត់នាសម័យនោះ។ តើអ៊ីចឹងដែរឬទេ?

[១០:៥៥:៤៧]

**2-TCW-850៖**

**ឆ៖** បាទ អ៊ីចឹងមែន គឺមានពូម្នាក់ហ្នឹងគាត់សួររកកូន ហើយកូនហ្នឹងធ្វើកងទ័ព។

**ស៖** នៅពេលដែលលោកនិយាយថាធ្វើកងទ័ពហ្នឹង កងទ័ពឲ្យខាងណាដែរ?

**ឆ៖** កងទ័ព ពេលហ្នឹងគឺកងទ័ពខាងខ្មែរក្រហម។

**ស៖** មុនពេលដែលលោកទៅដល់បារាយណ៍ ថាតើលោកបានដឹងថា គេបានសម្លាប់មនុស្ស <នៅស្រុកបារាយណ៍ដោយចោទថាជាគិញ>ដែរឬទេ ដូចដែលលោកបានប្រាប់ ថេត សម្បត្តិ?

**ឆ៖** លោក ថេត សម្បត្តិ ណា? ខ្ញុំដូចអត់ អត់ចាំ។

**ស៖** ខ្ញុំដកស្រង់ចេញពីសៀវភៅនិពន្ធដោយលោក ថេត សម្បត្តិ ដែលគាត់សរសេរជាមួយនឹង ជីណា ចន ហើយ<ពេលខ្លះគាត់ក៏ធ្វើការជាមួយ>ជនជាតិអង់គ្លេស<ម្នាក់ទៀត> ដែលគាត់<ជាអ្នកថតកុន។ នៅក្នុងសៀវភៅនេះ គេ>បានដកស្រង់<សម្ដីលោក អំពីអ្វីដែលបានកើតឡើងនៅស្រុករបស់លោក> តើលោកនៅចាំថាលោកធ្លាប់បាននិយាយជាមួយនឹងបុរសម្នាក់<> រួមជាមួយនឹងជន<បរទេសមួយចំនួន> អំពី<អ្វីដែលបានកើតឡើងក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យដែរឬទេ>?

លោកសាក្សីនេះគឺជារូបថតរបស់គាត់តូចមួយដែលនៅលើសៀវភៅនេះ <នេះគឺជាសៀវភៅដែលគេបាន>ដកស្រង់សម្ដី<លោក។ តើអាចពង្រីករូបហ្នឹងបានទេ វាមានរូបថតរបស់គាត់។> អាចចាប់កាមេរ៉ាឲ្យជិតបន្តិចទៅ នៅខាងក្រោមហ្នឹងមានកង់បុរសម្នាក់ដែលកាន់កង់ហ្នឹង គឺរូបថតរបស់ ថេត សម្បត្តិ។ តើលោកស្គាល់ ហើយចាំបុរសវ័យក្មេងម្នាក់ហ្នឹងដែរឬទេ?

[១០:៥៧:២៤]

**ឆ៖** បាទ អត់ចាំមែន។

**ស៖** នៅពេលដែលលោកទៅភូមិភាគកណ្ដាលលើកដំបូងហ្នឹង ពីមុនហ្នឹងគឺថាលោកនៅខាងនិរតី តើអ៊ីចឹងដែរឬទេ?

**ឆ៖** ខ្ញុំនៅតែខាងត្បូងភ្នំពេញហ្នឹង មិនដឹងជា ខ្ញុំដឹងតែអ៊ីចឹង។

**ស៖** លោកនិយាយថានៅស្អាង ស្អាងហ្នឹងគឺស្រុក២៥ មែនដែរឬទេ?

**ឆ៖** បាទ មែន។

សៈ ហើយគឺក្រោមការគ្រប់គ្រងរបស់ខាងភូមិភាគនិរតី តើត្រឹមត្រូវដែរឬទេ?

ឆៈ ខ្ញុំមិនសូវចាំច្បាស់ដែរ មិនដឹងជាកំណត់ត្រឹមណា ខេត្តណាខ្លះ នៅក្នុងនិរតី។

សៈ តើលោកចាំដែរឬទេ? តើលោកនៅចាំទេ នរណាគេជាលេខាភូមិភាគដែលគ្រប់គ្រងនៅលើលោកនោះ? តើលោកនៅចាំទេ នរណាជាលេខាភូមិភាគនៅគ្រប់គ្រងនៅស្រុករបស់លោក ស្រុកស្អាងរបស់លោកដែលលោកទៅនាពេលនោះ?

ឆៈ ភូមិភាគហ្នឹងខ្ញុំដូចស្រពេចស្រពិលណាស់។ វាជារួមមកដឹងឮតគ្នាទៅថា តាម៉ុកៗ។

សៈ នៅពេលដែលគេបញ្ជូនលោកទៅភូមិភាគកណ្តាល តើគេបញ្ជូនលោកតែម្នាក់ឯងតែប៉ុណ្ណោះ ឬក៏រួមជាមួយនឹងអ្នកផ្សេងទៀតនៅក្នុងតំបន់របស់លោកទៅជាមួយលោក ពេលដែលទៅភូមិភាគកណ្តាលនោះ?

[១០:៥៩:៥៤]

ឆៈ ទៅមានក្មេងពីរនាក់។

សៈ តើលោកនៅចាំឈ្មោះគាត់ទាំងពីរទេ?

ឆៈ បាទ ខ្ញុំចាំ។ ឈ្មោះៗ ចនៗ មួយ និងស្អីហើយទេភ្លេចហើយ ឈ្មោះ ទៀក។ ចន ហើយទៀក។

សៈ តើលោកបានធ្វើដំណើរទៅភូមិភាគកណ្តាលឆ្លងកាត់ភ្នំពេញដែរទេ?

ឆៈ បាទ ឆ្លងកាត់។

សៈ មុនពេលបញ្ជូនលោកទៅភូមិភាគកណ្តាល តើគេមានបញ្ជូនលោកទៅទទួលការបណ្តុះបណ្តាល ឬក៏ទទួលការណែនាំមុនពេលបញ្ជូនទៅភូមិភាគកណ្តាលទេ? គេអាចបញ្ជូនលោកទៅបណ្តុះបណ្តាលណែនាំនៅក្នុងកន្លែងណាមួយក្នុងទីក្រុងភ្នំពេញ <ឬកន្លែងណាផ្សេង>?

ឆៈ បាទ អត់មានទេ គឺដឹកទៅពេលយប់។

សៈ សូមលោកពន្យល់បន្ថែមទៅ សូមបរិយាយបន្ថែមទៅ គេដឹកលោកនៅពេលយប់ ហើយគេមានឈប់ឲ្យលោកសម្រាកនៅក្នុងក្រុងភ្នំពេញដែរឬទេ?

ឆៈ អត់មានទេ អត់មានសម្រាកនៅភ្នំពេញទេ ប៉ុន្តែគេណែនាំថាទៅឡានដឹកយកទៅ ចេញពីថ្ងៃរសៀលទៅ។

[១១:០២:១២]

**ស៖** នៅតាមផ្លូវ ឬក៏នៅពេលលោកទៅដល់ភូមិភាគកណ្តាល តើលោកមានទាក់ទងជាមួយនឹងលេខាស្រុកមួយឈ្មោះ ប្រាក់ យុត ដែរទេ?

**ឆ៖** បាទ ខ្ញុំស្គាល់តែលោក ប្រាក់ ឈ្មោះ ប្រាក់ៗ ប្រធានតំបន់ ដែលបញ្ជូនខ្ញុំ ហើយណែនាំឲ្យខ្ញុំ។

**ស៖** ខ្ញុំកំពុងតែ<និយាយពីស្ត្រីម្នាក់។ តើលោកកំពុងតែនិយាយពីស្ត្រីម្នាក់ដែល>ជាលេខាស្រុក<ម្នាក់ដែរនៅភូមិភាគកណ្តាល>គឺនៅតំបន់៤២?

**ឆ៖** បាទ ប្រាក់ ហ្នឹងគាត់នៅឯខេត្តកណ្តាល គាត់នៅកណ្តាល ហើយគាត់ដែលត្រូវបញ្ជូនខ្ញុំ និងតែងតាំងខ្ញុំ -- បញ្ជូនខ្ញុំមកភាគកណ្តាលហ្នឹង។ ដឹងតែ ប្រាក់ ហ្នឹងទេ។

**ស៖** តើលោកស្គាល់ ពេជ្រ ជឹម ដែរឬទេ? តើលោកនឹកឃើញមនុស្សម្នាក់ឈ្មោះ ពេជ្រ ជឹម ដែរឬទេ លោកស្គាល់ដែរឬទេ?

**ឆ៖** ពេជ្រ ជឹម ខ្ញុំអត់ស្គាល់ទេ។

**ស៖** គាត់ទៅពីខាងស្រុកត្រាំកក់ទៅ ខ្ញុំសូមអានចម្លើយមួយ ដើម្បីជួយរំឭកដល់ការចាំរបស់លោកគឺ E3/9587 គឺសំណួរចម្លើយលេខ២២០ និង២២១។ <ពេជ្រ ជឹម បាននិយាយថា> “ខ្ញុំអាចនឹកឃើញដល់លេខាស្រុកតាំងគោក។ <ឈ្មោះគាត់គឺ” -- ហើយ>គាត់និយាយអំពីឈ្មោះរបស់លោក។ សួរ៖ តើឈ្មោះរបស់គាត់នេះ ទៅដល់ភូមិភាគកណ្តាលនៅពេលណា? ពេជ្រ ជឹម ឆ្លើយថា ឈ្មោះរបស់លោកហ្នឹង គឺបានទៅដល់ភូមិភាគកណ្តាលនៅពេលជាមួយនឹង ពេជ្រ ជឹម ដែរ។ តើលោកនឹកឃើញទេថា លោកបានទៅដល់ភូមិភាគកណ្តាលនៅចំពេលជាមួយគ្នានឹងឈ្មោះ ពេជ្រ ជឹម ដែលគាត់ទៅពីស្រុកត្រាំកក់ទៅ?

[១១:០៦:០៤]

**ឆ៖** បាទ គឺខ្ញុំដូចជា ភ្លាប់មិនបានរឿងលោក ពេជ្រ ជឹម មកពីត្រាំកក់ ថាដំណើរមកជួបគ្នា ជាមួយនឹងគាត់ គឺខ្ញុំអត់បាន – អ្នេមិនដឹងថ្ងៃបញ្ជូនខ្ញុំមកហ្នឹង យកទៅដាក់ហ្នឹង គឺខ្ញុំមានតែ គ្នាដូចខ្ញុំបានលើកអ៊ីចឹង បីនាក់ក្មេង។

**ស៖** ឥឡូវខ្ញុំសូមសួររឿងមួយដែលកូនប្រុសរបស់ កែ ពក បាននិយាយ។ ដំបូងសួរអ៊ីចេះ សួរថាតើលោកធ្លាប់ដែលបានជួប កែ ពេជ្រវណ្ណៈ ដែរទេ?

**ឆ៖** ខ្ញុំអត់ស្គាល់ មិនដឹងជា កែ ពេជ្រវណ្ណៈ ហ្នឹង ខ្ញុំបាត់--។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សៈ** កែ ពេជ្រវណ្ណៈ នេះគឺគាត់ស្គាល់លោក។ គឺឯកសារ E3/35 ERN ជាភាសាខ្មែរ 00340565, បារាំង 00367732, អង់គ្លេស 00346152។ គាត់បានឆ្លើយដូចតទៅនេះ៖ “នៅពេលក្រុមពួកនិរតីទៅដល់ ហើយការបោសសម្អាតចាប់ផ្តើម គឺយើងចាប់ផ្តើមធ្វើពីថ្នាក់ស្រុកទៅដល់ភូមិ។ គណៈកម្មាធិការស្រុកបារាយណ៍ គឺថាក្រោយពេលពួកនិរតីទៅដល់ (គឺគាត់លើកពីឈ្មោះរបស់លោកយកមកនិយាយ) ថាឥឡូវគាត់រស់នៅអន្លង់វែង។” គាត់បានបញ្ជាក់ថា ក្រោយក្រុមនិរតីទៅដល់ការបោសសម្អាតក៏ចាប់ផ្តើមឡើង។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ខ្ញុំនៅមិនទាន់ ច្បាស់រឿង កែ វណ្ណៈ។ហ្នឹង។ ហើយខ្ញុំក៏អត់បានឮ អត់បានដឹងពីបញ្ហាអំមិញហ្នឹងដែរ។

[១១:០៨:៥៣]

**សៈ** អ៊ីចឹងចំណុចនេះហាក់បីដូចជា ស៊ីចង្វាក់គ្នា ដែលនូវអ្វីដែលលោកប្រាប់ទៅ ថេត សម្បត្តិ ហើយដែលគាត់បានសរសេរនោះ ថានៅក្នុងស្រុករបស់លោក គឺមនុស្សរាប់ពាន់នាក់ត្រូវបានគេសម្លាប់ដោយចោទប្រកាន់ថាជាគិញ។ លោកសាក្សី នៅពេលនេះខ្ញុំមិនចោទប្រកាន់លោកទេ ក៏ប៉ុន្តែចង់ឲ្យលោកប្រាប់ការពិត<> តើ<លោកបានដឹងថាមានរឿងនេះបានកើតឡើងទេ? ខ្ញុំមិនមែនសួរលោកថាតើលោកបានធ្វើវា ឬក៏លោកបានប្រឆាំងនឹងវានោះទេ។ តើ>វាពិតដែរទេ ដែលថានៅស្រុកបារាយណ៍នោះ នៅពេលដែលលោកបានទៅដល់ ប្រជាជនរាប់ពាន់នាក់ត្រូវបានបោសសម្អាត ត្រូវបានសម្លាប់ចោល ដោយសារគេចោទប្រកាន់ប្រជាជនទាំងនោះថា មិនស្មោះស្ម័គ្រ មិនស្មោះត្រង់ជាមួយនឹងរបបនោះ តើពិតដែរឬទេ?

**ឆ៖** ពេលខ្ញុំទៅដល់ហ្នឹង គឺឮតែប្រជាជនគាត់និយាយ។ បាទ និយាយអ៊ីចឹងមែន។

**សៈ** តើលោកបានស្តាប់ឮពីប្រជាជននិយាយថាម៉េច ចំពោះប្រជាជនរាប់ពាន់ដែលត្រូវបានគេសម្លាប់ចោល<>ដោយ<គ្មាន>កំហុសអ្វី?

**ឆ៖** ខ្ញុំក្តាប់អត់បានទេ មិនដឹងជាកំហុសខុសឆ្គងកម្រិតណា កម្រិតណា ខ្ញុំអត់បានដឹង។

**សៈ** ខ្ញុំសូមអានចម្លើយមួយឲ្យលោកស្តាប់។ ទី១ ខ្ញុំសូមសួរទៅលោកជាដំបូងសិន ថាលោកស្គាល់ឈ្មោះមនុស្សម្នាក់ឈ្មោះ <សូ រ៉េន ដែលត្រូវបានគេដាក់គុក>នៅមន្ទីរសន្តិសុខ។ ខ្ញុំសូមឲ្យសហការីរបស់ខ្ញុំសូមអានឈ្មោះរបស់ -- បាទ គឺនៅឃុំជីវភាព ស្រុកតាំងគោក។ លោកសាក្សី តើលោកស្គាល់មនុស្សម្នាក់ឈ្មោះ <សូ រ៉េន> ដែរទេ?

**ឆ៖** បាទ ខ្ញុំអត់ស្គាល់ទេ។

[១១:១១:៤៣]

**ស៖** នេះគឺជាអ្វីដែលគាត់ឆ្លើយជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាគឺ <E3/2073>, អង់គ្លេស 00876419, បារាំង <00892873> ខ្មែរ 00055197។ គាត់បានឆ្លើយថា "ចៅហ្វាយស្រុកតាំងគោក នេះ<គឺ"> {<គាត់និយាយពី>ឈ្មោះលោក <ហើយគាត់បន្ត>ថា} "សព្វថ្ងៃនេះ គាត់នៅរស់រានទេ <ប៉ុន្តែ"> ហើយ<បន្ទាប់មក>គាត់និយាយអំពីរបួស<របស់លោក> ដែលលោកបានទទួល<ការឈឺចាប់ ហើយនៅតែឈឺចាប់បន្តមក>។ គាត់និយាយថា សព្វថ្ងៃនេះគឺលោករស់នៅអន្លង់វែង ហើយគាត់បានជម្រាបទៅអ្នកសម្ភាសគាត់នោះថា គឺថាគាត់ជាមនុស្សម្នាក់ក្នុងចំណោមមនុស្ស<បី>នាក់ ដែលរស់រានមានជីវិតពីមន្ទីរសន្តិសុខមួយ<ដែលមានអ្នកទោស៧០នាក់នៅក្នុងនោះ>។ ហើយគាត់បានបន្តឆ្លើយតទៅទៀត នៅត្រង់ទំព័របន្ទាប់ថា ខ្ញុំផ្តល់លេខ ERN ជាថ្មីម្តង អង់គ្លេស 0087674--

**អ្នកបកប្រែ៖**

បាទ លោកប្រធានសូមការអនុញ្ញាត គាត់អាន ERN ញាប់ពេក ស្តាប់អត់ទាន់។

**ប្រធានអង្គជំនុំ៖**

លោកព្រះរាជអាជ្ញា លោកអានលេខ ERN ឲ្យបានយឺតៗបន្តិច ដើម្បីអ្នកបកប្រែស្តាប់បាន។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** សូមទោស។ អង់គ្លេស 00876423, បារាំង 00892872, ខ្មែរ 00055201។ គឺគាត់ សូ វ៉ែន ឆ្លើយថា <"វាជាបញ្ជាមកពីថ្នាក់តំបន់ គឺពី"> គាត់លើកពីឈ្មោះរបស់លោក ថានៅក្នុងឆ្នាំ១៩៧៧ គឺលោកនេះ បានឆ្លើយសារភាពថា លោកបានធ្វើខុស ដោយសារតែលោកបានសម្លាប់មនុស្ស ដោយមិនបានពិចារណា។ ហើយបានគេសួរ<គាត់>ថា៖ តើម៉េចបានជាលោកឆ្លើយសារភាពថាដូច្នេះ? <គាត់>ឆ្លើយថា៖ លោកបាន<សារភាពថា លោកបាន>សម្លាប់មនុស្សដោយមិន<>ត្រឹមត្រូវទេ។ ហើយ<គេ>សួរ<គាត់>ថា៖ ហេតុអីបានលោកឆ្លើយសារភាព? <គាត់និយាយថា "គ្នាយើងបានសួរគាត់"។ គេសួរថា៖ តើរឿងនេះកើតនៅពេលណា?> ហើយយោងទៅតាម សូ វ៉ែន <ថាលោកនិយាយរឿង> នេះនៅក្នុងឆ្នាំ១៩៧៧ <នៅ>ចម្ការកៅស៊ូ។ <តើ>លោកនៅចាំ<>ថា<បានជួបមនុស្សមួយក្រុម>នៅឯចម្ការកៅស៊ូ <ដែលពួក>គាត់ខឹងសម្បានឹងការបាត់បង់បងប្អូនសាច់ញាតិរបស់គាត់?

[១១:១៥:១២]

**2-TCW-850៖**

**ឆ៖** ខ្ញុំអត់បានដឹងទេ ក្នុងចម្លើយនេះ ហើយសំណួរនេះ។ ហើយអត់ស្គាល់ឈ្មោះស្អី រិន ហ្នឹងផង។

**ស៖** តើលោកមានចាំទេ លោកធ្លាប់បាននិយាយទៅហ្វូងមនុស្សមួយក្រុមនៅឯចម្ការកៅស៊ូ ហើយ <ដែល>ប្រជាជនទាំងនោះ<ចោទប្រកាន់លោក ឬក៏ចោទរបបនោះថា>កាប់សម្លាប់សាច់ញាតិ ឬក៏បងប្អូនរបស់គាត់ លោកចាំទេ?

**ឆ៖** បាទ ខ្ញុំអត់ចាំទេ។

**ស៖** លោកសាក្សី តើលោកមានបានមករៀនសូត្រនៅភ្នំពេញអំពីវគ្គនយោបាយដែរឬទេ?

**ឆ៖** វគ្គនយោបាយហ្នឹងគឺខ្ញុំបាទអត់ដែលបានទៅរៀននៅភ្នំពេញទេ។

**ស៖** តើលោកមានបានមករៀនសូត្រនៅភ្នំពេញនេះ ជាមួយនឹង នួន ជា ដែរឬទេ?

**ឆ៖** បាទ អត់ដែលទេ។

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន សូមការអនុញ្ញាតបញ្ចាំង*ឃ្លីប*វីដេអូលេខ៣។

[១១:១៦:៥៨]

**ប្រធានអង្គជំនុំ៖**

មន្ត្រីសោតទស្សន៍ដាក់បញ្ចាំង*ឃ្លីប*វីដេអូនេះលើអេក្រង់ទូរទស្សន៍។

សូមអញ្ជើញលោកមេធាវី!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ មុនពេលចាក់វីដេអូនេះ ខ្ញុំចង់ដឹងថាតើវីដេអូនេះ ពាក់ព័ន្ធនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា ឬក៏យ៉ាងម៉េច? បើអ៊ីចឹងទេ សូមឲ្យលេខ ERNផង។

**លោក នីកូឡាស គូមជែន៖**

<បាទ ជាឯកសារមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា> គឺE3/9149 បារាំង 01101033, ខ្មែរ 00731247, អង់គ្លេស 01116149 ហើយវីដេអូ*ឃ្លីប*នេះ គឺនៅម៉ោង -- តាមពិតទៅគឺនៅនាទីទី២៧: ១៥វិនាទី។

**ប្រធានអង្គជំនុំ៖**

សូមមន្ត្រីសោតទស្សន៍ចាក់បញ្ចាំងឃ្លីបវីដេអូនេះ!

[១១:១៨:៥៤]

*(ការបង្ហាញឯកសារជាសំឡេង)*

*"...ចុះអ៊ីកាលជំនាន់នោះ ដូចថា មួយឆ្នាំយើងត្រូវតែឡើងមកភ្នំពេញមកប្រជុំម្តង? ឆ្លើយ៖ បាទ សួរ៖ មកប្រជុំហ្នឹងមកប្រជុំជាមួយអ្នកណាគេ? ឆ្លើយ៖ ប្រជុំរួមអ៊ីចឹងទៅគ្រប់ស្រុក គ្រប់ខេត្តអ៊ីចឹង ប្រជុំនៅភ្នំពេញហ្នឹង។ សួរ៖ ក្រោមអធិបតីរបស់អ្នកណា? ឆ្លើយ៖ របស់ នួន ជា អ៊ីចឹង។..."*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង)*

[១១:១៩:២៦]

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី លោកស្តាប់ទៅនេះ លោកស្គាល់សំឡេងរបស់លោកទេ?

**2-TCW-850៖**

**ឆ៖** បាទ ស្គាល់។

**ស៖** លោកសាក្សី ចុះហេតុអីបានជាឥឡូវនេះ លោកប្រាប់ថា លោកមិនដែលបានឡើងមករៀនសូត្រនយោបាយនៅភ្នំពេញ? ឯនៅឆ្នាំ២០០៨ ក្នុងកិច្ចសម្ភាសន៍មួយនេះ លោកថា លោកបានឡើងមករៀនសូត្រនយោបាយនៅភ្នំពេញ<មួយឆ្នាំម្តង>គឺរៀនជាមួយនឹង នួន ជា។ ហេតុអ្វីនៅពេលនេះ លោកឆ្លើយផ្សេងទៅវិញ ឯនៅឆ្នាំ២០០៨ លោកឆ្លើយផ្សេង <តើលោកខ្លាចឬ>?

**ឆ៖** បាទ រឿងនេះខ្ញុំវាក់ វាក់ដែរការចាំវាមិនអស់។

**ស៖** ខ្ញុំមិនយល់លោក លោកនឹកអត់មានឃើញអ្វីសោះ។ ចុះនិយាយអំពីបាត់ខ្លួនសហការី ឬក៏សមមិត្តរបស់លោកនេះ តើលោកភ្លេចដែរទេ?

**ឆ៖** បាទ ការចងចាំវាមិនបានចិតថេរទេ។

**ស៖** តើលោកចង់បំភ្លេចរឿងទាំងអស់នោះ ដោយសារថារឿងនោះវាជារឿងអាក្រក់ រឿងមិនល្អ ឬក៏ដោយសារ<តែលោកមានអារម្មណ៍ថាមានកំហុស>? តើលោកអាចរៀបរាប់បានទេ<ថាហេតុអ្វីបានជាលោកមិនអាចចងចាំព្រឹត្តិការណ៍ទាំងអស់នេះ>?

**ឆ៖** បាទ ខ្ញុំមិនមានគំនិតអី ឬក៏ការលាក់លៀមពីតុលាការទេ។

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** តើលោក<អាចប្រាប់យើងបានទេ ថាតើលោក>ដឹងអំពីមន្ទីរសន្តិសុខមួយនៅបារាយណ៍ជាន់ដែកដែរឬទេ?

**ឆ៖** មន្ទីរសន្តិសុខនៅបារាយណ៍នៅជាន់ដែកហ្នឹងគឺខ្ញុំអត់ដឹង ដែលខ្ញុំបានឆ្លើយពីកិច្ចសម្ភាសន៍លើកមុនហ្នឹង ព្រោះដូចខ្ញុំបានជម្រាបអីចឹង ទៅដល់គឺគិតតែពីការងារ ហើយក៏មិនទាន់ស្គាល់ ពេលខ្លី។ ហើយលោកអ្នកសម្ភាសក៏សួរៗខ្ញុំទៅ ខ្ញុំក៏មិនដឹង ហើយមិនស្គាល់ ព្រោះចូលភ្លាមមិនអាចស្គាល់ទាំងអស់បាន។

[១១:២២:៥៨]

**ស៖** មានកម្មាភិបាលមួយរូបទៀតដែលគេបានសម្ភាសគាត់ឈ្មោះ បាន សៀក។ នៅក្នុងចម្លើយរបស់គាត់ E3/375 អង់គ្លេសគឺ 00360759, បារាំង 00369922, ខ្មែរ 00348800។ អ្នកសម្ភាសក៏បានសួរគាត់អំពីព្រឹត្តិការណ៍ផ្សេងៗ ដែលទាក់ទងទៅនឹងវត្តមួយនៅបារាយណ៍ជាន់ដែក គាត់បានឆ្លើយថា "បើសិនជាលោកចង់ច្បាស់គឺលោកអាចទៅសួរបង {គឺជាលោកនេះឯង គាត់<លើក> ឈ្មោះលោកមក។ <ហើយគាត់បន្តថា>} គាត់ធ្វើការនៅស្រុកបារាយណ៍។ <យ៉ាងហោចណាស់មួយខែម្តង គាត់ទៅមើលទីនោះម្តង។> បើសិនណាជាគាត់មិនអាចទៅបាន គឺគាត់អាចចាត់តាំងកូនចៅរបស់គាត់ក៏ឲ្យទៅមើលមន្ទីរសន្តិសុខនោះដែរ។ ទោះជាយ៉ាងណាក៏ដោយ គាត់មិនអាចឆ្លើយថា គាត់មិនដឹងអំពីមន្ទីរសន្តិសុខមួយនេះបានទេ។ នៅពេលដែលធ្វើការចាប់ខ្លួននេះ គឺថ្នាក់ស្រុកត្រូវតែដឹងអំពីការចាប់ខ្លួន។"

ហើយត្រង់ចម្លើយលេខ៣៤គឺឯកសារ <E319/19.3.86> គាត់ថា "ក្នុងឋានៈ<>ជាលេខាស្រុកគឺថា <គាត់>ត្រូវតែដឹងអំពីមន្ទីរសន្តិសុខ<នៅក្នុងស្រុករបស់គាត់>។ <នៅក្នុងសក្ខីកម្មរបស់គាត់នៅមុខអង្គជំនុំជម្រះនេះ> ឯកសារនេះឯកសារ E319/19.3.86 នៅថ្ងៃទី០៥ តុលា កាលពីឆ្នាំទៅ បាន សៀក គាត់បានឆ្លើយ ដោយលើកឈ្មោះរបស់លោកមកនិយាយថា "លោកមកពីភូមិភាគនិរតី ដែលថាក្រោយពេលបាត់ខ្លួនរបស់កម្មាភិបាលភូមិភាគកណ្តាលហើយ គឺថាគាត់<ត្រូវតែ>ដឹងអំពី<ការចាប់ខ្លួនកម្មាភិបាលទាំងនោះ ឬក៏យ៉ាងហោចណាស់ក៏ដឹងអំពី>ទីតាំង និងទីកន្លែងទាំងអស់នោះ។

លោកសាក្សីថា តើចម្លើយរបស់ បាន សៀក នេះត្រឹមត្រូវដែរឬទេ? ហើយឬក៏<ហេតុអ្វីបានជា>លោកឆ្លើយថា <គាត់និយាយ>មិនត្រឹមត្រូវទេ? ហើយក្នុងឋានៈជាលេខាស្រុក តើលោកពិតជាមិនដឹងអ្វីសោះមែនឬ? តើលោក<មិនបាន>ដឹងអំពីការចាប់ខ្លួនមនុស្សនៅក្នុងស្រុករបស់លោកទេ<ឬ>?

[១១:២៥:៤២]

ឆ៖ ខ្ញុំ ដែលឆ្លើយថា ខ្ញុំអត់ដឹងនេះ គឺដូចខ្ញុំបានបញ្ជាក់អ៊ីចឹង ខ្ញុំទៅថ្មី ហើយលោក បាន សៀក ដែលបានបញ្ជាក់ថា ខ្ញុំធ្វើលេខាស្រុក ហើយម៉េចក៏មិនដឹងកន្លែងហ្នឹង។ ការឆ្លើយរបស់លោក បាន សៀក នេះគឺជាការឆ្លើយ វាអត់ទាន់ត្រឹមត្រូវដែរទេ ព្រោះកន្លែងហ្នឹងជាកន្លែងសន្តិសុខ ប៉ុន្តែខ្ញុំបាទទៅក្រោយមែន ឲ្យខ្ញុំដឹងទាំងអស់ឯណាបាន។ ទៅភ្លាមដឹងទាំងអស់ភ្លាមហ្នឹង គឺអត់ទេ។ អាហ្នឹងខ្ញុំឆ្លើយមុនគឺអ៊ីចឹង។ ហើយលោក បាន សៀក នេះគាត់ចេះតែនិយាយទៅឲ្យខ្ញុំដឹងម៉េច រឿងចាប់ពីខែមុន ឆ្នាំមុនមកហើយ ឲ្យខ្ញុំទៅភ្លាម ឲ្យខ្ញុំឆ្លើយថាខ្ញុំស្គាល់ ខ្ញុំដឹង ឲ្យបានច្បាស់លាស់ហ្នឹងគឺ អត់ទេ។

ស៖ តើលោកមានបានទទួលបញ្ជីឈ្មោះដែលថ្នាក់លើចង់ធ្វើការស៊ើបសួរដែរឬទេ? មិនមែនលោកទេ ថ្នាក់លើបញ្ជាមកឲ្យមានការស៊ើបសួរ ហើយលោកបានទទួលបញ្ជីឈ្មោះនេះទេ?

ឆ៖ បាទ ខ្ញុំអត់ដែលបានទេ បានទទួលបញ្ជីឈ្មោះទេ។

ស៖ ចុះខ្លួនលោកផ្ទាល់ហ្នឹង លោកធ្លាប់ធ្វើការស៊ើបអង្កេតក្នុងរឿងទាំងនេះទេ?

ឆ៖ ខ្ញុំដូចមិនធ្លាប់ទេ ខ្ញុំអត់ដែលធ្លាប់រឿងស៊ើបអង្កេតហ្នឹង ខ្ញុំជំនាញខ្ញុំហ្នឹងគិតតែពីរឿងបញ្ហាអនុវត្តផែនការធ្វើស្រែ គឺធ្វើម៉េចដោះស្រាយឲ្យបានប្រជាជនមានហូប។ ហើយផែនការ ៣តោន ក្នុង១ហិកតា។ ហើយកម្មាភិបាលណាធ្វើមិនបាន គឺត្រូវមានៗទោសហើយ។ ដល់អ៊ីចឹងខ្ញុំមិនបានគិតពីបញ្ហាបញ្ជី១០០អីៗទេ។ បាទ ខ្ញុំនិយាយពីផ្ទាល់ខ្លួនរបស់ខ្ញុំ។

ស៖ តើលោកធ្លាប់ដែលបានអនុវត្តគោលនយោបាយស្តីអំពីខ្មាំងដែរឬទេ?

ឆ៖ បាទ រឿងគោលនយោបាយហ្នឹងគឺមាន បាទៗ។

[១១:២៨:០៣]

ស៖ <និយាយអ៊ីចឹង>គោលនយោបាយពាក់ព័ន្ធនឹងខ្មាំង <ឬអ្នកដែលគេសង្ស័យ>នេះ <>តើគោលនយោបាយនេះមាននិយាយអំពីជនជាតិចាមដែរឬទេ?

ឆ៖ បាទ គោលនយោបាយនេះ គឺខ្ញុំមិនៗដែលដឹង ហើយក៏មិនបានចាំអំពីគោលនយោបាយអំពីការដោះស្រាយ ឬក៏ការធ្វើទុក្ខ ធ្វើទោសយ៉ាងម៉េចចំពោះចាមអីគឺអត់។

ស៖ ពីមុននេះខ្ញុំអានចម្លើយរបស់លោកនៅឆ្នាំ២០០៨ឲ្យលោកស្តាប់ លោកបានឆ្លើយថា៖ “នៅក្នុងរបបនោះ ខ្ញុំមិនដឹងថាថ្ងៃណានឹងដល់វេនរបស់ខ្ញុំទេ។” ហើយ<លោកបានប្រាប់យើងនៅព្រឹកមិញនេះថានៅក្នុងរបបនោះ> លោកមានការ<ភ័យខ្លាច ហើយព្រួយ>បារម្ភ<>នឹងបញ្ហាសុវត្ថិភាពសន្តិសុខ

របស់លោក។ <តើហេតុអ្វីបានជាអ៊ីចឹង>? លោកមិនបានធ្វើអ្វីខុសទេ <>ហេតុអីបានលោកព្រួយបារម្ភពីបញ្ហាអាយុជីវិតរបស់លោក ហើយលោកថា មិនដឹងថាថ្ងៃណាដល់វេនខ្ញុំទេ?

**ឆ៖** បាទ ពេលនោះខ្ញុំនិយាយអ៊ីចឹងមែន គឺខ្ញុំបារម្ភ។ ដល់តែបារម្ភ ខ្ញុំបារម្ភ ខ្ញុំនឹងខំធ្វើម៉េចកុំឱ្យៗមាន កុំឱ្យមានកំហុសចំពោះលើច្បាប់ជំនាន់នោះមែន អាហ្នឹងអ៊ីចឹង។ ប្រយ័ត្នណាស់ ភ័យណាស់ ព្រោះនៅក្នុងរបបមួយដែលប្រៀបបាននឹងពពកខ្មៅ។

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន ឃើញថាដល់ពេលដែលត្រូវឈប់ពិសាបាយហើយ។

[១១:៣១:៤២]

**ប្រធានអង្គជំនុំ៖**

អរគុណលោកព្រះរាជអាជ្ញា។ ឥឡូវដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយកន្លះរសៀល។ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ លោកសាក្សីឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ លោកអាចសម្រាកបានហើយ។ អង្គជំនុំជម្រះអញ្ជើញលោកមកកាន់កន្លែងផ្ដល់សក្ខីកម្មវិញឱ្យបានមុនម៉ោងមួយកន្លះរសៀលនេះ។ លោកមេធាវីប្រឹក្សាក៏ដូចគ្នា លោកអាចសម្រាកបានហើយ ហើយសូមអញ្ជើញមកកាន់កន្លែងផ្ដល់សក្ខីកម្មវិញនៅម៉ោងមួយសាមសិបនាទី។

បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួន លោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការ និងបង្គាប់ឱ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឱ្យបានមុនម៉ោងមួយកន្លះ។

សូមអញ្ជើញសម្រាក!

*(សវនាការសម្រាកពីម៉ោង ១១:៣២ នាទី ដល់ម៉ោង ១៣:២៨ នាទី)*

[១៣:២៨:៥៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

អង្គជំនុំជម្រះបន្តសវនាការ។ អង្គជំនុំជម្រះសូមជម្រាបលោកព្រះរាជអាជ្ញា និងមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី ថាពេលវេលារបស់លោកនៅសល់២០នាទីទៀត។

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**សួរដោយលោក នីកូឡាស គូមជែន៖**

**សៈ** លោកសាក្សី សួស្តី! តើលោកឮខ្ញុំនិយាយទេ?

**2-TCW-850៖**

**ឆៈ** បាទ ឮ។

**សៈ** លោកបាននិយាយព្រឹកមិញអំពីវិធីបុណ្យ ហើយនិង<អ្នកអុជ>ធូប ហើយលោកបាន <ប្រាប់ទៅពួកគេថា មិនអីទេ ប៉ុន្តែ>បើសិនជាគេដឹង គេនឹងសម្លាប់ពួកយើងចោល។ ហេតុអ្វីបានជាគេសម្លាប់មនុស្សចោល បើគ្រាន់ត្រឹមតែដុតធូបធ្វើបុណ្យសោះហ្នឹង នៅក្នុងរបបនោះ?

**ឆៈ** បាទ ខ្ញុំមិនដឹងដែរ ប៉ុន្តែចេះតែបារម្ភ ប្រាប់គាត់ ព្រោះបុណ្យគេអត់ជឿ។

[១៣:៣០:៤២]

**សៈ** នៅពេលដែលលោកនិយាយថា "ពួកគេមិនជឿទៅលើពិធីបុណ្យផ្សេងៗនោះទេ"។ តើ <លោកអាចពន្យល់បានទេ តើ>លោកបានទទួលការណែនាំយ៉ាងម៉េចអំពីគោលនយោបាយ ពាក់ព័ន្ធនឹងពិធីបុណ្យផ្សេងៗ ហើយនិងការគោរពសាសនា? តើមេលោកប្រាប់គោលនយោបាយយ៉ាងម៉េច ពាក់ព័ន្ធទៅនឹងការគោរពសាសនា និងពិធីបុណ្យ?

**ឆៈ** ព្រោះកន្លងមកមិនឃើញមានវត្ត មិនឃើញមានស្អីៗទៅ ដល់អ៊ីចឹងខ្ញុំចេះតែព្រួយបារម្ភ ព្រោះគេថាអត់ជឿហើយ។

**សៈ** ដោយសារលោកជាអតីតព្រះសង្ឃ ប្រហែលជាលោកចាប់អារម្មណ៍នឹងប្រធានបទនេះ។ ក្នុងចិត្តរបស់លោក តើលោកនៅតែជឿជាក់ ហើយនិងចាត់ទុកខ្លួន និងគោរពសាសនាព្រះពុទ្ធដែរឬទេ?

**ឆៈ** បាទ ខ្ញុំជឿរហូត។

**សៈ** <ប៉ុន្តែ>នៅក្នុងរបបនោះ <តើត្រឹមត្រូវទេ>គឺលោកមិនបានគោរព និងប្រតិបត្តិសាសនានោះទេ <ឬក៏>លោក<គោរពដែរ ប៉ុន្តែលោកធ្វើដោយសម្ងាត់>។ តើត្រឹមត្រូវដែរឬទេ?

**ឆៈ** បាទ ក្នុងសភាពការណ៍នោះ ខ្ញុំយល់ថា វាត្រឹមត្រូវ។

**សៈ** ហេតុអ្វីគិតថា លោកគិតថាត្រឹមត្រូវ? ហេតុអ្វីបានជាលោកគិតថានឹងធ្លាក់ក្នុងសភាពគ្រោះថ្នាក់ប្រសិនបើគេដឹងថាគោរពសាសនា?

**ឆៈ** បាទ ខ្ញុំខ្លាចបារម្ភ ដូចខ្ញុំបានបញ្ជាក់អ៊ីចឹង បើកាលណាយើងធ្វើដោយមិនបានការអនុញ្ញាត

ឬក៏--

[១៣:៣២:៥៤]

**ស៖** លោកសាក្សីៗ តើលោកដឹងអំពីគោលនយោបាយពាក់ព័ន្ធនឹងសាសនានេះយ៉ាងដូចម្តេចដែរ តាមរបៀបណាទៅ? តើលោកបានអាន ឃើញនៅក្នុងសៀវភៅ កាសែត ឬក៏ទទួលការណែនាំ ឬក៏ចូលរួមប្រជុំ ទើបបានដឹងថាការប្រតិបត្តិសាសនាបែបនេះ ឬក៏បែបណានោះ ត្រូវបានអនុញ្ញាត ឬក៏មិនត្រូវបានអនុញ្ញាត?

**ឆ៖** ក្នុងសំណួរនេះ ខ្ញុំដូចជាពិបាកឆ្លើយ។ ខ្ញុំយល់មិនដល់។

**ស៖** លោកសាក្សី តើលោកធ្លាប់បានជួប នួន ជា, ប៉ុល ពត, ខៀវ សំផន ក្នុងរបបនោះដែរឬទេ?

**ឆ៖** ត្រឹមនឹងខ្ញុំ មិនដែលបានជួបដោយផ្ទាល់ទេ។

**ស៖** ក៏ប៉ុន្តែនៅក្នុងសៀវភៅ ថេត សម្បត្តិ ដែលខ្ញុំបានដកស្រង់<នោះ និយាយថា លោកបាន> ដកស្រង់<សម្តី>ប៉ុល ពត <មកនិយាយ។ លោក>ថា <ប៉ុល ពត បានសួរថា> មនុស្សទាំងអស់ហ្នឹងទៅណា? <តើនរណានឹងត្រូវបានគេ>យកទៅសម្លាប់ចោល។ ហើយនៅក្នុងខ្សែអាត់សំឡេងនោះ លោកបាននិយាយអំពីការដែលលោកបានចូលប្រជុំជាមួយនឹង នួន ជា ផងដែរ។ តើលោកនៅតែរក្សាចម្លើយថា មិនដែលធ្លាប់ជួបអ្នកទាំងអស់នោះដែរឬទេ ឬក៏លោកឆ្លើយយ៉ាងម៉េចដែរ?

**ឆ៖** ខ្ញុំអត់បានចាំទាំងអស់ ដូចខ្ញុំថាអ៊ីចឹងដែរ វាយូរឆ្នាំដែរ។

[១៣:៣៤:៥៨]

**លោក នីកូឡាស គូមជែន៖**

លោកសាក្សី ខាងតំណាងសហព្រះរាជអាជ្ញាជាតិមានសំណួរខ្លះ ចង់សួរបន្តទៀត តែខ្ញុំអស់ហើយលោកសាក្សី។ សូមអរគុណ។

**លោក សេង លាង៖**

ជាបឋម សូមគោរពលោកប្រធាន។ សូមគោរពអង្គសវនាការទាំងមូល។ ខ្ញុំបាទឈ្មោះ សេង លាង ជាតំណាងសហព្រះរាជអាជ្ញាជាតិ – សហព្រះរាជអាជ្ញារងជាតិ។

**សួរដោយលោក សេង លាង៖**

**ស៖** ថ្ងៃនេះ ខ្ញុំមានសំណួរទៅលើប្រធានបទមួយចំនួន ហើយចង់សួរទៅលោកសាក្សី ឲ្យលោក

សាក្សីជួយបំភ្លឺដល់អង្គសវនាការទាំងមូល។ ខ្ញុំចាប់អារម្មណ៍ទៅលើពេលវេលាមួយដែលលោកត្រូវបានគេផ្លាស់ប្តូរឲ្យទៅបម្រើការនៅស្រុកបារាយណ៍។ តើលោកអាចបញ្ជាក់បានទេថា ម្តងទៀតបានទេថា តើពេលណាពិតប្រាកដដែលលោកទៅបំពេញការងារនៅស្រុកបារាយណ៍?

**2-TCW-850៖**

**ឆ៖** ពេលវេលាហ្នឹងខ្ញុំ ដែលចាំខ្លះហ្នឹងគឺ ប្រហែលជាខែ៨ ឆ្នាំ៧៨ ឆ្នាំ១៩៧៨។

**ស៖** នៅពេលដែលលោកទៅដល់ស្រុកបារាយណ៍ហ្នឹង តើលោកមានដឹងអំពីការជីកទំនប់ ឬក៏លើកទំនប់អីទេ?

**ឆ៖** បាទ ដឹង។ ដឹងពេលខ្ញុំទៅដល់ហ្នឹង ឃើញគេជីក។ ហើយបានហើយជិត៨០ភាគរយហើយ។

[១៣:៣៦:៣២]

**ស៖** លោកដឹងអ្វីខ្លះ លោកអាចនិយាយលម្អិតបន្តិចបានទេ?

**ឆ៖** បាទ ខ្ញុំដឹង ព្រោះផ្ទាល់ខ្លួនខ្ញុំក៏បានទៅរែក បានទៅជីកនៅចំណុចកន្លែងមួយគេហៅថា ភ្នំកំប៉ើយ។

**ស៖** នៅពេលណាដែរ ដែលលោកទៅជីកនៅការដ្ឋាននៅភ្នំកំប៉ើយហ្នឹង? ហើយនៅទីហ្នឹងលោកធ្វើអ្វីខ្លះ? ហើយប្រជាជនហ្នឹងលើកទំនប់ហ្នឹង គេធ្វើអ្វីខ្លះ?

**ឆ៖** ខ្ញុំទៅចូលរួមជីកជាមួយនឹងកម្លាំងប្រជាជននៅកន្លែងហ្នឹង អាច -- ហើយខ្ញុំក៏បានរែកផ្ទាល់ខ្លួនឯងជាមួយនឹងគាត់។ ព្រោះផែនការគេត្រូវធ្វើសម្រុកឲ្យហើយ ដល់អ៊ីចឹងទៅ គឺខ្ញុំក៏នៅជាប់នៅកន្លែងហ្នឹង ដើម្បីបានទឹកទៅប្រើប្រាស់។

**ស៖** លោកមានប្រសាសន៍ថា លោកនៅជាប់ហ្នឹង គឺលោកនៅរយៈពេលប្រហែលប៉ុន្មានដែរ លោកអាចបញ្ជាក់ឲ្យច្បាស់បានទេ?

**ឆ៖** បាទ ប្រហែលជាក្នុងមួយថ្ងៃហ្នឹង ខ្ញុំតែងឆៀងទៅម្តង ទៅបានរែកបីបួនដើង។ ហើយក្រៅពីហ្នឹង ចុះទៅស្រែទៅ។

**ស៖** លោកចង់និយាយថា លោកទៅរៀងរាល់ថ្ងៃ តើអ្វីដែលខ្ញុំនិយាយហ្នឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ គឺត្រឹមត្រូវដែរ។ បាទ ត្រឹមត្រូវហើយ។

[១៣:៣៨:៣១]

សៈ ចុះនៅក្នុងការជីកការដ្ឋាននៅភ្នំកំប៉ើយហ្នឹង តើមានគេរៀបចំពិធីសម្ពោធបើកការដ្ឋាន ឬក៏យ៉ាងម៉េចដែរទេ លោកអាចជម្រាបបានទេ?

ឆៈ កន្លែងហ្នឹងមិនបានសម្ពោធអីទេ គ្រាន់តែគឺផែនការហ្នឹង គឺជីកឲ្យហើយក្នុងរយៈ១ខែ ឬ២ខែ ឬ៣ខែ គេកំណត់អ៊ីចឹង។

សៈ ចុះតើមានថ្នាក់ដឹកនាំមជ្ឈិម ឬក៏ភូមិភាគណាចុះមកបើកនៅការដ្ឋានហ្នឹងដែរឬទេ នៅចុះជាប់ជាមួយនឹងលោកដែរទេ?

ឆៈ បាទ គឺមានខាងតំបន់ ភូមិភាគទៅម្តងៗ។

សៈ តើលោកអាចប្រាប់បានទេថា តើការដ្ឋានហ្នឹងជាការដ្ឋានរបស់ភូមិភាគ តំបន់ ឬក៏យ៉ាងម៉េចដែរ?

ឆៈ ការដ្ឋានហ្នឹង ជាការដ្ឋានរបស់ភូមិភាគ។

សៈ តើអ្នកណាគេអ្នកគ្រប់គ្រងការដ្ឋានហ្នឹង លោកអាចបញ្ជាក់បានឲ្យច្បាស់បានទេ?

ឆៈ ការដ្ឋានហ្នឹង គឺភូមិភាគហ្នឹងហើយមើល។ ការដ្ឋានហ្នឹងវាតភ្ជាប់ពី ហៅថាទំនប់ស្ពឺនោះ ១មកវាហ្នឹង។

សៈ អ៊ីចឹងលោកចង់និយាយថា ភូមិភាគជាអ្នកគ្រប់គ្រង អ៊ីចឹងអ្ហ៎? តើត្រឹមត្រូវ? ហើយបើភូមិភាគជាអ្នកគ្រប់គ្រង ចុះតំបន់ ហើយនិងស្រុកលោកហ្នឹង ធ្វើអីដែរ?

ឆៈ ភូមិភាគ គេដាក់មកគ្រប់គ្រង ប៉ុន្តែតំបន់ ក៏ចូលមកក្នុងហ្នឹងដែរ។ មើលតាមដាន មើលផែនការហ្នឹង ឯចុះស្រុកហ្នឹង ជាប់នៅផ្ទាល់ហ្នឹងហ្នង គេឲ្យនៅចាំមើល។

[១៣:៤០:៣៩]

សៈ តើលោកអាចប្រាប់បានទេ គណៈភូមិភាគហ្នឹងឈ្មោះអី ហើយនិងគណៈតំបន់ដែលគ្រប់គ្រងនៅការដ្ឋានហ្នឹង ឈ្មោះអីដែរ?

ឆៈ បាទ ឈ្មោះ កែ ពក ភូមិភាគ ហើយតំបន់ឈ្មោះ អឿន។

សៈ ចុះក្នុងការដឹកនាំនៅកន្លែងការដ្ឋានកំប៉ើយហ្នឹង តើមានប្រជាជនប៉ុន្មាននាក់ ចូលរួមក្នុងការលើកទំនប់នៅកន្លែងហ្នឹង លោកអាចបញ្ជាក់បានទេ?

ឆៈ ខ្ញុំគ្រាន់តែប៉ាន់ស្មាន វាប្រហាក់ប្រហែល ប្រហែលជា៣០០ ព្រោះតំបន់ភ្នំហ្នឹងវាខ្ចីដែរ។

សៈ លោកអាចគិតម្តងទៀតមើល ៣០០ ឬក៏ច្រើនជាងហ្នឹង?

**ធ៖** ព្រោះនៅសល់បន្តិច ដូចខ្ញុំថាអ៊ីចឹង វាបង្អើយផែនការហ្នឹង។

**ស៖** លោកសាក្សី មានឯកសារមួយដែលជាកិច្ចសម្ភាសន៍របស់លោក ជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា គឺឯកសារលេខ E3/9149។ ឯកសារហ្នឹង មាន ERN ជាភាសាអង់គ្លេស 01116150, ជាភាសាខ្មែរ 00731248 ដល់49, ជាភាសាបារាំង 01101034 ដល់35។ នៅក្នុងហ្នឹងលោកបាននិយាយថា គេសួរលោកថា៖ "ចុះទៅតាមការដ្ឋានទេ? លោកឆ្លើយថា៖ បាទ ដូចជាការដ្ឋានជីកប្រឡាយនៅកន្លែងកំប៉ើយ នៅបារាយណ៍ឯណោះ ដូចជាកងចល័តនេះ រាប់ម៉ឺន ខ្ញុំចុះទៅជាប់។ ពេលឃើញក្មេងៗ វានឹកផ្ទះសម្បែង និងម៉ែឪ ខ្ញុំតែងតែកំណត់ថា ខ្ញុំថាឥឡូវ យើងយ៉ាងយូរ១០ថ្ងៃ ឲ្យទៅលេងផ្ទះ។" តើលោកឆ្លើយតបយ៉ាងម៉េចដែរ ចំពោះចម្លើយដែលលោកបានឆ្លើយនៅជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា កាលឆ្នាំ២០០៨ហ្នឹង?

[១៣:៤៣:១០]

**ធ៖** បាទ មុននឹងបន្តិចគឺមានច្រើន ដែលនៅសល់ សេសសល់ហ្នឹង ដូចខ្ញុំបានបញ្ជាក់អ៊ីចឹងមានតែ៣០០ ហើយខ្ញុំនឹកគិតថា ទៅផ្ទះ ទៅលេងស្រុក គាត់ទៅជួបនឹងម៉ែឪ បងប្អូនទៅ គឺកូនក្មួយខ្ញុំតែងតែគេយកទៅការដ្ឋានអស់។ ដល់អ៊ីចឹងខ្ញុំនឹកឃើញថា ខ្ញុំត្រូវធ្វើយ៉ាងម៉េច គឺត្រូវតែមានពេលវេលាឬក៏បើកឱកាសឲ្យកងចល័ត ឬបងប្អូនដែលនឹកផ្ទះសម្បែងហ្នឹង--

**ស៖** អរគុណលោក អរគុណ។ លោកឆ្លើយខ្លីៗទៅបានហើយ។

**ធ៖** បាទ។

**ស៖** មុននេះ លោកបានមានប្រសាសន៍ថា មុននេះបន្តិច គឺមានច្រើន។ តើមុនបន្តិចដែលលោកមានប្រសាសន៍ហ្នឹង ពេលណា? ហើយច្រើនហ្នឹង មានប្រហែលជាប៉ុន្មាននាក់ដែរ?

**ធ៖** ច្រើនហ្នឹង វាគឺចូល ប្រហែលជាប្រាំប្រាំមួយពាន់ដែរ នៅមួយកំណាត់ហ្នឹង។

**ស៖** អាចដល់ម៉ឺននាក់ដែរទេ លោក? រាប់ម៉ឺននាក់ដែរទេ?

**ធ៖** អ្ហឺ! បើប៉ាន់ប្រមាណទំនប់ បើពីដំបូង តាមខ្ញុំស្មាន គឺអាចចូលដល់ម៉ឺន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមជម្រាបសួរទៅមេធាវីដើមបណ្តឹងរដ្ឋប្បវេណី តើលោកមានសំណួរទេ លើសាក្សីរូបនេះ?

[១៣:៤៥:០០]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន ខ្ញុំអត់មានសំណួរទេលោកប្រធាន។ សូមជូនពេលវេលាជូនសហព្រះរាជអាជ្ញា។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ សូមអញ្ជើញលោកព្រះរាជអាជ្ញាបន្ត!

**លោក សេង លាង៖**

ប្រហែលប៉ុន្មានទៀតដែរលោកប្រធាន?

**ប្រធានអង្គជំនុំ៖**

លោកនៅ១០នាទីទៀត។

**លោក សេង លាង៖**

បាទ អរគុណលោកប្រធាន។

**សួរដោយលោក សេង លាង៖**

**ស៖** លោកអំមិញមានប្រសាសន៍ថា លោកតែងតែមានប្រសាសន៍ថា មុននេះបន្តិច មុននេះបន្តិច ប៉ុន្តែបើតាមឯកសារដែលខ្ញុំអានជូនលោកហ្នឹង គឺពេលដែលលោកចុះជាប់ហ្នឹង នៅក្នុងឯកសារហ្នឹងគឺលោកបាននិយាយហើយ មានរាប់ម៉ឺននាក់ឯណោះ។ អ៊ីចឹងមុននេះបន្តិចហ្នឹង លោកចង់មានប្រសាសន៍ថា យ៉ាងម៉េចវិញ?

[១៣:៤៥:៤៨]

2-TCW 850៖

**ឆ៖** មុននឹងខ្ញុំចង់និយាយថា មុនមួយខែពីរខែ មុនដែលនៅការដ្ឋាន ដែលនៅតូចហើយខ្លីហ្នឹង។

**ស៖** នៅក្នុងការលើកទំនប់នៅកំប៉ើយហ្នឹង សួរថាតើខាងឃុំរបស់លោកហ្នឹង លោកដាក់ផែនការ យ៉ាងម៉េចទៅឲ្យថ្នាក់ក្រោមរបស់លោក ក្នុងការធ្វើការងារហ្នឹង?

**ឆ៖** ធ្វើផែនការហ្នឹងខាងតំបន់ ខាងភាគហ្នឹងកំណត់ដូចជាកំណត់ខែ ពីពីរខែទៅបីខែ។

**ស៖** តើលោកប្រជុំដាក់ផែនការយ៉ាងម៉េចដែរ? ហើយក្នុងហ្នឹងមានកំណត់ទេ ថាតើលម្អិតដល់ថាតើនៅក្នុងហ្នឹងម្នាក់ត្រូវជីកប៉ុន្មានម៉ែត្រគូប ឬក៏ត្រូវធ្វើការថ្ងៃយប់អីយ៉ាងម៉េច លោកមាននិយាយដែរទេ?

**ឆ៖** បាទ មាននិយាយហើយ ក៏បានកំណត់គ្នាពិគ្រោះគ្នាក្នុងសហករណ៍មួយៗនោះ កំណត់ថាយើងត្រូវផែនការពីលើមក កំណត់ថា៣ខែ តើយើងរៀបចំយ៉ាងម៉េច។ ក្នុងនោះគឺចែកតាមកង តាមក្រុម ប៉ុន្មានម៉ែត្រៗអ៊ីចឹង ត្រូវបង្ហើយ។

**ស៖** អ៊ីចឹងនៅពេលដែលបំពេញការងាររួច តើខាងកងខាងក្រុមហ្នឹងរាយការណ៍ទៅណាវិញដែរ រាយការណ៍ទៅលោកវិញ ឬក៏រាយការណ៍ទៅយ៉ាងណាដែរ?

**ឆ៖** ខាងក្រុមខាងកងហ្នឹងឡើងចុះពិនិត្យជាក់ស្តែងទៅ គេរាយការណ៍មក ៗខ្ញុំ ហើយខ្ញុំបន្តទៅទៀត។

**ស៖** តើមានកងណាដែលអត់ធ្វើតាម ឆ្លើយតបខាងផែនការដែលលោកដាក់ឲ្យដែរឬទេ?

**ឆ៖** បាទ គឺអត់ទេ។

[១៣:៤៧:៥៩]

**ស៖** ចុះនៅក្នុងការលើកទំនប់ហ្នឹង ថាខាងលោកបានផ្តល់ឧបករណ៍អ្វីខ្លះដល់កម្មករដែលលើកទំនប់ហ្នឹង? តើគេធ្វើដោយគ្រឿងម៉ាស៊ីន ឬក៏ធ្វើដោយដៃ?

**ឆ៖** បាទ ធ្វើដោយដៃ បាទធ្វើដោយដៃ ហើយនិងមានរំសេវ ហៅថារំសេវ យកទៅបំផ្ទុះបំបែកថ្មហ្នឹង។

**ស៖** តើនៅក្នុងការធ្វើការងារហ្នឹង តើមានពេលណាមួយដែលកម្មករត្រូវធ្វើការនៅយប់ដែរទេ?

**ឆ៖** ដូចអត់មានទេ បាទអត់មានទេ។

**ស៖** ចុះការស្នាក់នៅរបស់គេយ៉ាងម៉េចដែរ លោកអាចប្រាប់បានទេ អំពីការស្នាក់នៅ?

**ឆ៖** ការស្នាក់នៅរបស់កម្លាំងហ្នឹង គឺមានតង់ មានរោងនៅសងខាង។

**ស៖** តើមានរោងគ្រប់គ្រាន់ដែរឬទេ? ឬក៏មានអ្នកខ្លះអត់មានរោងដេក ហើយដេកនៅហាលសន្សើម?

**ឆ៖** បាទ គឺអត់មានទេ គឺសុទ្ធតែរោង ប៉ុន្តែវាដឹងស្រាប់ហើយ ពេលនោះវាមិនអាចគ្រប់គ្រាន់ទាំង១០០ភាគរយទេ។

**ស៖** តើលោកអាចប្រាប់បានទេ ថាតើនៅកន្លែងការដ្ឋានលើកទំនប់ហ្នឹងមានកុមារ និងនារីដែលធ្វើការនៅទីនោះដែរទេ?

**ឆ៖** បាទ មានតែកងចល័ត មិត្តនារី យុវជន។

[១៣:៥០:០១]

**ប្រធានអង្គជំនុំ៖**

លោកព្រះរាជអាជ្ញា លោកអស់ពេលហើយ។

**សួរដោយលោក សេង លាង៖**

បាទ អរគុណលោកប្រធាន។ ខ្ញុំសុំមួយសំណួរទៀតទេ។

**ស៖** តើលោកសាក្សីអាចប្រាប់បានទេថា ការដ្ឋានហ្នឹងគេបញ្ចប់នៅពេលណា? ហើយនៅពេលដែលគេបញ្ចប់ហ្នឹង អ្នកណាគេមកបិទការដ្ឋានហ្នឹង? ខ្ញុំសំដៅលើថ្នាក់ដឹកនាំមជ្ឈិម ឬក៏ថ្នាក់ដឹកនាំភូមិភាគ។

**2-TCW-850៖**

**ឆ៖** ការដ្ឋានហ្នឹង គឺបង្ហើយក្រោយគេ ក្រោយគេ បិទបញ្ចប់ការដ្ឋានហ្នឹង គេបិទមុនៗអាកន្លែងចំណុចដែលខ្ញុំធ្វើហ្នឹង។

**ស៖** ចង់សុំឲ្យលោកជួយបញ្ជាក់ថា តើមានថ្នាក់ដឹកនាំណាមកបិទការដ្ឋានហ្នឹងដែរឬទេ?

**ឆ៖** បាទ មេភូមិភាគ។

**ស៖** លោកសំដៅលោក កែ ពក ហ្នឹងឬក៏អ្នកណា?

**ឆ៖** បាទៗ លោក កែ ពក។

**លោក សេង លាង៖**

បាទ លោកប្រធាន ខ្ញុំសូមអស់សំណួរ។

[១៣:៥១:០២]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអរគុណលោកព្រះរាជអាជ្ញា។ ជាបន្តសូមអញ្ជើញលោកមេធាវីការពារក្ដីលោក នួន ជា មានសំណួរទៅសាក្សីរូបនេះ។

**លោកស្រី ដូរីន ជិន៖**

សួស្ដីលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ភាគីទាំងអស់ និងលោកសាក្សី។ ខ្ញុំនឹងសួរសំណួរលោកមួយចំនួនតាំងនាមឲ្យលោក នួន ជា។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោកស្រី ដូរីន ជិន៖**

**ស៖** ខ្ញុំសូមពន្យល់លោកសិន ខ្ញុំនឹងលើកឡើងនូវអ្វីដែលលោកបានពិភាក្សាជាមួយនឹងសហព្រះរាជអាជ្ញាកាលពីព្រឹកមិញ។ <ប៉ុន្តែខ្ញុំនឹងសួរពីជ្រុងម្ខាងទៀត។> ដើម្បីចាប់ផ្តើម ខ្ញុំសូមសួរតពីសំណួរចុងក្រោយដែលសហព្រះរាជអាជ្ញាបានសួរ មុនពេលសម្រាកអាហារថ្ងៃត្រង់។ តាម<ដែលលោកអាច>ចាំ<>បាន <គាត់>សួរលោក<អំពី> ថាតើ<គេធ្លាប់ស្នើឲ្យ>លោក<>ស៊ើបអង្កេតអ្នកដែលគេហុចឈ្មោះឲ្យនោះដែរឬទេ? ហើយគោលនយោបាយនោះ គឺគេលើកឡើងយ៉ាងម៉េចដែរ? ខ្ញុំសូមសួរសំណួរដូចតទៅ។ អ្វីដែលខ្ញុំចង់សួរ ខ្ញុំនឹងអាននូវចម្លើយរបស់លោក ដែលលោកឆ្លើយប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយចម្លើយនោះគឺលោកបានពិភាក្សាព្រឹកមិញច្រើនណាស់ជាមួយនឹងសហព្រះរាជអាជ្ញា។ លោកប្រធាន គឺឯកសារ E3/9149 ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨ ERN គឺអង់គ្លេសគឺ 01116147, ខ្មែរគឺ 00731244 ទៅដល់45, ហើយបារាំង 01101031។

[១៣:៥២:៤៨]

លោកសាក្សី នេះជាចំណុចដកស្រង់ដែលខ្ញុំសូមអានជូនលោកស្តាប់ សូមដកស្រង់៖ “និយាយឲ្យត្រង់ទៅ ខ្ញុំមិនដែលទៅរាយការណ៍ <អំពីប្រវត្តិរបស់បុគ្គលណាម្នាក់ទេ។ វាមិនមែនជា>ជំហារ<របស់>ខ្ញុំ<ឡើយ>។ <>ហើយចំណុចខាងក្រោម លោកបានលើកឡើងទៀតថា៖ “ខ្ញុំមិនដឹងប្រវត្តិប្រជាជនទាំងអស់ ឬក៏សាច់ញាតិរបស់គាត់នៅក្នុងភូមិនោះទេ។ ដូច្នេះខ្ញុំប្រាប់អនុរបស់ខ្ញុំ ហើយនិងសមាជិកនៅក្នុងហ្នឹងថា ថ្នាក់លើចាត់តាំងឲ្យខ្ញុំតាមដានសកម្មភាពរបស់អ្នកដែលប្រឆាំងនឹងបក្សនៅក្នុងពេលនោះ។” បញ្ចប់ការដកស្រង់។

ខ្ញុំសូមសួរសំណួរដូចតទៅ លោកសាក្សី។ តាមខ្ញុំយល់ លោកមិនបានរាយការណ៍ប្រវត្តិរបស់បុគ្គលម្នាក់ៗ<ទេ>។ <ប៉ុន្តែ>លោក<>បានទទួលការណែនាំឲ្យតាមដាន<សកម្មភាពប្រឆាំងនឹងបក្ស>។ តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវដែរឬទេ?

**2-TCW-850៖**

**ឆ៖** ខ្ញុំ តាមគំនិតខ្ញុំ ខ្ញុំយល់ថា គឺត្រឹមត្រូវ ព្រោះខ្ញុំអត់ស្គាល់គេទេ ដូចខ្ញុំបានបញ្ជាក់ពីព្រឹក។

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំគួរតែនិយាយខាងដើម។ លោកបានឆ្លើយប្រាប់បញ្ជាក់មជ្ឈមណ្ឌលឯកសារកម្ពុជាអំពីពេលវេលាដែលនៅបារាយណ៍ ស្រុកបារាយណ៍។ ខ្ញុំចង់សួរទៀតថា តើ

01351233



លេខាស្រុក ឬក៏កម្មាភិបាលផ្សេងទៀត គាត់ធ្វើដូចលោក បានន័យថា តាមដានតែទៅលើសកម្មភាពរបស់បុគ្គលទាំងអស់នោះតែប៉ុណ្ណោះ មិនបានតាមដានទៅលើប្រវត្តិរូបរបស់បុគ្គលម្នាក់ៗនោះឡើយ តើអ្នកទាំងអស់នោះធ្វើអ៊ីចឹងដូចលោកដែរឬទេ?

[១៣:៥៥:១០]

**ឆ៖** បាទ ខ្ញុំក្លាប់អត់បានទេចំណុចនេះ ព្រោះចិត្តដោយខ្លួន ហើយការយល់ដោយខ្លួន។

**ស៖** មិនជាថ្វីនោះទេ លោកសាក្សី។ យើងពិភាក្សាអំពីពាក្យថា "សកម្មភាព" វិញម្តង។ គឺលោកបានពិភាក្សា និងលើកពន្យល់លម្អិតនៅក្នុងចម្លើយរបស់លោកពីមុនៗ។ តាមលោកយល់ តើមានសកម្មភាពអ្វីខ្លះដែលចាត់ទុកថា ជាសកម្មភាពប្រឆាំងនឹងបក្ស?

**ឆ៖** សកម្មភាពដែលប្រឆាំងនឹងបក្សជំនាន់នោះ ឃើញថាអ្នកដែលដុតបំផ្លាញស្រូវ ឬក៏យកថ្នាំបំពុលទៅដាក់នៅឆ្នាំងបាយរួម។

**ស៖** សូមអរគុណលោកសាក្សី។ វាពាក់ព័ន្ធទៅនឹងចំណុចខាងបន្ទាប់ដែលខ្ញុំចង់សួរលោក។ លោកបានលើកឡើងអំពីសកម្មភាពស្រដៀងគ្នានេះដែរ នៅក្នុងកំណត់ហេតុដែលលោកបានឆ្លើយប្រាប់អ្នកស៊ើបអង្កេតរបស់តុលាការនេះនៅថ្ងៃទី១៤ ខែ<កក្កដា> ឆ្នាំ២០០៩។ <ទោះបីជា>លោក<ទើបតែ>បាន<ពិភាក្សាលើបញ្ហានោះ>អម្បាញ់មិញ<ក៏ដោយ ក៏ខ្ញុំនឹងប្រើ>នូវអ្វីលោកដែលឆ្លើយប្រាប់អ្នកស៊ើបអង្កេត <ព្រោះនៅក្នុងចម្លើយនោះ>លោកបញ្ជាក់លម្អិត<ជាង>។ លោកប្រធានគឺឯកសារ E3/5293 ដូចដែលខ្ញុំលើកឡើងអ៊ីចឹង ជាកំណត់ហេតុស្តាប់ចម្លើយរបស់ចៅក្រមស៊ើបអង្កេត ឯកសារនេះមានលើកឡើងត្រង់ ERN អង់គ្លេស 00351705 ទៅដល់ 06, ខ្មែរគឺត្រង់ទំព័រ ERN 00348845 ហើយបារាំងគឺត្រង់ទំព័រ 00367752។

[១៣:៥៧:២៤]

លោកសាក្សីនេះ គឺអ្វីដែលលោកបានឆ្លើយប្រាប់ចៅក្រមស៊ើបអង្កេត។ សំណួរ ខ្ញុំសូមដកស្រង់៖ "តើជាកាតព្វកិច្ចរបស់សហករណ៍ដែលត្រូវរាយការណ៍អំពីបញ្ហាសន្តិសុខទៅថ្នាក់លើ ឬក៏យ៉ាងម៉េច? ចម្លើយ៖ មានការរាយការណ៍ ដូចជាការទាក់ទងនឹងការដាក់ថ្នាំបំពុលក្នុងអាហារ។" ហើយ<>ខាងក្រោម<ចៅក្រមអង្កេតបានសួរ>ថា៖ "តើមាននរណាធ្លាប់ប្រព្រឹត្តខុសនឹងនយោបាយរបស់អង្គការដែរឬទេ? ចម្លើយ៖ មិនដែលមានទេ ប៉ុន្តែគ្រាន់តែមានអ្នកដែលប្រព្រឹត្តខុសបន្តិចបន្តួច ដូចជាមកធ្វើការយឺតម៉ោង ហើយក៏ត្រូវបានគេណែនាំ។ ពេលនោះគេហៅ ទិតៀន, ស្វ័យទិតៀន កំហុសទាំងនេះមិនរាយ-

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ការណ៍មកថ្នាក់ស្រុកទេ។" ហើយខាងក្រោមទៀត អ្នកស៊ើបអង្កេតបានសួរលោកបន្តទៀតថា៖ "សំណួរ ៖ តើកំហុសប៉ុនណាទើបគេបញ្ជូនមកខាងស្រុក? ចម្លើយ៖ គឺកំហុសធំៗ ដូចជាការដុតបំផ្លាញស្រូវ។ សំណួរ៖ ចំពោះអ្នកដែលមានកំហុសធ្ងន់ធ្ងរ តើគេយកទៅណា? ចម្លើយរបស់លោកឆ្លើយនៅពេលនោះថា៖ គេយកទៅអប់រំនៅឃុំពីរបីថ្ងៃ។" បញ្ចប់ការដកស្រង់។

លោកសាក្សី តាមខ្ញុំយល់ចម្លើយរបស់លោកនៅក្នុងកំណត់ហេតុនេះ គឺមានទោស ឬក៏កំហុសពីរដែលលោកបានលើកឡើង គឺលោកបានលើកឡើងអំពីទោសស្រាល និងទោសធ្ងន់ កំហុសស្រាល និងកំហុសធ្ងន់។ តើលោកយល់យ៉ាងម៉េចអ្វីដែលខ្ញុំនិយាយថា លោកលើកឡើងកំហុសនោះមានពីរ កំហុសធ្ងន់ និងកំហុសស្រាលនោះ តើត្រឹមត្រូវដែរឬទេ បើសិនជាខ្ញុំលើកដូច្នេះ?

**ឆ៖** បាទ គឺត្រឹមត្រូវហើយ។

**ស៖** សូមអរគុណលោកសាក្សី។ នៅពេលនេះយើងផ្តោតទៅលើប្រភេទកំហុសទី១ គឺកំហុសស្រាល។ តើខ្ញុំយល់ត្រឹមត្រូវផងដែរឬទេថា តាមអ្វីដែលលោកយល់ ការដាក់ទោសចំពោះកំហុសស្រាលនោះ គឺគ្រាន់តែទិតៀន ឬក៏ស្ស័យទិតៀនតែប៉ុណ្ណោះ គឺមិនតម្រូវឲ្យរាយការណ៍ទៅថ្នាក់ស្រុកនោះឡើយ?

[១៤:០០:០៧]

**ឆ៖** បាទ ព្រោះកំហុសនេះគឺយើងអាចអប់រំ ឬក៏កសាងគ្នានៅត្រឹមឃុំ ត្រឹមសហករណ៍ហ្នឹង។

**ស៖** សូមអរគុណ។ ខ្ញុំលើកឡើងសួរលោកអំពីកំហុសស្រាលនេះដដែល។ តើខ្ញុំយល់ត្រឹមត្រូវដែរឬទេថា កំហុសស្រាលរួមមាន ឧទាហរណ៍ សកម្មភាពដូចជាមកធ្វើការយឺត ជាដើម?

**ឆ៖** បាទ កំហុសនេះស្រាលហើយ មកការងារ មកវាយឺតយ៉ាវ។

**ស៖** លោកសាក្សី តើលោកអាចលើកជាឧទាហរណ៍សកម្មភាពណាខ្លះដែលចាត់ទុកថាជាកំហុសស្រាលបានដែរឬទេ?

**ឆ៖** បាទ កំហុសស្រាលគឺខ្ញុំបានបញ្ជាក់ក្នុងហ្នឹង សំណួរអ៊ីចឹងគឺមកយឺតម៉ោង ខុសពេលវេលាមកមិនទាន់គេ។

**ស៖** លោកសាក្សី ឥឡូវនេះខ្ញុំនិយាយអំពីព្រឹត្តិការណ៍ទី២ ដែលលោកបានរៀបរាប់។ លោកថា គឺជាការប្រព្រឹត្តខុសធ្ងន់ធ្ងរ។ សំណួរទី១ ខ្ញុំសួរថា បើខ្ញុំយល់មិនច្រឡំទេតាមសម្តីរបស់លោក ការដាក់ទណ្ឌកម្មសម្រាប់កំហុសទាំងអស់នេះ គឺត្រូវតែរាយការណ៍មកថ្នាក់ស្រុក ហើយបន្ទាប់មកគឺថាអាចបញ្ជូនទៅធ្វើការអប់រំកែប្រែនៅថ្នាក់ឃុំនេះ គឺថាពីរទៅបី<ថ្ងៃ> អ៊ីចឹងមែនទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01351235



**ឆ៖** បាទ អ៊ីចឹងមែន។

[១៤:០២:១៨]

**ស៖** សំណួរដូចគ្នានេះដែរ បើខ្ញុំយល់មិនច្រឡំទេគឺថា នៅពេលណាមានការប្រព្រឹត្តកំហុសធ្ងន់ធ្ងរ គឺថាប្រភេទបទល្មើសទាំងអស់នេះ ដែលលោកឆ្លើយថា ដូចជាបំពុលចំណីអាហារ ឬក៏<ដុតស្រូវ> អីជាដើមនេះ តើយ៉ាងម៉េចដែរ?

**ឆ៖** បាទ កំហុសនេះគឺហ្នឹងជាការកំណត់ ហើយនៅកន្លែងខ្ញុំធ្វើការហ្នឹងគឺអត់ដែលមាន អត់ដែលមានបំផ្លាញ ឬក៏បំពុលអីទេ ប៉ុន្តែជាទោសកំហុសហ្នឹងគឺមាន បើមានអ៊ីចឹង គេណែនាំអ៊ីចឹង។

**ស៖** ខ្ញុំយល់ហើយត្រង់ចំណុចនេះ ខ្ញុំបន្តទៅមុខទៅទៀតចុះ។ សំណួរចុងក្រោយពាក់ព័ន្ធទៅនឹងបទល្មើសទាំងនេះ <ទោះបីជាវាមិនបានកើតឡើងនៅកន្លែងលោកក៏ដោយ> តើលោកអាចជម្រាបជូនតុលាការបានទេ ឬក៏លើកជាឧទាហរណ៍ពីសកម្មភាពណាមួយបានទេ ដែលត្រូវបានចាត់ទុកថាជាអំពើ ឬក៏ជាកំហុសធ្ងន់ធ្ងរនោះ?

**ឆ៖** បាទ គឺខ្ញុំមិនអាចឆ្លើយបានទេ ព្រោះការកើតមាននេះ គឺសូមបញ្ជាក់អ៊ីចឹង។

**ស៖** មិនថ្វីទេលោកសាក្សី។ ឥឡូវនេះខ្ញុំអានសម្រង់មួយទៀតឲ្យលោកស្ដាប់ពីកិច្ចសម្ភាសន៍ស្ដាប់ចម្លើយរបស់លោក។ ដូច្នេះយើងអាចពិភាក្សាគ្នាបានលម្អិតបន្តិច ពាក់ព័ន្ធទៅនឹងការបំពុលចំណីអាហារ។ លោកប្រធាន នេះគឺជាកំណត់ហេតុស្ដាប់ចម្លើយ ឯកសារ E3/5293 ចុះថ្ងៃទី១៤ កក្កដា ២០០៩ ERN ដែលខ្ញុំនឹងផ្ដល់ជូននោះគឺ អង់គ្លេស 00351705, ខ្មែរ 00348845 និងបារាំង 00367752។ លោកសាក្សី នេះជាសម្រង់ សូមដកស្រង់ ហើយសំណួរពីសហចៅក្រមស៊ើបអង្កេត គឺដូចតទៅនេះ៖ “តើវាជាតួនាទីរបស់សហករណ៍ដែលត្រូវរាយការណ៍អំពីបញ្ហាសន្តិសុខជូនទៅថ្នាក់លើឬ? លោកឆ្លើយ សូមដកស្រង់៖ “បាទ គឺអ៊ីចឹងហើយ វាពាក់ព័ន្ធទៅនឹងការបំពុលនៅក្នុងចំណីអាហារជាដើម។ ហើយជាការពិតនោះគឺថាមិនមានករណីបែបនេះកើតឡើងនោះទេ ក៏ប៉ុន្តែវាជាការប្រុងប្រយ័ត្នជាមុន។ សួរ៖តើធ្លាប់មានព្រឹត្តិការណ៍ណាមួយពាក់ព័ន្ធទៅនឹងការបំពុលក្នុងចំណីអាហារទេ? ឆ្លើយ៖ អត់មានទេ ប៉ុន្តែវាអាចមាននៅតំបន់ផ្សេងទៀត គឺថាថ្នាក់តំបន់ ជាកម្រិតមួយដែលកំណត់ថាផែនការនេះឡើង។”

លោកសាក្សីសំណួរពីរបី ពាក់ព័ន្ធទៅនឹងសម្រង់ទាំងនេះ។ ទី១ តើលោកយល់ស្របជាមួយចម្លើយមុនៗរបស់គាត់ឬទេ ដែលថាថ្នាក់តំបន់ទេដែលជាអ្នករៀបចំផែនការពាក់ព័ន្ធទៅនឹងការ<>រាយការណ៍ទៅថ្នាក់លើ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្សែបកប្រែ និងខ្សែបកប្រែបន្ត។*

**ឆ៖** បាទ យល់ស្រប ដែលចម្លើយខ្ញុំលើកមុន។

**ស៖** តើលោកចាំបានផងដែរឬទេ នៅថ្នាក់តំបន់ហ្នឹង អ្នកណាគេហ្នឹងនៅថ្នាក់តំបន់ដែលជាអ្នកកំណត់ផែនការនេះឡើង?

[១៤:០៦:០៦]

**ឆ៖** ឈ្មោះដូចខ្ញុំបានជម្រាបខាងលើអ៊ីចឹងមាន លោក អឿនៗ ឈ្មោះ អឿន។

**ស៖** ខ្ញុំយល់ហើយ។ លោកថាព្រឹត្តិការណ៍បែបនេះ ពាក់ព័ន្ធទៅនឹងការបំពុលក្នុងចំណីអាហារការដុតវាលស្រែចោលជាដើមនេះ គឺថាមិនបានកើតឡើងនៅទីកន្លែងរបស់លោកទេ។ ក៏ប៉ុន្តែលោកដឹងទេ ថានេះរឿងរាវបែបហ្នឹងមានកើតឡើងនៅកន្លែងផ្សេងទៀត នៅស្រុកផ្សេងទៀត ឬនៅតំបន់ផ្សេងទៀតដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់ដឹងទេ ស្រុកផ្សេង តំបន់ផ្សេង។

**ស៖** មិនជាអ្វីទេលោកសាក្សី។ <ទាំងអស់នោះជា>សំណួរ<>ដែលខ្ញុំចង់សួរលោក<> ពាក់ព័ន្ធទៅនឹងសកម្មភាពទាំងអស់នេះ ក៏ប៉ុន្តែខ្ញុំចូលប្រធានបទមួយថ្មីសិនចុះ។ ពីខាងដើមនោះសហព្រះរាជអាជ្ញាអន្តរជាតិបានសួរលោក សំណួរមួយចំនួនពាក់ព័ន្ធទៅនឹងគោលនយោបាយពាក់ព័ន្ធទៅនឹងខ្មាំង។ ឥឡូវខ្ញុំសូមសួរលោកអំពីអង្គប្រជុំមួយ ដែលលោករៀបរាប់នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកដែលមិនទាន់បានលើកយកមកសួរនៅឡើយទេ<នៅថ្ងៃនេះ>។ តើលោកនៅនឹកឃើញទេ ថាលោកបានចូលរួមអង្គប្រជុំមួយនៅបារាយណ៍ ដែល<អនុ>លេខាស្រុករបស់លោកបានប្រកាសថា ប្រជាជនប្រភេទណាដែលត្រូវចាត់ទុកជាខ្មាំងនោះ។ លោកនៅនឹកឃើញទេ?

**ឆ៖** បាទ រកនឹកអត់ឃើញទេ។

[១៤:០៧:៥២]

**ស៖** លោកប្រធាន ខ្ញុំសូមការអនុញ្ញាតអានសម្រង់ចេញពីមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីជួយរំឭកដល់ការចងចាំដល់សាក្សី។ ឯកសារខ្ញុំសូមអាននេះគឺ E3/9149, ERN គឺអង់គ្លេស 01116151, ខ្មែរ 00731250 និងបារាំង 01101036។ លោកសាក្សី ដូចខ្ញុំពន្យល់លោកអំម្បាញ់មិញហើយថានេះគឺជាសម្រង់ចេញពីចម្លើយរបស់លោក ឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា។ នេះគឺជាសម្រង់នៃសម្តីរបស់លោក សូមដកស្រង់៖ "អនុលេខាស្រុកបារាយណ៍របស់ខ្ញុំ បានធ្វើប្រកាសជាសាធារណៈថាប្រជាជនដែលធ្វើឲ្យបាក់ផាល ឬក៏ខូចរទេះគោហ្នឹង គឺត្រូវចាត់ទុកថាជាខ្មាំង។ អ្នកដែលខ្ជិលមិនទៅធ្វើ

ការហ្នឹង ក៏ត្រូវចាត់ទុកជាខ្មាំងដែរ។” បញ្ចប់ការដកស្រង់។ លោកសាក្សី តើចំណុចទាំងនេះវារំឭកដល់ការឲ្យលោកនឹកឃើញពីកិច្ចប្រជុំនៅស្រុកបារាយណ៍ដែលអនុលេខាស្រុករបស់លោកប្រកាសថា នេះប្រជាជនដែលប្រព្រឹត្តកំហុសបែបហ្នឹង ត្រូវចាត់ទុកថាជាខ្មាំង លោកនឹកឃើញទេ?

**ឆ៖** បាទ ខ្ញុំនឹកឃើញ គឺលោកអនុហ្នឹង គឺឈ្មោះ ទិន។ បាននិយាយអ៊ីចឹងពិតមែន។

**ស៖** លោកសាក្សី<តើ>លោកនៅចាំ<ថា>លោក<>មានប្រតិកម្មយ៉ាងម៉េចចំពោះការប្រកាសចេញពីអនុលេខាស្រុកនេះ?

**ឆ៖** គឺក្រោយពីប្រកាសអ៊ីចឹង គឺប្រជាជន គាត់ភ័យ គាត់ព្រួយ ដល់ក្រោយខ្ញុំបានទៅប្រជុំប្រាប់ប្រកាសប្រាប់ប្រជាជនវិញ។

**ស៖** សូមអរគុណលោកសាក្សី។ ចុះលោកនៅចាំទេ លោកប្រកាសថាម៉េចដែរ?

**ឆ៖** ប្រកាសដូចព័ត៌មានដែលនិយាយអំមិញហ្នឹង គេទៅប្រជុំ គេលើកឡើងថា ដូចពាក្យអម្បាញ់មិញអ៊ីចឹង បែកផាល បាក់នង្គ័ល។

[១៤:១០:៥៧]

**ស៖** លោកសាក្សី ខ្ញុំខ្លាចតែខ្ញុំយល់ចម្លើយលោកមិនច្បាស់ទេ។ ដើម្បីជួយដល់លោក ខ្ញុំសូមអានសម្រង់ដែលលោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជាបន្ថែមទៅទៀត ពាក់ព័ន្ធទៅនឹងភាពលម្អិតនៃសេចក្ដីប្រកាសរបស់លោក។ លោកប្រធាន យើងខ្ញុំសូមការអនុញ្ញាតឯកសារ E3/9149 ដដែល ERN ដូចចុងក្រោយដែរ សូមផ្ដល់ឡើងវិញគឺ 01116151 ហ្នឹងជាអង់គ្លេស, 00731250 ជាខ្មែរ និងជាបារាំង 01101036។ លោកសាក្សី នេះគឺជាអ្វីដែលលោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា។ សូមដកស្រង់៖ “ខ្ញុំមិនអាចយល់ស្របចំពោះការប្រកាសនេះទេ ខ្ញុំហៅប្រជាជននៅទូទាំងឃុំមកប្រជុំ។ មានប្រជាជនប្រហែលមកចូលរួមប្រជុំពី៥០០ទៅ៦០០នាក់។ <ខ្ញុំបាននិយាយ>ថា រឿងហេតុដែលប្រជាជនលួចដំឡូង និងស្រូវអង្ករ ដោយសារពួកគាត់ឃ្លាន។ ហើយពួកគាត់<ឃ្លាន> ដោយសារយើងមិនអាចផ្ដល់ម្ហូបអាហារគ្រប់គ្រាន់។ <វាមិនត្រឹមត្រូវទេក្នុងការ>ចោទប្រជាជនថាជាខ្មាំង <ដោយគ្រាន់តែ>ធ្វើឲ្យបាក់នង្គ័លជាដើម។” លោកសាក្សី តើចំណុចនេះ វាជួយរំឭកដល់ការចងចាំរបស់លោកទេ ដែលលោកប្រកាសនៅក្នុងអង្គប្រជុំពេលក្រោយមកទៀត ប្រាប់ទៅប្រជាជននោះ?

**ឆ៖** បាទ ខ្ញុំបានចាំខ្លះហើយ។ ខ្ញុំបានប្រជុំមែន នៅប្រជាជននៅឃុំចើងដើង។

**ស៖** ចម្លើយរបស់លោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា លោកថា លោកមិនមែនត្រឹមតែ

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ចូលរួមក្នុងអង្គប្រជុំបែបនេះទេ គឺលោកធ្វើការប្រកាសផងថាលោកនឹងមិនឃោគយល់ចំពោះអ្វីដែលអនុលេខាស្រុករបស់លោកបាន<ឲ្យនិយមន័យអំពីខ្លាំង>នោះទេ។ តើវាជួយដល់លោកនឹកឃើញទេ?

**ឆ៖** បាទ ដូចខ្ញុំបញ្ជាក់អ៊ីចឹងខ្ញុំនឹកឃើញបញ្ហាហ្នឹង ព្រឹត្តិការណ៍ហ្នឹង ក៏ខ្ញុំបានចាប់ផ្ដើមប្រជុំប្រាប់ ប្រកាសដល់ប្រជាជន។

[១៤:១៣:២៤]

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះយើងយល់គ្នាបានហើយ។ ក្រោយពីពេលលោកប្រកាសពីរឿងនេះហើយ តើលោកមានទទួលការដាក់ទណ្ឌកម្មទេ គេដាក់ទណ្ឌកម្មលោកទេ?

**ឆ៖** បាទ អត់ទេ អត់មានដាក់ទេ។

**ស៖** ហេតុអ្វីបានគេមិនដាក់ទណ្ឌកម្មមកលើរូបលោក មានអ្នកណាប្រាប់លោកទេ?

**ឆ៖** អត់ទេបាទ អត់មានអ្នកណាប្រាប់ទេ។

**ស៖** អរគុណលោកសាក្សី។ ខាងក្រោមនេះបន្តិច នៅក្នុងចម្លើយរបស់លោកដដែល លោកបានរៀបរាប់លម្អិតបន្តិចអំពីអង្គប្រជុំដែលលោកធ្វើការប្រកាសប្រាប់ប្រជាជននេះ។ អ៊ីចឹងឥឡូវនេះ ខ្ញុំសូមអានសម្រង់នេះជាលម្អិត ហើយថាតើលោកយល់ដូចម្ដេចចំពោះសម្ដីរបស់លោក។ លោកប្រធាន គឺឯកសារដដែលទេE3/9149 ERN ដូចដែលបានផ្ដល់រួចមកហើយ លើកលែងតែខ្មែរទេគឺ00731251។ លោកសាក្សី នេះគឺអ្វីដែលលោកបានឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា។ សូមដកស្រង់ នេះគឺពាក់ព័ន្ធទៅនឹងអង្គប្រជុំដែលលោកបានធ្វើការប្រកាសនេះឯង។ សូមដកស្រង់៖ “នេះគឺជាគំនិតរបស់ខ្ញុំ គាត់(គាត់នេះ<ខ្ញុំគិតថា>គឺលោកសំដៅទៅអនុលេខាស្រុករបស់លោក) បានរាយការណ៍ពីរឿងខ្ញុំទៅថ្នាក់លើ ប៉ុន្តែគាត់អត់ទទួលបានជោគជ័យទេ។ គំនិតរបស់ខ្ញុំ គឺស្របជាមួយនឹងថ្នាក់ភូមិភាគ និងថ្នាក់លើ។ ខ្ញុំប្រកាន់យកជំហររបស់ថ្នាក់លើថា ជីវភាពប្រជាជន គឺជារឿងមួយដែលធ្វើឲ្យប្រសើរ គឺជាត្រឹមត្រូវ។ គាត់ទទួលតួនាទីនេះ គួរធ្វើការងារហ្នឹងឲ្យល្អ។” បញ្ចប់ការដកស្រង់។

[១៤:១៥:២៣]

លោកសាក្សី សំណួរខ្ញុំគឺដូចតទៅ លោកបានឆ្លើយថា គំនិតរបស់លោកស្របជាមួយនឹងភូមិភាគ និងថ្នាក់លើ។ ហើយបន្ទាប់មកលោកនិយាយថា ជំហររបស់ថ្នាក់លើ កាលណាពាក់ព័ន្ធទៅនឹងជីវភាពរបស់ប្រជាជន។ <>អ្វីដែលខ្ញុំចង់ដឹង<គឺ>ថា តើលោកអាចជម្រាបជូនអង្គជំនុំជម្រះឲ្យលម្អិតបន្តិចបានទេ ថា ជំហររបស់ថ្នាក់<លើ>ហ្នឹង គឺមានជំហរបែបម៉េចដែរ?

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

**ឆ៖** ខ្ញុំក្ដាប់មិនបានទេ ហើយខ្ញុំយល់មិនដល់ដែរ ពិបាកនិយាយ។

**ស៖** តើលោកអាចបញ្ជាក់លម្អិតបន្តិចបានទេ ចំពោះសម្ដីរបស់លោកដែលឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជាថា "នៅពេលណាដែលជីវភាពរបស់ប្រជាជនបានល្អ <អ្នកដែល>ទទួលតួនាទី<នៅកន្លែងនោះ គឺធ្វើការងារបាន>ល្អប្រសើរ។ នៅពេលដែលលោកនិយាយថា "ជីវភាព" តើលោកសំដៅទៅលើអ្វី?

**ឆ៖** ជីវភាព គឺសំដៅលើអាហារហូបចុកក៏បាន មានបាយ មានម្ហូបអី។

**ស៖** ហើយចុះធ្វើម៉េចទើបលោកដឹងថា នេះគឺជាជំហររបស់ថ្នាក់លើ?

**ប្រធានអង្គជំនុំ៖**

លោកសាក្សី លោកយល់សំណួរទេ? សូមឆ្លើយ!

**2-TCW-850៖**

**ឆ៖** បាទ ដូចជាអត់យល់ទេបាទ ប៉ុន្តែឆ្លើយដូចជម្រាបខាងដើម លោកប្រធាន។

[១៤:១៧:៣៤]

**សួរដោយលោកស្រី ដូរីន ជិន៖**

**ស៖** សំណួររបស់ខ្ញុំមិនសំដៅតែទៅលើជំហររបស់ថ្នាក់លើទេ ប៉ុន្តែខ្ញុំសួរថា តើលោកដឹងអំពីជំហរថ្នាក់លើនេះបានដឹងមកពីណាដែរ? លោកបានដឹងពីជំហរថ្នាក់លើតាមរយៈអង្គប្រជុំ ឬក៏តាមរយៈការប្រកាសណាមួយ ឬក៏យ៉ាងណា?

**ឆ៖** បាទ ជំហរថ្នាក់លើ គឺដឹងតាមរយៈប្រកាសក្នុងវិទ្យុ ឬក៏ប្រកាសតាមរយៈភូមិភាគនិងតំបន់។

**ស៖** សូមអរគុណលោកសាក្សី។ ពេលលោកនិយាយអំពីសារដែលប្រកាសដោយថ្នាក់តំបន់ថ្នាក់ភូមិភាគ តើ<គេផ្សព្វផ្សាយសារនេះដោយរបៀបណា? តើគេផ្សព្វផ្សាយ>តាមរយៈ<>សារទូរលេខឬ? <តើក្នុងអង្គប្រជុំលោកមាននិយាយពីសារនោះទេ?> សូមលោកបញ្ជាក់បានទេ?

**ឆ៖** បាទ តាមរយៈប្រជុំតំបន់ ឬក៏តំបន់ចុះមកស្រុកអ៊ីចឹងមក។

**ស៖** នេះគឺជាសំណួរចុងក្រោយពាក់ព័ន្ធប្រធានបទនេះ ហើយចាំយើងចូលប្រធានបទថ្មី។ ពេលលោកនិយាយ<អំពីកិច្ចប្រជុំនៅ>ថ្នាក់តំបន់ តើនៅថ្នាក់តំបន់នេះ អ្នកណាដែលបានចូលរួមនៅក្នុងអង្គប្រជុំនេះ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ពេលនោះ គឺចូលរួមក្នុងអង្គប្រជុំហ្នឹង គឺមានភាគក៏មក តំបន់ក៏មក។

[១៤:១៩:៣១]

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះខ្ញុំបញ្ចូលទៅសំណួរបន្ទាប់ទៅទៀត ហើយខ្ញុំសូមសួរលោកលម្អិតបន្តិចអំពីថ្នាក់លើ ប៉ុន្តែខ្ញុំមិននិយាយអំពីបទពិសោធន៍របស់លោកនៅស្រុកបារាយណ៍ទេ។ ឥឡូវនិយាយពីបទពិសោធន៍ពីមុនវិញ ខ្ញុំផ្តោតទៅលើបទពិសោធន៍មុនៗនៅតាំងគោក។ នៅរសៀលនេះ មុននេះគឺសហព្រះរាជអាជ្ញាបានយោងទៅសៀវភៅរបស់ ថេត សម្បត្តិ "នៅពីខាងក្រោយ<វាលពិឃាត>" គឺ<លោកនិយាយអំពីការប្រជុំជាមួយ> ប៉ុល ពត ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ លោកថា លោកនឹកឃើញពីអង្គប្រជុំនេះនឹកមិនឃើញទេ ប៉ុន្តែខ្ញុំសាកព្យាយាមមើល ដោយអានសារនេះចេញពីសៀវភៅនេះដើម្បីជួយរំឭកដល់ការចងចាំរបស់លោក។ លោកប្រធាន ខ្ញុំយោងទៅលើសៀវភៅថា "*ប៊ីហាញ់ ឌឺ ឃីល្លីង ហ្វៀល*" គឺ "នៅខាងក្រោយ<វាលពិឃាត>" គឺឯកសារ E3/4202 ជាសៀវភៅសរសេរដោយ ជីណា ចន និង ថេត សម្បត្តិ នៅឆ្នាំ២០១០។ ERN ដែលខ្ញុំនឹងផ្តល់ជូននោះ គឺជាអង់គ្លេស 00757529, ខ្មែរ 00858335 និងបារាំង 00849432។

លោកសាក្សី នេះគឺជាអ្វីដែលបានកត់ត្រា ដោយ ចន និងលោក ថេត សម្បត្តិ តាមរយៈការសម្ភាសជាមួយនឹងរូបលោកនេះតែម្តង។ សូមដកស្រង់៖ "ក្នុងអំឡុងទស្សនកិច្ចរបស់ ប៉ុល ពត បងទី១ ឃើញប្រជាជនជាច្រើន គេដឹកតាមរយៈឡានកាមីញ៉ុង ទៅកាន់ខេត្តកំពង់ចាម។ គេដឹកអ្នកទាំងនោះសំដៅទៅកន្លែងសម្លាប់ចោល។ ប៉ុល ពត សួរថា តើគេដឹកប្រជាជនទាំងនេះទៅទីណា? ហើយអ្នកណាបញ្ជាឲ្យដឹកប្រជាជននេះទៅ?" លោកនេះ គាត់និយាយពីឈ្មោះរបស់លោក ប៉ុន្តែខ្ញុំមិនបាច់និយាយឈ្មោះរបស់លោកទេ។ លោកឆ្លើយនៅក្នុងកិច្ចសម្ភាសន៍នោះថា លោកមានការភ្ញាក់ផ្អើលណាស់ ដែលថា ប៉ុល ពត អត់ដឹងអីចឹង។ លោកបានសន្និដ្ឋានថា "បងទី១ ជាអ្នកផ្តល់សេចក្តីណែនាំនេះហើយ។" បញ្ចប់ការដកស្រង់។ លោកសាក្សី ខ្ញុំសង្ឃឹមថាលោកតាមសម្រង់នេះទាន់ហើយ។ អ្វីដែលខ្ញុំចាប់អារម្មណ៍នោះ គឺលោកនិយាយអំពី ប៉ុល ពត។ អ្វីដែលខ្ញុំចង់ដឹងហ្នឹង គឺថាត្រឹមត្រូវដែរឬទេ តាមអ្វីដែលលោកបានដឹងនោះ គឺថា ប៉ុល ពត ហាក់មិនបានដឹងថា ប្រជាជនរាប់រយពាន់នាក់នេះ ត្រូវគេដឹកយកទៅ<>ទេ <ហើយក៏មិនដឹងថានរណាជាអ្នកចេញបញ្ជាដែរ>?

[១៤:២២:២០]

**ឆ៖** សំណួរនេះ ខ្ញុំមិនអាចឆ្លើយបានទេ ព្រោះខ្ញុំអត់ចាំ។

**ស៖** មិនជាថ្វីទេ លោកសាក្សី<ខ្ញុំនឹងបន្តទៅសំណួរផ្សេងទៀត> ហើយប្រហែលជាសំណួរចុងក្រោយផង។ សំណួរនេះ គឺយើងសំដៅទៅលើបញ្ជាមួយ ដែលសហព្រះរាជអាជ្ញាអន្តរជាតិបានសួរលោករួចមកហើយ គឺនិយាយអំពីការបោសសម្អាតភូមិភាគឧត្តរ។ លោកសាក្សី ខ្ញុំសូមចាប់ផ្តើមសួរទៅលោក ដោយចេញពីចម្លើយមួយផ្នែក ដែលលោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយដែលសហព្រះរាជអាជ្ញាអន្តរជាតិបានសួររួចមកហើយ ហើយក្នុងនោះក៏បានយកវីដេអូ*ញ៉ឹម*មកចាក់ស្តាប់ ហើយសួរលោកឡើងវិញ។ ឥឡូវខ្ញុំសូមអានសម្រង់ដើម្បីជួយរំឭកដល់ការចងចាំរបស់លោកផងដែរ។ លោកប្រធាន នេះគឺជាកិច្ចសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាគឺ E3/9149។ ERN ដែលខ្ញុំផ្តល់ជូននេះ គឺជាអង់គ្លេស 01116153, ខ្មែរ 00731253, បារាំង 01101039។ លោកសាក្សី នេះគឺការពិភាក្សានៅត្រង់នេះ សូមដកស្រង់ ជាកិច្ចសម្ភាសន៍ជាមួយ ឡុង ដានី សួរថា៖ “នៅពេលដែលលោកធ្វើជាលេខាស្រុក តើថ្នាក់<តំបន់>មាន<បញ្ជាឲ្យលោក>ដកហូតប្រជាជនដែរឬទេ? លោកឆ្លើយថា៖ ខ្ញុំជំទាស់ជាមួយកម្មាភិបាលចាស់ៗនៅស្រុកបារាយណ៍។ ពួកគេគំរាមកំហែងដល់ខ្ញុំដោយសារថា មិន<មានការ>ដកកម្មាភិបាលចាស់ៗចេញ<នៅក្រោមការគ្រប់គ្រងរបស់ខ្ញុំ>។ កម្មាភិបាលចាស់ៗនោះ គេត្រូវដកចេញ។ ហើយគេសួរថា ហេតុអីបានខ្ញុំមិនដកកម្មាភិបាលចាស់ៗនោះចេញ។ ខ្ញុំសួរពួកគេថា តើខ្ញុំអាចដកពួកគេដោយរបៀបណា? បើពួកគេដឹកនាំប្រជាជន ហើយមិនដែលជំទាស់ជាមួយយើង ហើយមិនដែលមានទំនាស់អីផង។ អ៊ីចឹងខ្ញុំរកមិនឃើញថា មូលហេតុអីដែលត្រូវដកហូតពួកគេចេញទេ។ <ខ្ញុំបាននិយាយបែបនេះបី ឬប្រាំដង>” ហើយខាងក្រោមនេះបន្តិច សូមដកស្រង់ លោកថា៖ “មានបញ្ជាមកពីថ្នាក់លើ ឲ្យចាប់ខ្លួនអ្នកដែលប្រឆាំងជាមួយនឹងយើង។” បញ្ចប់ការដកស្រង់។

[១៤:២៤:៤៤]

<> សំណួររបស់ខ្ញុំសួរថា តើលោកបានទទួលបញ្ជាពីថ្នាក់លើឲ្យចាប់ខ្លួនអ្នកដែលប្រឆាំងនេះនៅពេលណា? ឧទាហរណ៍ថាលោកបានទទួលបញ្ជាតាមរយៈអង្គប្រជុំ ឬក៏តាមរយៈឯកសារណាមួយដែរ?

**ឆ៖** ខ្ញុំអត់បានបញ្ជាទេ។ ហើយគឺរឿងទាំងអស់នោះ គឺថ្នាក់តំបន់ គេមកៗខ្លួនគេផ្ទាល់។ មកសួរខ្ញុំ ខ្ញុំថា ខ្ញុំក្តាប់មិនបានទេ។

**ស៖** លោកសាក្សី ខ្ញុំដឹងហើយថាលោកមិនមែនជាអ្នកចេញបញ្ជាទេ។ ប៉ុន្តែតើលោកដឹងទេ អ្នក

ណាជាអ្នកចេញបញ្ជានេះ? តើពួកថ្នាក់តំបន់ដែលមកទីតាំងរបស់លោកនោះ ឬក៏ជាអ្នកណាផ្សេងដែលជាអ្នកចេញបញ្ជានេះ?

**ឆ៖** គឺតំបន់ គេចុះមកផ្ទាល់ខ្លួនគេ។

**ស៖** ចុះលោកនឹកឈ្មោះឃើញទេ អ្នកដែលមកពីថ្នាក់តំបន់ មកកន្លែងរបស់លោកហ្នឹងឈ្មោះអ្វីដែរ?

[១៤:២៦:៣៤]

**ឆ៖** ដូចខ្ញុំជម្រាបពីលើហ្នឹង តំបន់មានតែ អឿន ហ្នឹង ឈ្មោះ អឿន។

**ស៖** សូមសួរបញ្ជាក់បន្តិច តើ អឿន នេះជាលេខាតំបន់ឬ?

**ឆ៖** អឿន ជាលេខាតំបន់។

**ស៖** តើលោកនៅចាំបានទេ អឿន នេះមកកន្លែងលោកញឹកញាប់ប៉ុនណាដែរ?

**ឆ៖** មកយូរៗមកម្តង ប៉ះកាលណា២០ថ្ងៃ ប៉ះកាលណា១ខែ។

**ស៖** នៅពេលដែល អឿន ហ្នឹងមកកន្លែងលោក តើគាត់មកធ្វើអ្វី?

**ឆ៖** មកដូចខ្ញុំបានបញ្ជាក់អ៊ីចឹង គេមកហ្នឹងសាកសួរ។ ជួបនឹង ដូចខ្ញុំថាអ៊ីចឹង ជួបនឹងអនុលេខាហ្នឹងគឺមក គេស្គាល់គ្នា ហើយក៏មកជួបខាងអនុលេខាហ្នឹង។

**ស៖** ហើយក្រៅពី អឿន លេខាតំបន់មកកន្លែងលោកនោះ តើលោកមានការប្រាស្រ័យទាក់ទងជាមួយនឹងអឿន ទេនៅពេលដែល អឿន ទៅកន្លែងផ្សេង? ឧទាហរណ៍ថា តើលោកមានទាក់ទងជាមួយ អឿន <ទៅវិញទៅមកអំពីអ្វីដែលបានកើតឡើងនៅក្នុងតំបន់នេះ ក្នុងចន្លោះពេលដែលគាត់មកមើលរវាងរៀងរាល់២០ថ្ងៃម្តងនោះ>?

**ឆ៖** បាទ អត់ទេ។

[១៤:២៨:៣៧]

**ស៖** សូមអរគុណលោកសាក្សី។ សំណួរចុងក្រោយរបស់ខ្ញុំពាក់ព័ន្ធទៅនឹងផ្នែកមួយនៃសៀវ-ភៅថា "នៅពីខាងក្រោយ<វាលពីឃាត>" នេះ ដែលយើងបានពិភាក្សាគ្នាពីដើមមុនមកហើយ។ នេះគឺជាផ្នែកមួយដែលលោក<និយាយអំពីការ>ទទួលបញ្ជីឈ្មោះមនុស្សជាង៣០០នាក់។ លោកបាន -- នៅពេលដែលលោកផ្តល់សក្ខីកម្មឆ្លើយសំណួរដល់សហព្រះរាជអាជ្ញា លោកថា លោកនឹកមិនឃើញថាមានទទួលបញ្ជីហ្នឹងទេ។ ក៏ប៉ុន្តែខ្ញុំសូមអានសម្រង់ហ្នឹងឡើងវិញ ក្រែងវារំឭកដល់ការចងចាំរបស់លោក

ហើយនិងសួរសំណួរតាមរបៀបផ្សេងពាក់ព័ន្ធទៅនឹងសម្រង់នេះ។

លោកប្រធាន នេះគឺជាសៀវភៅ "នៅពីខាងក្រោយ<វាលពិឃាត>" ដោយ ជីណា និង សម្បត្តិ ដែលនៅឆ្នាំ២០១០ ឯកសារE3/4202, ERNនោះគឺអង់គ្លេស 00757529, ខ្មែរ 00858335 និង បារាំង 00849432។ លោកសាក្សី លោកបានស្តាប់សម្រង់នេះម្តងហើយ ឥឡូវខ្ញុំសូមដកស្រង់ឡើងវិញទៀត។ សូមដកស្រង់៖ នៅឆ្នាំ១៩៧៧ កែ ពក បានហៅគាត់ (គឺលោកហ្នឹងហើយ) ទៅប្រជុំ។ លោកបានទទួលបញ្ជាពីថ្នាក់លើ ឲ្យស៊ើបសួរអំពីសមាសភាពមិនល្អនៅក្នុងជួរកម្មាភិបាល។ <ប្រធានតំបន់ម្នាក់>បានឲ្យបញ្ជីឈ្មោះមនុស្សជាង៣០០នាក់ ដែលផ្ញើទៅតំបន់របស់លោក គឺផ្ញើពីភ្នំពេញទៅ។ លោកបានចំណាយពេល៣ខែដើម្បីតាមដានឈ្មោះទាំងអស់នេះ <មុនពេល>លោកបានរាយការណ៍ទៅថ្នាក់តំបន់ថា លោកអត់មានធ្វើអ្វីខុស។ ហើយថ្នាក់តំបន់ចោទប្រកាន់លោកថា លោកនេះគឺជាអ្នកលាក់ពួកក្បត់ ព្រោះរកអត់មានឃើញខ្មាំងសោះ។ បញ្ចប់ការដកស្រង់។ លោកសាក្សី ផ្នែកដែលខ្ញុំ<ចាប់អារម្មណ៍>នេះគឺជាផ្នែកទី២ ដែលលោកនិយាយថា <រាយការណ៍ទៅ>ប្រធានតំបន់។ ហើយក្រោយមកប្រធានតំបន់ស្តីបន្ទោសឲ្យលោក។ តើលោកនៅចាំឈ្មោះប្រធានតំបន់នេះ ដែលលោករាយការណ៍ទៅឲ្យហ្នឹងដែរឬទេ?

**ឆ៖** ឈ្មោះដដែលហ្នឹង អឿន ហ្នឹងដដែល។

[១៤:៣១:១៦]

**ស៖** តើ អឿន មានប្រាប់លោកទេថា ហេតុអ្វីបានជាគាត់តម្រូវឲ្យលោកស៊ើបអង្កេតឈ្មោះមនុស្សដែលមាននៅក្នុងបញ្ជីនេះ?

**ឆ៖** ខ្ញុំមិនបាន ក្តាប់មិនបានទេចំណុចនេះ។

**ស៖** មិនថ្វីទេ ខ្ញុំព្យាយាមតាមរបៀបផ្សេង។ តើ អឿន មានប្រាប់លោកទេថា លោកត្រូវស៊ើបអង្កេតឈ្មោះទាំងអស់នេះ ពីព្រោះថានេះគឺជាបញ្ហា? ហើយបើលោកបានទទួលមែន តើលោកដឹងថា បើតាម អឿន ប្រាប់លោក តើបញ្ហានេះចេញមកពីណាដែរ?

**ឆ៖** ខ្ញុំអត់ដឹងដែរ ក្តាប់មិនបានដែរ។ ហើយ អឿន ហ្នឹងក៏មិនដែលហុចបញ្ជីមកឲ្យខ្ញុំពិនិត្យដែរ គឺថា--។

**ស៖** នៅក្នុងសម្រង់ដែលខ្ញុំអានឲ្យលោកស្តាប់នៅផ្នែកចុងក្រោយ លោកថាប្រធានតំបន់ហ្នឹងស្តីបន្ទោសលោក ដោយសារថាលោករកកំហុសអីមិនឃើញ ហើយលោកនេះ ក្រោយមកត្រូវបានប្រធាន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

តំបន់ចោទប្រកាន់ថា លាក់បំពួនពួកក្បត់។ នៅពេលដែលលោកឆ្លើយថា ប្រធានតំបន់ឈ្មោះ អឿន ស្ដី បន្ទោសឲ្យលោកនោះ តើមានអ្វីកើតឡើងចំពោះលោកទេ?

**ឆ៖** បាទ អត់មានអីទេ។

**ស៖** ហើយតើមានអ្នកណាពន្យល់ប្រាប់លោកទេថា លោកមិនស៊ើបអង្កេតអីចឹងហើយ ទៅជាមិនមានរឿងអីកើតមកដល់លោក?

**ឆ៖** ព្រោះខ្ញុំមិនដែលបានទទួល ហើយក៏ខ្ញុំមិនមានកំហុសអី ដែលគេនាំឲ្យគេចាប់ថ្នាក់បាន។

**លោកស្រី ដូរីន ជិន៖**

សូមអរគុណច្រើនលោកសាក្សីចំពោះភាពអត់ធ្មត់របស់លោក។

លោកប្រធាន អស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

ឥឡូវដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី គិតចាប់ពីនេះតទៅ។

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៤ នាទី ដល់ម៉ោង ១៤:៥៧ នាទី)*

[១៤:៥៧:៣៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

ជាបន្តសូមលោកមេធាវីការពារក្ដីលោក ខៀវ សំផន អញ្ជើញមានសំណួរលើសាក្សីរូបនេះ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរភាគីទាំងអស់គ្នា។

**សួរដោយកកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោកសាក្សី។ ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាសហមេធាវីអន្តរជាតិរបស់លោក ខៀវ សំផន។ ខ្ញុំចោទសំណួរទៅលោកនេះបន្តិចបន្តួចទេបន្ថែម។ ចំណុចទី១ ដែលខ្ញុំចង់សួរលោកនោះគឺ លោកបាននិយាយជាមួយនឹងសហវិតារបស់ខ្ញុំអម្បាញ់មិញនេះ អំពីកិច្ចប្រជុំដែលលោកបានចូលរួមនៅតំបន់ កាលនោះលោកធ្វើជាចៅហ្វាយស្រុកនៅបារាយណ៍។ អីចឹងខ្ញុំសួរលោកថាតើ

លោកមាននៅចាំអំពីកិច្ចប្រជុំមួយដែលក្នុងពេលប្រជុំនោះ គេនិយាយអំពីការប្រព្រឹត្តទៅលើប្រជាជន ហើយនិងជាពិសេសការប្រព្រឹត្តទៅលើប្រជាជន១៧មេសា? តើលោកមាននៅចាំថា លោកបានចូលរួមក្នុងកិច្ចប្រជុំហ្នឹងដែរឬទេ?

**2-TCW-850៖**

**ឆ៖** បាទ ខ្ញុំអត់ចាំក្នុងកិច្ចចូលរួមប្រជុំទេ។

**ស៖** តើលោកមានចាំថា បានឃើញឯកសារមួយទាក់ទងទៅនឹងការប្រព្រឹត្តទៅលើប្រជាជន១៧មេសា ដែរឬទេ?

[១៤:៥៩:២៧]

**ឆ៖** បាទ អត់បានទទួលទេ។

**ស៖** ខ្ញុំនឹងព្យាយាមរំឭកដល់លោក ពីព្រោះថា លោកបាននិយាយអំពីចំណុចនេះនៅពេលដែលអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតសួរទៅលោក គឺឯកសារ E3/5293, ERN ជាភាសាបារាំងគឺ 00367749, ERN ជាភាសាអង់គ្លេសគឺ00351703, ERN ជាភាសាខ្មែរគឺ 0034 8842 ទៅដល់43។ ខ្ញុំសូមអានសំណួរ និងចម្លើយនេះទាំងស្រុងតែម្ដងដើម្បីឲ្យដឹងថាតើលោកចាំឬក៏អត់? សំណួរដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ "តើលោកមានធ្លាប់ចូលប្រជុំនៅស្រុកបារាយណ៍ដែរឬទេ? ចម្លើយរបស់លោក៖ ខ្ញុំធ្លាប់ត្រូវបានគេកោះហៅទៅប្រជុំម្ដង ប្រជុំនៅចំការលើខេត្តកំពង់ចាម គឺអឿនមកពីតំបន់ ជាអ្នកដឹកនាំប្រជុំ។ ក្នុងប្រជុំ ថ្នាក់លើបានដាក់ផែនការឲ្យធ្វើស្រែ ប៉ុន្តែមិនមានការដាក់ផែនការក្នុងការបោសសម្អាតខ្មាំងនោះទេ។ នៅពេលដែលខ្ញុំទៅដល់ស្រុកបារាយណ៍ហ្នឹង មានការចេញឯកសារមួយដែលចេញការណែនាំដែលទាក់ទងនឹងការការពារព្រំដែន ហើយនិងការពារបដិវត្តន៍តែប៉ុណ្ណឹងទេ។ ហើយមានឯកសារមួយទៀតគេថា គេឲ្យយើងចែករំលែកជាមួយនឹងប្រជាជន១៧មេសាហ្នឹងឲ្យស្មើគ្នា ហើយមិនឲ្យរើសអើងគ្នាទេ ចាស់និងថ្មីឲ្យដូចគ្នា។ សំណួរបន្តទៀត៖ តើលោកមានបានឃើញឯកសារសារាចរហ្នឹងទេ? ចម្លើយរបស់លោក៖ ខ្ញុំឃើញសារាចរនេះ ហើយខ្ញុំបានទាំងរៀនទៀតផង។ ខ្ញុំមិនដឹងថាចេញមកពីថ្នាក់ណានោះទេ ហើយគឺជាឯកសារជាសៀវភៅកាលហ្នឹង។" សូមបញ្ចប់ការដកស្រង់។

[១៥:០១:៥៤]

ឥឡូវខ្ញុំអានចម្លើយរបស់លោកចំពោះមុខសហចៅក្រមស៊ើបអង្កេតហើយនេះ អ៊ីចឹងខ្ញុំសួរលោក

ថាតើលោកនឹកឃើញទេ? មានលោកឃើញឯកសារហ្នឹងដែលគេនិយាយអំពីការប្រព្រឹត្តទៅលើប្រជាជន១៧មេសា ហើយដែលគេណែនាំថាឲ្យប្រព្រឹត្តទៅលើប្រជាជន១៧មេសាហ្នឹង ដូចប្រជាជនចាស់អ៊ីចឹងកុំឲ្យរើសអើងគ្នា?

**ឆ៖** បាទ ឯកសារហ្នឹងគឺខ្ញុំបានទទួល។

**ស៖** តើលោកមានចាំថា លោកបានទទួលឯកសារហ្នឹងនៅក្នុងឱកាសណាដែរ? តើនៅក្នុងឱកាសប្រជុំណាមួយ ឬក៏ក្នុងឱកាសណាមួយផ្សេងទៀត?

**ឆ៖** បាទ អត់បានចាំពេលវេលាដែរ។

**ស៖** លោកៗបានឆ្លើយនៅក្នុងឯកសារអម្បាញ់មិញនេះ ដែលលោកថាអាហ្នឹងជាសៀវភៅសារាចរហ្នឹងជាសៀវភៅ។ តើលោកចាំថាតើវានៅក្នុងទង់បដិវត្ត ឬក៏ទង់យុវជន យុវនារីកម្ពុជាឬក៏លោកនៅចាំថានៅក្នុងឯកសារមួយផ្សេងទៀតទេ?

**ឆ៖** បាទ ឯកសារហ្នឹងវាជាទង់ បាទទង់បដិវត្ត។

**ស៖** តើលោកនៅធ្លាប់ពិគ្រោះទង់បដិវត្តហ្នឹងញឹកញាប់ដែរឬទេ ឬក៏កាលហ្នឹង ជាលើកទី១របស់លោកហើយដែលលោកបានអានទង់បដិវត្តហ្នឹង?

**ឆ៖** បាទ បានអាន និងប្រជុំពិគ្រោះពិភាក្សាគ្នា នៅក្នុងសៀវភៅហ្នឹង។

**ស៖** សូមអរគុណ។ ក៏ប៉ុន្តែតើលោកធ្លាប់អានទង់បដិវត្តហ្នឹងញឹកញាប់ដែរឬទេ? ឬក៏លើកហ្នឹងៗគឺជាលើកទី១ហើយ ដែលលោកបានអានទង់បដិវត្តហ្នឹងនៅក្នុងពេលប្រជុំនោះ?

[១៥:០៤:៤២]

**ឆ៖** បាទ លើកទី១ហើយ។

**ស៖** នៅក្នុងកិច្ចសម្ភាសន៍ដែលជាមួយនឹងសហចៅក្រមស៊ើបអង្កេតហ្នឹង លោកបាននិយាយអំពីការចូលរួមទៅនឹងពិធីការមួយ។ ខ្ញុំសួរលោកថា លោកមានចាំដែរឬទេថា លោកបានចូលរួមពិធីការហ្នឹងនៅកន្លែងណា? ហើយនៅពេលណាដែរ?

**ឆ៖** បាទ ទីកន្លែងខ្ញុំ អត់ចាំដែរ ប៉ុន្តែខ្ញុំបានចូលរួមការយុវជន យុវនារីហ្នឹង។

**ស៖** តើលោកបានចូលរួមហ្នឹង ក្នុងឋានៈជាគណៈស្រុក ឬក៏ក្នុងឋានៈអីដែរ?

**ឆ៖** ក្នុងឋានៈជាភ្ញៀវ ក្នុងឋានៈជាគណៈស្រុក។

**ស៖** បើសិនជាលោកចាំ តើលោកមានចាំថា មានអ្នកណាខ្លះចូលរួមក្នុងពិធីរៀបការហ្នឹងដែរឬ

ទេ?

**ឆ៖** បាទ ខ្ញុំចាំ គឺក្នុងពិធីរៀបការហ្នឹង គឺមានមិត្តភក្តិយុវជន យុវនារីហ្នឹង ហើយនិងមាតាបិតា ឪពុកម្តាយទាំងសងខាង។

**ស៖** តើលោកមានចាំដែរឬទេ ថាតើលោកបានចូលរួមពិធីការផ្សេងទៀត ក្រៅពីពិធីការមួយហ្នឹងដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់បានចូលរួមទេ។

[១៥:០៦:៥៧]

**ស៖** នៅថ្ងៃដែលលោកបានចូលរួមក្នុងពិធីការនុ៎ង តើការច្រើនគូដែរឬទេ នៅថ្ងៃនុ៎ង?

**ឆ៖** បាទ មួយគូ ពីរគូ មួយគូម្តង មួយគូម្តង។

**ស៖** តើកាលនោះគេរៀបការហ្នឹង គេធ្វើយ៉ាងម៉េចដែរ?

**ឆ៖** បាទ រៀបការហ្នឹង គ្រាន់តែឡើងប្រកាសប្រវត្តិរូបទាំងសងខាង ហើយនិងភ្ញៀវ ម្តាយឪពុក ហើយនិងប្រធានកម្មវិធីហ្នឹង ក៏ប្រកាសទទួលស្គាល់ថាជាគូស្វាមីហ្នឹង។

**ស៖** សំណួរខ្ញុំ មិនច្បាស់ មិនសូវច្បាស់។ តាមពិតខ្ញុំចង់ដឹងថាតើដើម្បីរៀបការបានហ្នឹង ដើម្បីអាចរៀបការបានហ្នឹង គេត្រូវធ្វើយ៉ាងម៉េច? នៅពេលដែលបុគ្គលម្នាក់ចង់រៀបការជាមួយម្នាក់ទៀតហ្នឹង តើគេត្រូវធ្វើយ៉ាងម៉េចដែរ និយាយពីនីតិវិធី?

**ឆ៖** បាទ មុននឹងពេលរៀបការហ្នឹង គឺអ្នកទាំងសងខាងហ្នឹង គឺបានស្នើឡើងដល់មេក្រុម ឬក៏សហករណ៍។

**ស៖** ពេលដែលគេស្នើទៅប្រធានសហករណ៍ហើយហ្នឹង តើមានរឿងអីកើតឡើងទៅ?

**ឆ៖** បាទ អត់មានរឿងអីកើតឡើងទេ មានតែកំណត់ពេលវេលា និងថ្ងៃខែ។

[១៥:០៩:២២]

**ស៖** ឥឡូវខ្ញុំសូមរំឭកដល់ការចងចាំរបស់លោក អំពីអ្វីដែលលោកបាននិយាយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត និងគឺឯកសារដដែល គឺឯកសារ <E3/5293> ជាភាសាបារាំងគឺ 00367751, ជាភាសាអង់គ្លេសគឺ 00351705, ជាភាសាខ្មែរគឺ 00438844 ទៅដល់ ត្រឹម 44 នេះទេ។ នៅពេលដែលលោកឆ្លើយទៅសហចៅក្រមស៊ើបអង្កេតនេះ លោកឆ្លើយច្បាស់ជាងហ្នឹង។ សំណួរដែលគេសួរលោកហ្នឹងដូចតទៅនេះ៖ “បើសិនជាពីរមនុស្សពីរនាក់ស្រឡាញ់គ្នា តើគេអាចរៀបការបាន

ដែរឬទេ? ចម្លើយរបស់លោកគឺថា៖ បើសិនជាពួកគេស្រឡាញ់គ្នានោះ ខាងបុរសគេត្រូវស្នើសុំរៀបការ ហើយយើងមិនអាចបំបែកបំបាក់ពួកគេទេ។ ហើយដើម្បីរៀបការនេះត្រូវសុំច្បាប់ទៅសហករណ៍ រួច ហើយត្រូវបញ្ជូនទៅគណៈស្រុកដើម្បីសម្រេច។ សំណួរបន្តទៀត៖ តើអ្នកណាជាអ្នកអនុញ្ញាតឲ្យមាន ការរៀបការហ្នឹង? ចម្លើយរបស់លោក៖ ពេលមានរៀបការហ្នឹង គេប្រជុំថ្នាក់ស្រុក ថ្នាក់ឃុំរួមគ្នា ហើយនិងគេធ្វើការសម្រេចហ្នឹងអំពីរៀបការនេះ ដំបូងគេគិតពីអាយុ យ៉ាងហោចណាស់ឲ្យមាន១៨ឆ្នាំ ខាងស្រី។ ហើយបន្ទាប់មកទៀត ត្រូវឲ្យស្រឡាញ់គ្នា ពីរនាក់ហ្នឹងត្រូវស្រឡាញ់គ្នាពិត ឬមិនពិត។ ហើយបន្ទាប់មកទៀត ត្រូវមានការយល់ព្រមពីឪពុកម្ដាយ។"

តើអ្វីដែលខ្ញុំអានអំម្បាញ់មិញនេះ ដែលជាចម្លើយរបស់លោក ៗឆ្លើយទៅសហចៅក្រមស៊ើប អង្កេតនោះ អ្នកស៊ើបអង្កេតនៃចៅក្រមស៊ើបអង្កេតនោះ តើធ្វើឲ្យលោកនឹកឃើញទេ ថាហ្នឹងឬនីតិវិធី ដែលគេធ្វើអង្គាល់ហ្នឹងនោះ <គឺត្រូវធ្វើសំណើទៅសហករណ៍ ហើយ>គេត្រូវផ្ទៀងផ្ទាត់អាយុខាងស្រី គេត្រូវឲ្យដឹងថាទាំងពីរនាក់ហ្នឹងគេព្រមព្រៀងគ្នា គេស្ម័គ្រចិត្តនឹងគ្នា ហើយនិងមានការយល់ព្រមពី ឪពុកម្ដាយជាដើមហ្នឹង? ធ្វើឲ្យលោកនឹកឃើញទេ ខ្ញុំអានជូនលោកស្ដាប់អ៊ីចឹង?

**ឆ៖** បាទ ខ្ញុំនឹកឃើញហើយ។ គឺមុននឹងរៀបចំគ្នា គឺអ្នកទាំងពីរហ្នឹងត្រូវតែមានការយោគយល់ ឬក៏មានការស្មោះស្ម័គ្ររវាងគ្នានឹងគ្នា ទៅវិញទៅមក។

[១៥:១២:០៧]

**ស៖** លោកបានឆ្លើយថា ជាដំបូងនោះត្រូវស្នើទៅសហករណ៍ ហើយបន្ទាប់មកទៀត គេបញ្ជូន ទៅគណៈស្រុក។ អ៊ីចឹងសំណួរខ្ញុំហ្នឹងចង់ផ្ដោតទៅលើសំណើដែលលោកបានទទួលពេលដែលលោកធ្វើ ការនៅគណៈស្រុក។ អ៊ីចឹងសំណួរទី១ របស់លោកនោះថា ក្រៅពីពិធីរៀបការមួយហ្នឹងដែលលោកបាន ចូលរួមនោះ ហើយលោកមិនបានចូលរួមទៅពិធីរៀបការផ្សេងទៀតទេ តើលោកមានបានទទួលសំណើ ដែលគេបញ្ជូនបន្តពីសហករណ៍ហ្នឹងទៅស្រុកបារាយណ៍ហ្នឹងដែរឬទេ ទៅកន្លែងដែលលោកធ្វើការហ្នឹង?

**ឆ៖** បាទ គេស្នើដែរ ពីសហករណ៍មកស្នើ ថាធ្វើរៀបការឈ្មោះនេះៗអ៊ីចឹង។

**ស៖** អ៊ីចឹងនៅពេលដែលលោកបានទទួលសំណើទាំងអស់ហ្នឹង ដោយដាក់លាក់តែម្ដងហ្នឹង ថ្នាក់ស្រុកគេធ្វើអីទៅពេលដែលបានទទួលសំណើហើយ? ខ្ញុំសូមបញ្ជាក់សំណួរម្ដងទៀត លោកបាន ឆ្លើយថា ដើម្បីអាចរៀបការបានហ្នឹង ត្រូវផ្ទៀតផ្ទាត់អាយុខាងស្រី ហើយនិងកិច្ចព្រមព្រៀងរបស់ភាគី ទាំងពីរហ្នឹង ហើយនិងការព្រមព្រៀងរបស់ឪពុកម្ដាយ។ អ៊ីចឹងខ្ញុំសួរថា <តើលោកជាអ្នក>ផ្ទៀងផ្ទាត់

ហ្នឹង <ឬក៏ថ្នាក់ណាផ្សេងទៀតជាអ្នក>ផ្ទៀងផ្ទាត់<>? <>តើអ្នកណាដែរជាអ្នកទទួលបន្ទុកខាងផ្ទៀងផ្ទាត់ព័ត៌មានទាំងអស់ហ្នឹង? <តើការផ្ទៀងផ្ទាត់នេះធ្វើនៅថ្នាក់សហករណ៍ ឬក៏នៅថ្នាក់ស្រុក?>

**ធ៖** បាទ ខ្ញុំអត់ចាំទេ។ ប៉ុន្តែឲ្យថ្នាក់សហករណ៍ហ្នឹងគេផ្ទៀងផ្ទាត់ហើយ គេស្នើឡើងមកខាងស្រុក ថាត្រូវរៀបចំគូនេះនឹងគូនេះអ៊ីចឹង។

**ស៖** អ៊ីចឹង<លោក>នៅថ្នាក់ស្រុកហ្នឹង <តើ>រូបលោកផ្ទាល់ហ្នឹងហើយដែលជាអ្នកចេញការអនុញ្ញាតឲ្យរៀបចំពិធីការហ្នឹង ពិធីរៀបការហ្នឹង ឬក៏យ៉ាងណា?

[១៥:១៤:៤២]

**ធ៖** បាទ ពេលមានកិច្ចប្រជុំស្រុក ដល់ពេលកិច្ចស្រុកទៅខាងសហករណ៍គេមកប្រជុំទៅ ក៏ស្នើឡើងទៅ ក៏សម្រេចនៅក្នុងគណៈកម្មការហ្នឹង ស្រុកហ្នឹងបណ្តោយ។

**ស៖** តើគេធ្វើសេចក្តីសម្រេចហ្នឹង ទាល់តែគេប្រជុំសិន ឬក៏យ៉ាងម៉េច ឬក៏ពេលដែលគេធ្វើសេចក្តីសម្រេចហើយហ្នឹង គឺគេសរសេរជាលាយលក្ខណ៍អក្សរបញ្ជូនត្រឡប់ទៅសហករណ៍វិញ ឬក៏គ្រាន់តែប្រជុំហើយ ប្រាប់សេចក្តីសម្រេចនៅពេលប្រជុំហ្នឹងផ្ទាល់មាត់តែម្តង តែប៉ុណ្ណឹងទេ?

**ធ៖** បាទ គឺខាងសហករណ៍ហ្នឹង ប្រធានសហករណ៍ហ្នឹងគេមក មកជួបហើយ ក៏សម្រេចបណ្តោយ។ ខ្លះក៏បានសរសេរជាលាយលក្ខណ៍អក្សរ ខ្លះក៏គេមកហើយ គេកត់ហេតុ។

**ស៖** បើសិនខ្ញុំច្រឡំ សូមកែខ្ញុំ ក៏ប៉ុន្តែបើតាមចម្លើយរបស់លោកនេះ លោកចេញសេចក្តីសម្រេចហ្នឹងដោយផ្អែកលើព័ត៌មាន ដែលប្រធានសហករណ៍ហ្នឹងផ្តល់មកលោក។ តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

**ធ៖** បាទខ្ញុំស្តាប់អត់ទាន់បានសំណួរនេះ អត់ទាន់យល់។

**ស៖** ខ្ញុំសូមបំភ្លឺ។ លោកបានឆ្លើយថា ប្រធានសហករណ៍ជាអ្នករាយការណ៍មកលោកជាមួយនឹងសំណើហ្នឹង ហើយលោកជាមួយនឹងគណៈស្រុកហ្នឹង គឺលោកធ្វើសេចក្តីសម្រេច។ អ៊ីចឹងខ្ញុំសួរលោកថា តើលោកយល់ស្របនឹងខ្ញុំដែរឬទេ គឺថាតើឲ្យផ្អែកលើព័ត៌មានដែលប្រធានសហករណ៍ហ្នឹងយកមកឲ្យលោកហ្នឹង ផ្អែកលើព័ត៌មានទាំងអស់ហ្នឹងហើយ បានធ្វើសេចក្តីសម្រេចចេញទៅឲ្យគេវិញ?

**ធ៖** បាទ បានទទួលព័ត៌មានហ្នឹងហើយហ្នឹង គឺត្រូវសម្រេចគ្នានៅក្នុងគណៈហ្នឹង គឺប្រគល់ឲ្យខាងសហករណ៍ហ្នឹង គេចាត់ចែងតាមនីតិវិធីហ្នឹង។

[១៥:១៧:៥៤]

**ស៖** រូបលោកផ្ទាល់នោះ លោកបានឆ្លើយថា លោកបានចូលរួមក្នុងពិធីរៀបការហ្នឹងតែម្តង

ហ្នឹងទេ។ អ៊ីចឹងខ្ញុំសួរលោកថា តើលោកអាចជម្រាបជូនតុលាការបានដែរឬទេ កាលដែលលោកធ្វើការនៅបារាយណ៍ហ្នឹង តើមានពិធីរៀបការហ្នឹងញឹកញាប់ប៉ុនណាដែរ?

**ធ៖** បាទ នៅតាមសហករណ៍ ខ្លះក៏ខ្ញុំក្តាប់បានទៅ ខ្លះក៏ក្តាប់មិនបាន អាហ្នឹងវាមានការរៀបចំបន្តបន្ទាប់តាមជាក់ស្តែងនៃសហករណ៍នីមួយៗ។

**ស៖** នៅក្នុងអំឡុងពេលដែលលោកជាលេខាស្រុកបារាយណ៍នេះ តើលោកនៅមានចាំអំពីចំនួនពិធីរៀបការ ដែលគេបានរាយការណ៍ប្រាប់លោកដែរឬទេ?

**ធ៖** បាទ អត់ចាំទេ។

**ស៖** ខ្ញុំមានចំណុចមួយទៀត ដែលចង់និយាយជាមួយលោក។ អម្បាញ់មិញនេះសហព្រះរាជអាជ្ញាអន្តរជាតិ គាត់បានចោទសំណួរលោកមួយចំនួនទាក់ទងទៅនឹងការប្រព្រឹត្តទៅលើជនជាតិចាម លោកបានឆ្លើយថា លោកភ្លេចហើយ ថាមិនដឹងថា គោលនយោបាយពាក់ព័ន្ធនឹងជនជាតិចាមនេះយ៉ាងណានោះទេ។ ខ្ញុំដឹងថា លោកថាមិនចាំពីគោលនយោបាយក៏ដោយចុះ ក៏ប៉ុន្តែខ្ញុំចង់ដឹងថាតើនៅពេលដែលលោកធ្វើការនៅបារាយណ៍ហ្នឹង តើមានជនជាតិចាមរស់នៅក្នុងស្រុកហ្នឹងដែរឬទេ?

**ធ៖** បាទ មាន។

**ស៖** តើលោកនៅចាំទេថា នៅក្នុងស្រុកហ្នឹង នៅកន្លែងណាដែរ មានក្រុមគ្រួសារចាមនោះរស់នៅ?

[១៥:២០:១៣]

**ធ៖** បាទ មានត្រពាំងឈូក ហៅភូមិត្រពាំងឈូក។

**ស៖** លោកបាននិយាយអំពីចំណុចនេះ នៅក្នុងកិច្ចសម្ភាសន៍មួយទៀត ដែលជាមួយនឹងអ្នកស៊ើបអង្កេតនៃសហចៅក្រមស៊ើបអង្កេត គឺឯកសារ E3/10634 លោកបាននិយាយអំពីចំណុចនេះ នៅសំណួរ និងចម្លើយទី៨ ទៅដល់ទី១៣។ លោកសាក្សី តើលោកមានបានទទួលបញ្ជាណាមួយឲ្យចាប់ខ្លួនជនជាតិចាមដែរឬទេ?

**ធ៖** បាទ ខ្ញុំអត់បានទទួលទេ។

**ស៖** តើលោកមានដឹងដែរឬទេថា ចាម ជនជាតិចាមដែលនៅត្រពាំងឈូកហ្នឹងណា តើគាត់មកពីណាដែរ? ដើមកំណើតគាត់មកពីណាដែរ ឬក៏គាត់ហ្នឹងអ្នកស្រុកនៅត្រពាំងឈូកហ្នឹងតាំងពីណាពីណីមកតែម្តង?

**ឆ:** បាទ គឺអ្នកស្រុកគេហ្នឹងតាំងពីមុនមករហូត។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយលោកប្រធាន សូមអរគុណ។

[១៥:២១:៥៨]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ សវនាការស្តាប់សក្ខីកម្មសាក្សី 2-TCW-850 ដល់ទីបញ្ចប់ហើយ។ អង្គជំនុំជម្រះអរគុណលោកសាក្សី ដែលបានចំណាយពេលវេលាមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ក្នុងឋានៈជាសាក្សីក្នុងរយៈពេល១ថ្ងៃនេះ។ លោកអាចសម្រាកបានហើយ លោកមេធាវីប្រឹក្សាដូចគ្នា លោកអាចសម្រាកបានហើយ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកអង្គភាពគាំពារសាក្សី អ្នកជំនាញ ក្នុងការជូនសាក្សីរូបនេះ វិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬគោលដៅណាដែលគាត់មានបំណងចង់បានទៅហើយ។

ជាបន្តទៀតអង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី2-TCCP-274។ មន្ត្រីរដ្ឋបាលតុលាការអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-274 មកកាន់កន្លែងផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ។

*(ដើមបណ្តឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

[១៥:២៤:៣៨]

មុននឹងចាប់ផ្តើមស្តាប់សក្ខីកម្មរដ្ឋប្បវេណីរូបនេះ អង្គជំនុំជម្រះកត់សម្គាល់ថា ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ត្រូវបានស្តាប់ចម្លើយនៅក្នុងកិច្ចស៊ើបអង្កេតដែលកំពុងដំណើរការនៅសំណុំរឿងផ្សេង។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានកំណត់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ស្ថិតនៅក្នុងក្រុម "ក" នៃក្រុមទាំងបីប្រភេទ នៅក្នុងអនុស្សរណៈរបស់ខ្លួន (ឯកសារ E319/35)។ ហើយបានស្នើថា ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ គួរប្រើរហស្សនាមក្នុងគោលបំណងការពារនូវភាពសម្ងាត់នៃកិច្ចដំណើរការស៊ើបអង្កេត។

អង្គជំនុំជម្រះយល់ឃើញថា វិធានការដែលមានមក្រិតបែបនេះ គឺត្រឹមត្រូវ សមស្របតាមច្បាប់នៅក្នុងករណីបែបនេះ។ ហើយបើការបង្គាប់នេះ គឺត្រូវធ្វើឱ្យមានតុល្យភាពគ្នារវាងតម្រូវការនៃ

សាធារណភាពនៃសវនាការ ជាមួយនឹងការការពារសុចរិតភាពនៃការងារស៊ើបអង្កេត។ ហើយអង្គជំនុំជម្រះក៏សូមរំឭកដល់ភាគីដែរថា ឲ្យគោរពឲ្យបានខ្ជាប់ខ្ជួននូវសេចក្តីណែនាំនៅក្នុងឯកសារ E319/7 ក្នុងការប្រើប្រាស់ឯកសារដាក់បង្ហាញពីសំណុំរឿងផ្សេង។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** ជម្រាបសួរលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី។ នៅក្នុងកិច្ចដំណើរការសវនាការ ចំពោះមុខអង្គជំនុំជម្រះ តាមសំណើរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ គឺយើងបានប្រើប្រាស់តែរហស្សនាមរបស់លោកស្រីទេ។ ហើយលោកស្រីដើមបណ្តឹងរដ្ឋប្បវេណីមានរហស្សនាមថា 2-TCCP-274 ហើយជាទូទៅភាគី នឹងតែងតែប្រើប្រាស់ ហៅលោកស្រីក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីប៉ុណ្ណោះ។ អ៊ីចឹងសូមលោកស្រីយល់ថា អង្គជំនុំជម្រះនឹងមិនអនុញ្ញាតឲ្យភាគីពាក់ព័ន្ធ រួមទាំងអង្គជំនុំជម្រះខ្លួនឯងប្រើនាមត្រកូល និងនាមខ្លួនរបស់លោកស្រីជាសាធារណៈក្នុងសវនាការនេះទេ។ លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី តើលោកស្រីចេះអានអក្សរទេ?

[១៥:២៦:៤៨]

**2-TCCP-274៖**

**ឆ៖** ខ្ញុំស្តាប់អត់បាន។

**ស៖** អង្គជំនុំជម្រះជម្រាបសួរលោកស្រីថា--

**ឆ៖** ខ្យល់ខ្លាំងពេក។

**ស៖** លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី លោកស្រីចេះអានអក្សរទេ?

**ប្រធានអង្គជំនុំ៖**

បង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការជួយសម្របសម្រួល ក្នុងការបញ្ជាក់អត្តសញ្ញាណរបស់ដើមបណ្តឹងរូបនេះ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោកស្រីដើមបណ្តឹងរដ្ឋប្បវេណីនេះ តទៅនេះអង្គជំនុំជម្រះសូមឲ្យលោកស្រីបញ្ជាក់អំពីអត្តសញ្ញាណរបស់លោកស្រីដែលមាននៅក្នុងឯកសារ E3/6011 ដែលមានលេខ ERN ជាភាសាខ្មែរ 00496717 ហើយមិនមានជាភាសាអង់គ្លេស និងបារាំងទេ។

01351253



មន្ត្រីរដ្ឋបាលតុលាការយកឯកសារ E3/6011 ទៅជូនលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។ សូមលោកស្រីពិនិត្យមើលកន្លែងដែលមាន *ហាយឡាយ*ពណ៌ទឹកក្រូច ថាតើលោកស្រី តើឈ្មោះលោកស្រី សញ្ជាតិ ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត មុខរបរ ឈ្មោះឪពុក ឈ្មោះម្ដាយ និងចំនួនកូនរបស់លោកស្រី ពិតជាត្រឹមត្រូវទេ? លោកស្រីគ្រាន់តែឆ្លើយថា ការសរសេរនេះ ពិតជាត្រឹមត្រូវ ឬមិនត្រឹមត្រូវបានហើយ។ លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី តើព័ត៌មាននៅក្នុងឯកសារនេះ ត្រឹមត្រូវទេ សូមលោកស្រីឆ្លើយ?

*(ដើមបណ្ដឹងរដ្ឋប្បវេណីមើលឯកសារ)*

លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី តើត្រឹមត្រូវឬទេ?

[១៥:៣០:០០]

**2-TCCP-274៖**

**ឆ៖** ត្រឹមត្រូវ។

**ស៖** អរគុណលោកស្រី។ តើលោកស្រីធ្លាប់ផ្ដល់សក្ខីកម្ម ឬក៏ផ្ដល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ នៅក្នុងរយៈពេលកន្លងមក? ហើយបើប្រសិនធ្វើ ១ប៉ុន្មានដង? ធ្វើនៅកន្លែងណាខ្លះ? លោកស្រីចាំទេ?

**ឆ៖** ធ្វើវាយរងតាមនៅខេត្តកំពង់ចាមហ្នឹង ភ្លេច មិនដឹងប៉ុន្មានដងទេ។ រួចដល់ពេលនៅឯខាងព្រៃវែង ហើយធ្វើនៅភ្នំពេញហ្នឹង អត់ចាំ។

**ស៖** អរគុណលោកស្រី។ ហើយនៅមុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះនេះ តើលោកស្រីបានពិនិត្យមើល ឬក៏បានអាននូវកំណត់ហេតុដែលលោកស្រីបានផ្ដល់សក្ខីកម្មកាលពីពេលមុន ជាមួយអ្នកស៊ើបអង្កេតដើម្បីរំឭកការចងចាំរបស់លោកស្រីដែរទេ? សូមលោកស្រីឆ្លើយ!

**ឆ៖** ខ្ញុំបានជួបនឹងមេធាវី ហើយនិងជួបនឹងអ្នកធ្វើការដែលកន្លងមកហ្នឹងខ្ញុំបានប្រាប់សាច់រឿង។

**ស៖** លោកស្រីមានបានអានកំណត់ហេតុដែលគេយកពីលោកស្រីហ្នឹងទេ?

លោកស្រី ចាំមីក្រូហ្វូនប្រតិបត្តិការចេញភ្លើងក្រហម ចាំលោកស្រីឆ្លើយ។

**ឆ៖** ខ្ញុំបានស្ដាប់កន្លងមកខ្លះៗ ហើយសរសេរប្រាប់ឲ្យខ្ញុំប្រាប់តាមរយៈមេធាវី ឬអ្នកដឹកនាំនេះទៅហ្នឹងមាន ទៅជាមួយហ្នឹង បានខ្លះៗដែរ។

[១៥:៣២:០៥]

**ស៖** អរគុណលោកស្រី។ តាមសមត្ថភាពដែលលោកស្រីអាចដឹង និងចងចាំបាន តើលោកអាចបញ្ជាក់បានទេថា កំណត់ហេតុដែលស្តាប់ចម្លើយដែលលោកស្រីបានអានដើម្បីរំឭកការចងចាំនោះ គឺពិតជាត្រឹមត្រូវ សមស្រប ស៊ីសង្វាក់គ្នានឹងសក្ខីកម្មដែលលោកបានផ្តល់កិច្ចសម្ភាសន៍ជាមួយអ្នកស៊ើបអង្កេតកាលពីមុនៗទេ?

**ឆ៖** ចាស។

**ស៖** តាមសមត្ថភាពដែលលោកស្រីអាចដឹង និងចងចាំបាន តើលោកស្រីអាចបញ្ជាក់បានទេថា ទម្រង់បែបបទព័ត៌មានដែលលោកស្រីបានអាន ដើម្បីរំឭកការចងចាំនោះ គឺពិតជាត្រឹមត្រូវ សមស្រប ស៊ីសង្វាក់គ្នា ទៅនឹងព័ត៌មានដែលលោកស្រីបានធ្វើជាមួយអង្គភាពជនរងគ្រោះកាលពីមួយមុនដែរឬទេ?

**ឆ៖** ចាស បាន។

**ប្រធានអង្គជំនុំ៖**

លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះកោះអញ្ជើញលោកស្រីមកផ្តល់សក្ខីកម្មថ្ងៃនេះក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងកិច្ចដំណើរការនីតិវិធីចំពោះមុខអង្គជំនុំជម្រះ។ ហេតុដូច្នេះ នៅចុងក្រោយបង្អស់នៃការផ្តល់សក្ខីកម្មរបស់លោកស្រី ៗអាចមានសិទ្ធិធ្វើសេចក្តីថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្ម មានន័យថា ជាផលអន្តរាយដែលកើតមានចំពោះលោកស្រី នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រសិនបើលោកស្រីមានបំណងធ្វើដូច្នេះ។

ក្នុងការសួរដេញដោលសាក្សីរូបនេះ អនុវត្តតាមបញ្ញត្តិ៩១ស្ទួននៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅឲ្យសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការសួរដេញដោលសាក្សីនេះមុនភាគីដទៃទៀតនៃរឿងក្តី។ ហើយសហមេធាវីនាំមុខ រួមជាអ្នកតំណាងសហព្រះរាជអាជ្ញាមានរយៈពេលពីរវគ្គសវនាការ។ សូមអញ្ជើញមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានសំណួរ។

[១៥:៣៤:៣០]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម មេធាវីនាំមុខសូមអនុញ្ញាតប្រគល់ការសួរសំណួរនេះជូនទៅលោកមេធាវី ហុង គឹមសួន។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីដើមបណ្តឹងរដ្ឋប្បវេណី!

**លោក ហុង គីមសួន៖**

ខ្ញុំបាទ សូមអរគុណ។ ជាដំបូង ខ្ញុំបាទសូមគោរពលោកប្រធាន លោកស្រី លោកចៅក្រម និង អង្គសវនាការជាទីគោរព។ ខ្ញុំបាទ មេធាវី ហុង គីមសួន ជាមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និង ជាមេធាវីនៃអង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោក ហុង គីមសួន៖**

**ស៖** សូមជម្រាបសួរលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។ តទៅនេះ ខ្ញុំសួរលោកស្រីទាក់ទងជាមួយនឹងការរៀបការនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ឬក្នុងសម័យរបបខ្មែរក្រហមដែលមានសំណួរជាលំដាប់លំដោយ ហើយលោកស្រីអាចសួរមកខ្ញុំវិញ បើសិនជាលោកស្រីមិនយល់។ សំណួរជាដំបូង ខ្ញុំបាទចង់សួរថា មុនឆ្នាំ១៩៧៥ ខែមេសា ថ្ងៃ១៧ មេសា តើលោកស្រី និងក្រុមគ្រួសារលោកស្រីរស់នៅទីកន្លែងណា?

[១៥:៣៥:៤៩]

**2-TCCP-274៖**

**ឆ៖** ឆ្នាំ៧៥ ខ្ញុំរស់នៅក្នុងអង្គភាពលេខ៧។

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់សួរទីលំនៅ មានភូមិ មានឃុំ ស្រុក ខេត្តជាដើម។

**ឆ៖** ខ្ញុំរស់នៅភូមិតាអង្គ ឃុំតាអង្គ ស្រុកចំការលើ។

**ស៖** ចុះបន្ទាប់ពីថ្ងៃ១៧ ខែមេសា ១៩៧៥ ឬក៏អាចហៅថានៅក្រោយពេលដែលរបបកម្ពុជាប្រជាធិបតេយ្យ ឬរបបខ្មែរក្រហមកាន់កាប់ទូទាំងប្រទេសបានហើយណ៎ា តើលោកស្រី និងក្រុមគ្រួសារលោកស្រីមករស់នៅកន្លែងដើម ឬផ្លាស់ទៅរស់នៅកន្លែងណាផ្សេងទៀត?

**ឆ៖** ខ្ញុំរស់នៅឯខាងភូមិលេខ៧។

**ស៖** លោកស្រីអាចបញ្ជាក់បានទេ ភូមិលេខ៧ហ្នឹងស្ថិតនៅក្នុងឃុំអី ស្រុកអី ឬក៏ខេត្តអីដែរ?

**ឆ៖** លេខ៧ហ្នឹង គេដាក់ឈ្មោះថាលេខ០៧ ប៉ុន្តែភូមិវាហ្នឹង បើស្រុកចំការលើ ខេត្តកំពង់ចាម ដែរ ប៉ុន្តែគ្រាន់តែនៅពីឆ្ងាយពីភូមិផ្ទះខ្ញុំ។

**ស៖** បាទ សូមអរគុណ។ នៅក្នុងភូមិលេខ៧ហ្នឹង តើលោកស្រីនៅក្នុងអង្គភាពជាស៊ីវិល ជាកងចល័ត ឬក៏កងវ័យកណ្ដាល ឬក៏កងទ័ពជាដើម?

[១៥:៣៦:៤២]

**ធ៖** ខ្ញុំនៅជាសហជីព។

**ស៖** បាទ សូមអរគុណ។ តើនៅក្នុងសហជីពរបស់លោកស្រីនោះគ្រប់គ្រងដោយមេបញ្ជាការជាកងទ័ព ឬក៏ជាស៊ីវិល?

**ធ៖** នៅជាមួយប្រធានអង្គភាពគេ។

**ស៖** បាទ សូមអរគុណ។ លោកស្រីអាចជម្រាបបានទេ ថាក្នុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង លោកស្រីមានបានទទួលការឲ្យរៀបអាពាហ៍ពិពាហ៍ដែរឬទេ?

**ធ៖** ចាស មាន។

**ស៖** ចុះមុនពេលដែលលោកស្រីរៀបអាពាហ៍ពិពាហ៍នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យហ្នឹង មុនពេលដែលរៀបអាពាហ៍ពិពាហ៍ក្រោយនេះ តើធ្លាប់មានរៀបអាពាហ៍ពិពាហ៍ស្វាមីលើកមុនហើយដែរឬទេ?

**ធ៖** ពីសង្គមមាន។

**ស៖** តើស្វាមីទី១ របស់លោកស្រីពីសង្គមនោះ គាត់បានបែកគ្នា ឬក៏មានរឿងរ៉ាវដែលៗត្រូវបានចាកចេញពីលោកស្រី?

**ធ៖** គាត់ទៅធ្វើការ គេហៅធ្វើការបដិវត្តន៍។ ធ្វើកងទ័ព គេហៅកងយោធាគេ កងទ័ពយោធា។

[១៥:៣៨:៤៥]

**ស៖** តើមានរឿងអ្វីកើតឡើងចំពោះស្វាមីអ្នកស្រីលើកមុននោះ?

**ធ៖** ខ្ញុំមិនសូវជាច្បាស់នឹងកាលនុ៎ង ពីគេហៅមួយជំនាន់ យៀកកុងវាយចូលលុក តែប៉ុណ្ណឹង ខ្ញុំសូវអត់ដឹងច្បាស់ដែរ វាភ្លេច យូរហើយដែរ។

**ស៖** តើស្វាមីលោកស្រី ពេលនោះ គាត់នៅទីណាដែរ គាត់រស់នៅដល់សព្វថ្ងៃដែរទេ?

**ធ៖** គាត់ស្លាប់បាត់យូរហើយ តាំងពីជំនាន់យៀកកុងហ្នឹងចូលមកម្ល៉េះ។

**ស៖** តើស្វាមីទី១របស់លោកស្រីហ្នឹង កាលនោះ អ្នកស្រីមានកូនៗប៉ុន្មាននាក់ជាមួយគាត់ដែរ?

**ប្រធានអង្គជំនុំ៖**

លោកស្រី ចាំៗមីក្រូហ្វូនប្រតិបត្តិការ មានភ្លើងក្រហម ចាំលោកស្រីឆ្លើយ។

**2-TCCP-274៖**

**ឆ៖** មានកូនមួយ ចាស។

**សួរដោយលោក ហុង គីមសួន៖**

**ស៖** បាទ សូមអរគុណ។ ដោយសារលោកស្រីបានឆ្លើយថា ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ លោកស្រីបានរៀបអាពាហ៍ពិបាហ៍ម្តងទៀត។ ខ្ញុំសូមសួរលោកស្រី ថាតើនៅឆ្នាំណា អ្នកស្រីអាចចងចាំបានទេ ដែលត្រូវបានរៀបអាពាហ៍ពិពាហ៍លើកទី២នេះ?

[១៥:៤១:២២]

**ឆ៖** ឆ្នាំ១៩៧៧ ដើមឆ្នាំ។

**ស៖** ពេលរៀបអាពាហ៍ពិពាហ៍លើក នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យហ្នឹង គេហៅថា រៀបអាពាហ៍ពិពាហ៍រៀបការ ឬគេហៅឈ្មោះរៀបការហ្នឹងយ៉ាងម៉េចផ្សេងពីពាក្យរៀបការដែរទេ?

**ឆ៖** ទៅរៀបការហ្នឹង គេហៅ មិនមែនហៅរៀបការ រៀបគ្រួសារ ហើយគេយកខ្ញុំទៅរៀបគ្រួសារហ្នឹង ខ្ញុំអត់ដឹងទេ ប៉ុន្តែទៅដល់កន្លែង បានគេប្រាប់។

**ស៖** បាទ សូមអរគុណ។ ពេលហ្នឹងលោកស្រីនៅជាកន្លែងការងាររបស់លោកស្រីហ្នឹង គេហៅអីដែរ?

**ឆ៖** កន្លែងខ្ញុំនៅហ្នឹង មន្ទីរអង្គភាពលេខ៧។ ខ្ញុំធ្វើការនៅសហជីពហ្នឹង។

**ស៖** នៅក្នុងពេលរៀបការលើកទី២នេះ តើលោកស្រីដឹងមុនទេថា លោកស្រីនឹងត្រូវបានគេឲ្យទៅរៀបការ?

**ឆ៖** អត់ដឹងទេ។ ទៅដល់កន្លែង បានគេប្រាប់។

**ស៖** តើគេប្រាប់លោកស្រីថាម៉េចខ្លះ?

**ឆ៖** គេថាសមមិត្តឯង ត្រូវតែរៀបគ្រួសារ។ នាងខ្ញុំបានប្រកែកថា ខ្ញុំអត់ទាន់ចង់បានទេ ព្រោះខ្ញុំមានកូនទៅហើយ។ រួចដល់តែគេថា អត់ទេ ត្រូវតែរៀប បើមិនរៀបទេ គេមានវិធានការផ្សេង។

**ស៖** អ្នកដែលប្រាប់លោកស្រីថា ទៅរៀបការហ្នឹង គេជាអ្នកណា?

**ឆ៖** ប្រធានអង្គភាពលេខ៧ ឈ្មោះ ឆេន ចាស។

[១៥:៤៣:៥៨]

**ស៖** តើនៅពេលដែលគេប្រាប់ទៅរៀបការហ្នឹង គេមានប្រាប់ថា គូស្រករ ឬក៏ស្វាមីរបស់

លោកស្រីហ្នឹងជាអ្នកណា ឬក៏ឈ្មោះអីដែរ?

**ឆ៖** អត់មានទេ លោកគ្រូ អត់មាន។ អត់មានប្រាប់ថា ឈ្មោះអី ឈ្មោះអីទេ។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងលោកស្រី បានដឹង ធ្លាប់ស្គាល់ ឬក៏បានស្គាល់ថាគូរបស់លោកស្រីដែលនឹងត្រូវរៀបការហ្នឹង ជាអ្នកណាទេ ពេលទៅដល់នោះ?

**ឆ៖** អត់ដឹងទេ ទាល់តែពេលចូលកម្មវិធីបានគេប្រកាសប្រាប់។

**ស៖** បាទ សូមអរគុណ។ លោកស្រីអាចជម្រាបជូនលោកប្រធាន និងអង្គសវនាការបានទេថា នៅពេលដែលរៀបអាពាហ៍ពិពាហ៍ ឬក៏ថ្ងៃរៀបការនោះ ធ្វើឡើងនៅក្នុងសហករណ៍ ឬនៅទីតាំងអង្គភាព ឬកន្លែងៗណាមួយនៃភូមិ ឃុំ ស្រុក ខេត្តជាដើម ចាំបានទេ?

**ឆ៖** ចាស នាងខ្ញុំចាំបាន។ កាលពីគេហៅខ្ញុំពីអង្គភាពលេខ៧ទៅដល់ គេនៅក្នុងអង្គភាពហ្នឹង គេហៅ "មន្ទីរក្នុង"។ មន្ទីរក្នុងហ្នឹងមានយោធាមួយចំហៀង ហើយនិងមន្ទីរខាង តាសាត ហ្នឹងមួយចំហៀង។ អ៊ីចឹងមានមន្ទីរពីរហ្នឹង។

**ស៖** អំម្បាញ់មិញលោកស្រីមានប្រសាសន៍អំពីមន្ទីរក្នុង ឬមន្ទីរ តាសាត។ តើមន្ទីរក្នុងហ្នឹងជាមន្ទីរអ្វី? ជាកន្លែងរបស់ខាងយោធា ឬខាងសហករណ៍ ឬខាងឃុំ គណៈឃុំ ឬតំបន់ជាដើម តើលោកស្រីស្គាល់ទេកន្លែងហ្នឹង?

**ឆ៖** កន្លែងហ្នឹងគេហៅ "មន្ទីរក្នុង" អ៊ីចឹងតែម្តង។ ហើយកន្លែងហ្នឹងគេហៅ "មន្ទីរក្នុង" ហ្នឹងគេ និយាយរួមបើសិនជាគេហៅនេះ គេហៅភូមិលេខ២ ភូមិចំការអណ្តូង គេហៅមន្ទីរក្នុងអ៊ីចឹងតែម្តង។

[១៥:៤៦:៥៨]

**ស៖** បាទ សូមអរគុណ។ នៅថ្ងៃរៀបការលោកស្រី តើគូរបស់លោកស្រីគាត់ឈ្មោះអីដែរ?

**ឆ៖** គាត់ឈ្មោះ ញៀន។

**ស៖** លោកស្រីបានស្គាល់ឈ្មោះស្វាមីលោកស្រី ដោយរបៀបណាពេលនោះ?

**ឆ៖** ក្រោយមកបានខ្ញុំស្គាល់ ពីដំបូងខ្ញុំអត់ស្គាល់ផង។

**ស៖** អំម្បាញ់មិញលោកស្រីបានមានប្រសាសន៍អំពីគេៗប្រាប់ឲ្យមកដល់កន្លែងហើយ នឹងរៀបការ ប៉ុន្តែលោកស្រីបានប្រាប់គេថា លោកស្រីធ្លាប់មានប្តី មានកូនហើយ។ តើលោកស្រី ពេលគេប្រាប់ថាត្រូវដល់ពេលរៀបការគូថ្មី ឬក៏រៀបការស្វាមីថ្មីអ៊ីចឹង តើលោកស្រីមានអ្វីជំទាស់ ឬក៏មានការប្រកែកជាមួយនឹងគេដែរទេពេលនោះ?

**ឆ៖** នាងខ្ញុំបានប្រកែក នាងខ្ញុំមិនព្រមថាអត់យកទេ ប៉ុន្តែមានសមមិត្តឃោធាហ្នឹងឈ្មោះ មិត្តផាន់ ហ្នឹងគេថាត្រូវតែយក ត្រូវតែរៀប។ ហើយយើងខ្ញុំអត់ហ៊ាននិយាយទេ ព្រោះកន្លងមកខ្ញុំមានការខ្លាច ព្រោះនៅនុំងតែប្រកែក អត់បាន ដឹងតែបាត់ខ្លួន។

**ស៖** លោកស្រីជម្រាបអង្គសវនាការបានទេ ការប្រកែកមិនរៀបអាពាហ៍ពិពាហ៍បាត់ខ្លួនហ្នឹង តើអ្នកដែលបាត់ខ្លួនហ្នឹងទៅណាដែរ?

**ឆ៖** ភាគច្រើនគេប្រាប់ថា ទៅបាត់ខ្លួនហ្នឹង គេហៅទៅ ជួនកាលគេហៅទៅបែកចានអ៊ីចឹងទៅ គេហៅទៅ៤១អ៊ីចឹងទៅ ទៅបាត់រហូតដល់សព្វថ្ងៃទៅ។

[១៥:៤៩:១០]

**ស៖** លោកស្រីដែលឃើញគេចាប់អ្នកដែលមិនព្រមរៀបការចង ឬក៏យកទៅសម្លាប់ដែរទេ?

**ឆ៖** ចាស ឃើញ។ គ្រាន់តែថាហៅទៅអារឿងចងចាប់អីហ្នឹង អត់មានដែលឃើញទេ ឃើញហៅទៅ ដាក់ឡានទៅ បាត់តែម្តងចាស។

**ស៖** អ៊ីចឹងបើសិនជាលោកស្រីមិនបានឃើញនឹងភ្នែកអំពីថាគេសម្លាប់ ឬគេចាប់ចងអីទេនោះ តើលោកស្រីមិនហ៊ានប្រកែក លោកស្រីអះអាងថាខ្លាចហ្នឹង មានអ្វីដែលធ្វើឲ្យលោកស្រីដែលខ្លាចមិនហ៊ានប្រកែកទទួលយកការរៀបការនេះ?

**ឆ៖** នាងខ្ញុំបានប្រាប់ថា ពីអង្គាល់គេការ គេនេះហ្នឹង ព្រោះកន្លងមក នាងខ្ញុំឃើញអ្នកច្រើនគ្នាហើយ ដែលប្រកែកៗហ្នឹងបាត់ខ្លួនបាត់ ហើយអ្នកខ្លះហ្នឹងក៏គេមានខ្សែណោះខ្សែណោះទៅ ចំពោះខ្លួនខ្ញុំតែម្តង ខ្ញុំប្រកែក គឺដាច់ខាតមិនយក ប៉ុន្តែគេត្រូវតែចាប់បង្ខំឲ្យរៀប ព្រោះត្រូវឲ្យទៅរៀបហ្នឹងតែម្តង។

**ស៖** បាទ សូមអរគុណ។ នៅថ្ងៃដែលរៀបការ ឬក៏ថ្ងៃមង្គលការរបស់លោកស្រីនោះ តើអ្នកណាជាប្រធាននៃកម្មវិធីរៀបការនោះ?

**ឆ៖** ចាស សមមិត្ត ផាន់ ហើយក្រៅទៀត មានអង្គភាពផ្សេងៗចូលរួម ខ្ញុំមិនអាចស្គាល់។

**ស៖** នៅថ្ងៃរៀបការនោះ មានប៉ុន្មានគូ អ្នកស្រីនៅចងចាំបានទេ?

**ឆ៖** ចាស ១២គូ។

[១៥:៥១:២២]

**ស៖** បាទ អរគុណ។ នៅក្នុងពិធីមង្គលការនោះ តើមានឪពុកម្តាយខាងប្រុសខាងស្រីហ្នឹងចូលរួមពិធីមង្គលការដែរទេ?

ផ៖ ចាស អត់មានទេ។

ស៖ តើមានភ្លេងប្រពៃណីខ្មែរប្រគំលេងបទភ្លេងការក្នុងពិធីនោះដែរទេ?

ផ៖ អត់មានទេចាស។

ស៖ ចុះមានលោកសង្ឃចូលមកសូត្រប្រោះព្រំជយន្តោឲ្យក្នុងពិធីមង្គលការដែរទេ?

ផ៖ អត់មានទេ លោកសង្ឃ។

ស៖ មានពិធីបាចផ្កាស្លា បាចប្រោះព្រំនៅក្នុងមង្គលការដែរទេ?

ផ៖ គ្មានទេ អ្វីៗគ្មានទាំងអស់ អត់មានដូចសម័យឥឡូវទេ អត់មានទាំងអស់។

ស៖ ចុះអំពីរបៀបស្លៀកពាក់វិញ តើពេលនោះគេឲ្យស្លៀកពាក់ជាឈុតមង្គលការ ឬក៏ឈុតយ៉ាងម៉េចដែរ?

ផ៖ ស្លៀកខោ ស្លៀកសំពត់ខ្មៅ ពាក់អាវខ្មៅ បង់កក្រមា។

ស៖ បាទ សូមអរគុណ។ តើមានគេតុបតែងជាវេទិកា ឬក៏រោង ដូចរោងមង្គលការ មានផ្កាមានពណ៌លម្អដែរទេ?

ផ៖ អត់មានទេចាស តុគេ មានដូចតុកូនក្មេងរៀនទាល់សព្វថ្ងៃហ្នឹង អាតុរៀនវែងៗ។

ស៖ អ្នកស្រីមានចាប់អារម្មណ៍ថា នៅខាងក្រោយឆាក ឬកន្លែងដែលរៀបអាពាហ៍ពិពាហ៍ហ្នឹងមានតាំងជារូបភាព ឬរូបសញ្ញាអ្វីនៃកន្លែងរៀបការហ្នឹងដែរទេ?

ផ៖ ខ្ញុំឃើញគេដាក់រូបកណ្ដៀវ ដាក់មានកណ្ដៀវមួយ។

[១៥:៥៣:៥៤]

ស៖ បាទសូមអរគុណ។ នៅក្នុងពិធីមង្គលការ តើមានរៀបចំជាម្ហូបអាហារ បង្អែម ឬភេសជ្ជៈអ្វីទទួលទេពេលនោះ?

ផ៖ គេរៀបធម្មតា មិនមែនម្ហូបដូចយើងសព្វថ្ងៃ ម្ហូបនៅជំនាន់ ប៉ុល ពត ម្ហូបវាមាន ៗម្ហូបអីបាយលាយអីហ្នឹង ហូបធម្មតា ប៉ុន្តែមិនចាំថាម្ហូបអីខ្លះ។

ស៖ តើលោកស្រីបានទទួលទាននូវម្ហូបអាហារ ដែលគេរៀបចំនៅមង្គលការនោះដែរទេ ថ្ងៃនោះ?

ផ៖ ចាស អត់បានទេ ព្រោះខ្ញុំពិបាកចិត្ត ហើយខ្ញុំអត់ចង់បានគ្រួសារហ្នឹងផង។

ស៖ បាទ ចូលដល់ចំណុចនេះ តើមានន័យយ៉ាងម៉េច លោកស្រីថាពិបាកចិត្តមិនពេញចិត្តនៅ

ក្នុងការរៀបការពេលហ្នឹង?

ឆ៖ ខ្ញុំអត់ពេញចិត្ត ហើយនិងគេបង្ខិតបង្ខំខ្ញុំ ហើយខ្ញុំនឹកអន់ចិត្តខ្លួនខ្ញុំ ខ្ញុំអត់អាចហួបកើត។

ស៖ ចំណុចត្រង់ណាដែលលោកស្រីអន់ចិត្ត មិនពេញចិត្តនោះ?

ឆ៖ មនុស្សដែលអត់ស្គាល់គ្នា។ មនុស្សខ្ញុំអត់ពេញចិត្ត។

ស៖ លោកស្រីអាចបញ្ជាក់ជូនអង្គសវនាការបានទេ ថាតើគូរបស់លោកស្រី ឬក៏យើងហៅថាស្វាមីខាងលោកស្រីនោះ គាត់មានរូបរាងយ៉ាងម៉េចដែរពេលនោះ?

ឆ៖ រូបរាងគាត់អាក្រក់ ហើយគាត់និយាយរដឺនៗ របៀបដូចជនជាតិ ហើយគាត់ខ្មៅតែម្ដង។ ហើយមនុស្សហ្នឹងរបៀបដូចនៅធ្វើយោធាគួរឲ្យខ្ញុំខ្លាច ហើយខ្ញុំអត់ចូលចិត្ត ខ្ញុំស្អប់។

[១៥:៥៥:៥៨]

ស៖ តើកាយសម្បទា ដៃជើង មុខមាត់ ភ្នែកច្រមុះអីគាត់មានគ្រប់គ្រាន់ទេ ពេលគូស្វាមីរបស់លោកស្រី?

ឆ៖ ដៃជើងរាងដើរមិនសូវជាត្រង់ទេ ភ្នែករាងអន់។

ស៖ លោកស្រីចងចាំបានខ្លះទេថា ពេលថ្ងៃដែលត្រូវរៀបអាពាហ៍ពិពាហ៍ ឬក៏រៀបការថ្ងៃនោះ លោកស្រីអាយុប្រហែលជាប៉ុន្មាន ហើយស្វាមីលោកស្រីអាយុប្រហែលជាប៉ុន្មានឆ្នាំដែរ?

ឆ៖ នាងខ្ញុំប្រហែលជាអាយុ បើមិន២៣, ២៤ចាស ហើយគ្រួសារហ្នឹងប្រហែលជាអាយុបើមិន៤៧, ៤៨។

ស៖ បាទសូមអរគុណ។ ពេលរៀបអាពាហ៍ពិពាហ៍ថ្ងៃនោះ តើរៀបពេលថ្ងៃ ឬក៏ពេលរសៀល ឬក៏ពេលយប់?

ឆ៖ ពេលព្រលប់ៗ ស្មើនឹងរបៀបថាប្រហែលជាម៉ោងប្រាំ ឬម៉ោងប្រាំកន្លះ ទៅម៉ោងប្រាំមួយប្រហែលប៉ុណ្ណឹង។

ស៖ បាទ សូមអរគុណ។ ចុះនៅពេលពិធីរៀបការព្រលប់ ឬយប់ថ្ងៃនោះ មានភ្លើងអគ្គិសនីមានភ្លើងពណ៌លម្អពិធីមង្គលការដែរទេ?

ឆ៖ ចាស អត់មានទេ អត់មានភ្លើងនៅខាងនុំង។ ពីដើមគេច្រើនប្រើ កន្លែងនុំងច្រើនមានម៉ាំងសុងប្រើ។

[១៥:៥៧:៥៧]

01351262



**ស៖** លោកស្រីមានប្រសាសន៍អំពីម៉ុំាងសុងហ្នឹងយ៉ាងម៉េចដែរ? ទ្រង់ទ្រាយម៉ុំាងសុងនឹងជាភ្លើងអគ្គិសនី ឬក៏ជាចន្លុះ ឬចង្កៀង ឬអំពូល?

**ឆ៖** ម៉ុំាងសុងនុ៎ង វាមានៗនេះវែងអ៊ីចឹងទៅ ហើយវាមានដៃវាមួយ ហើយវាមានសំបុកវា សំបុកវាទៅ គេសប់ៗវាទៅ វាឆេះ គេប្រើប្រេងកាត ប្រេងម៉ាស៊ូត។

**លោក ហុង គីមសួន៖**

បាទ សូមអរគុណ។

លោកប្រធាន តើពេលវេលានឹងបន្ត ឬក៏សម្រាកម៉ោងថ្មើរនេះលោកប្រធាន?

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ ឥឡូវនេះដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ ហើយសវនាការនឹងបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃអង្គារ ទី២៣ ខែសីហា ឆ្នាំ២០១៦ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ សវនាការនៅថ្ងៃស្អែកអង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-274 បញ្ចប់ ហើយនិងអាចចាប់ផ្តើមស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-224 សូមភាគីជ្រាប និង អញ្ជើញចូលរួមតាមពេលវេលាដែលបានកំណត់នេះ។

បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប លោក នួន ជា និង លោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីឃុំឃាំងនៃអ.វ.ត.ក វិញចុះ ហើយបង្គាប់ឱ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃអង្គារ ទី២៣ ខែសីហា ឆ្នាំ២០១៦ ឱ្យបានមុនម៉ោងប្រាំបួនព្រឹក។

សូមអញ្ជើញសម្រាក៕

*(សវនាការផ្អាកនៅម៉ោង ១៥:៥៩ នាទី)*